# ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

**វិទ្យាស្ថានជាតិអប់រំ**
National Institute of Education

## និក្ខេបបទ

## កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី ក្នុងខេត្តស្វាយរៀង

Factors Influencing the Students'quality Academic Performance in New Generation School in Svay Rieng Province

ដោយ/by

**អ៊ិន ចាន់ថា**

**IN CHANTHA**

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**

**ឯកទេសៈ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៧-២០១៩**

**សាស្ត្រាចារ្យដឹកនាំៈ បណ្ឌិត ម៉ុក សារ៉ុម**
**សាស្ត្រាចារ្យដឹកនាំរងៈ លោក គួយ សូគាន**

**ឧបត្ថម្ភដោយៈ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**
Supported by Cambodia International Education Support Foundation ( CIESF )

## ក្រសួងអប់រំ យុវជន និងកីឡា
Ministry of Education, Youth and Sport

## វិទ្យាស្ថានជាតិអប់រំ
National Institute of Education

# និក្ខេបបទ

# កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី ក្នុងខេត្តស្វាយរៀង

Factors Influencing the Students'quality Academic Performance in New Generation School in Svay Rieng Province


**ដោយ**/by

**អ៊ិន ចាន់ថា**

**IN CHANTHA**


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៧-២០១៩**


**សាស្ត្រាចារ្យដឹកនាំ៖** បណ្ឌិត ម៉ុក សារ៉ុម
**សាស្ត្រាចារ្យដឹកនាំរង៖** លោក គួយ សូគាន



**ឧបត្ថមដោយ៖ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**
Supported by Cambodia International Education Support Foundation ( CIESF )

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៩៦២៩ អយក. ១ស
(ការសម្ងាត់)

## លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យូន រិទ្ធិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត ស៊ិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កន្លែងទទួល៖**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# **សេចក្តីប្រកាសអះអាងរបស់បេក្ខជន**

ខ្ញុំបាទសូមបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា "**កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី**" សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំគឺជាស្នាដៃផ្ទាល់របស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បាន ប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់សញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ គ្មានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវនេះ ពិតជាចងក្រងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃ អង្គារ ៤កើត ខែ មិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែ ធ្នូ ឆ្នាំ២០១៩

ហត្ថលេខាបេក្ខជន

**អ៊ិន ចាន់ថា**

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា (CIESF) Cambodia International Education Support Foundation ដែលបានរៀបចំ និងផ្តល់អាហាររូបករណ៍ដល់ខ្ញុំបាទបានសិក្សាបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំនាពេលកន្លងមក។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់គណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលដ៏មមាញឹក និងមានតម្លៃមកបង្ហាត់បង្រៀន និងពន្យល់ណែនាំគ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នាដោយមិនគិតពីការនឿយហត់ឡើយ។ ជាពិសេសខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតដល់ **ឯកឧត្តមបណ្ឌិត ម៉ុក សារ៉ុម** សាស្ត្រាចារ្យដឹកនាំ ដែលតែងតែចំណាយពេលវេលាដ៏មមាញឹកមកពន្យល់ខ្ញុំបាទគ្រប់ជំហានទើបធ្វើឲ្យការស្រាវជ្រាវរបស់ខ្ញុំបាទ នាពេលនេះទទួលបានជោគជ័យ និងភាពរលូន។ ជាមួយគ្នានេះដែរ ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់លោក សាស្ត្រាចារ្យដឹកនាំរង **គួយ សុគាន** និងមិត្តរួមជំនាន់ទី៦ទាំងអស់ដែលតែងតែផ្តល់ជាគំនិតល្អៗ និងកម្លាំងចិត្ត តាមរយៈការចែករំលែក ចំណេះដឹង បទពិសោធន៍ ព័ត៌មានទាំងឡាយដល់រូបខ្ញុំបាទ ដើម្បីឲ្យការស្រាវជ្រាវនេះមានភាពងាយស្រួល។

បន្ថែមពីនេះទៀតខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់ លោកឪពុក អ្នកម្តាយ បងប្អូន និងជាពិសេសភរិយារបស់ខ្ញុំបាទ ព្រមទាំងកូនសម្លាញ់ *អ៊ិន ចន្ទឧត្តម* ដែលបានផ្តល់នូវកម្លាំងចិត្ត ពេលវេលា ប្រាក់កាស និងតែងតែជំរុញ ព្រមទាំងលើកទឹកចិត្តដើម្បីឲ្យខ្ញុំបានបន្តការសិក្សារហូតបានបញ្ចប់នូវការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ។

ជាទីបញ្ចប់ខ្ញុំបាទសូមប្រសិទ្ធិពរជូនចំពោះ ឯកឧត្តមបណ្ឌិត លោកសាស្ត្រាចារ្យ មិត្តរួមថ្នាក់ និងក្រុមគ្រួសារ ព្រមទាំងភរិយារបស់ខ្ញុំបាទឲ្យជួបតែពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

# មូលន័យសង្ខេប

ការអប់រំបានដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស និងជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ការអប់រំប្រកបដោយគុណភាពជាកត្តាសំខាន់បំផុត ។ គុណភាពនៃការអប់រំ ត្រូវពឹងផ្អែកលើកត្តាសំខាន់ បីគឺ ១)គុណភាពសាស្ត្រាចារ្យ ឬគ្រូបង្រៀន គឺត្រូវមានចំណេះដឹង ផ្នែកបច្ចេកទេស គរុកោសល្យបច្ចេកទេសទាក់ទងនឹងការអប់រំ ចំណេះដឹងផ្នែកភាសាបរទេស មានមនសិការវិជ្ជាជីវៈ និងមានបុគ្គលិកលក្ខណៈល្អ។ ២) គុណភាពកម្មវិធីសិក្សា ត្រូវផ្តោតលើការវិភាគទីតាំង បរិយាកាសជុំវិញ ចំនួនសិស្ស និន្នាការរបស់សិស្ស និងប្រតិកម្មរបស់សិស្ស សិក្សាប្រៀបធៀបនូវកម្មវិធីសិក្សារបស់បណ្តាប្រទេសក្នុងតំបន់ និងក្នុងសកលលោក។ ៣) គុណភាពសម្ភារៈរូបវន្ត ដោយបន្តកែលម្អ និងធ្វើទំនើបកម្មសៀវភៅសិក្សា បន្តពង្រឹងគុណភាពមជ្ឈមណ្ឌលឯកសារ បណ្ណាល័យ សម្ភារៈឧបទ្ទេស ឧបករណ៍នានា និងសម្ភារៈបច្ចេកវិទ្យាសម្រាប់ប្រើប្រាស់បម្រើឲ្យការអប់រំ និងការងារស្រាវជ្រាវពិសោធន៍។

ការស្រាវជ្រាវនេះមានគោលបំណងរកឲ្យឃើញនូវៈ

១. កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី។

២. ប្រៀបធៀបកត្តាជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស តាមកម្រិតថ្នាក់ និងភេទរបស់សិស្ស។

ការសិក្សាស្រាវជ្រាវនេះ ផ្អែកលើទ្រឹស្តី និងឯកសារមួយចំនួនដែលពាក់ព័ន្ធ ជាពិសេសក្រសួងអប់រំ យុវជន និងកីឡា និងអ្នកស្រាវជ្រាវមុន។ ទិន្នន័យដែលប្រមូលបានពីសាលារៀនជំនាន់ថ្មី ដែលមានសិស្សចំនួន ៣០០ នាក់ ស្រី ១៤៦ នាក់ ចេញពីសិស្សថ្នាក់ទី៧ ទី៨ និងទី៩។ អ្នកសិក្សាស្រាវជ្រាវបានធ្វើការសិក្សាតាមបែបបរិមាណវិស័យ ដោយផ្តោតទៅលើសំណួរចំនួន ពីរ គឺ (១)តើមានកត្តាអ្វីខ្លះ ដែលជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី? (២)តើមានភាពខុសគ្នា និងដូចគ្នាអ្វីខ្លះ រវាងកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មីតាមកម្រិតថ្នាក់ និងភេទរបស់សិស្ស?

លទ្ធផលបានពីការសិក្សាស្រាវជ្រាវ បានបង្ហាញឲ្យឃើញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី បើសង្កេតជាទូទៅកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សគឺ

(១) លទ្ធផលជាទូទៅនៃកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មីមានដូចតទៅៈ (១) សិស្សមានស្មារតីឧស្សាហ៍ព្យាយាមប្រឹងប្រែងរៀនសូត្រ គឺមានកម្រិតខ្ពស់ ៤.១៣ (M= 4.13)។ (២) គ្រូត្រូវប្រឡងចូលដើម្បីបានបង្រៀននៅសាលាជំនាន់ថ្មី គឺ មានកម្រិតខ្ពស់ ៤.០៦ (M= 4.06) និងកម្រិតខ្ពស់ចុងក្រោយគឺ(៣) គ្រូ និងសិស្សប្រើប្រាស់កុំព្យូទ័រ tablets និងស្លាយដើម្បីរៀន និងបង្រៀន មានកម្រិតខ្ពស់ ៤.០៣ (M= 4.03) ។

(២) ចំពោះការសិក្សាទៅលើផ្នែកនីមួយៗ បានរកឃើញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី មានដូចជា៖១) កត្តាសាលារៀន ស្ថិតក្នុងកម្រិតខ្ពស់ គឺ ៣.៧៦ (M=3.76) ២) កត្តាសង្គម មានកម្រិតមធ្យម ៣.៤២ ៣) កត្តាសិស្ស មានកម្រិតមធ្យម ២.៥៩ និង ៤) កត្តាគ្រួសារ មានកម្រិតមធ្យម ២.៥៩ (M=2.59)។

(៣) លទ្ធផលនៃការប្រៀបធៀបរវាងសិស្សប្រុស និង សិស្សស្រី បានបង្ហាញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី របស់សិស្សស្រីមានកម្រិតខ្ពស់ជាង សិស្សប្រុស ពោលគឺសិស្សស្រី មានកម្រិតខ្ពស់៣.៨១ (M=3.81) ហើយសិស្សប្រុសកម្រិតខ្ពស់ ៣.៧១ (M=3.71) ។

៤. តាមលទ្ធផលក្នុងការប្រៀបធៀបតាមកត្តានីមួយៗ បានបង្ហាញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី គឺ១) កត្តាសិស្ស ២) កត្តាគ្រួសារ និង ៣) កត្តាសាលារៀន មានភាពដូចគ្នា។ ចំណែកឯកត្តាសង្គមមានភាពខុសគ្នា។

៥. លទ្ធផលនៃការប្រៀបធៀបតាមថ្នាក់គឺ មានភាពខុសគ្នា រវាងថ្នាក់ទី៨នឹងថ្នាក់ទី៩ គឺតម្លៃខុសគ្នា (M.d=0.34) ចំពោះកត្តាគ្រួសារ គឺមានភាពខុសគ្នារវាង ពីរកម្រិតថ្នាក់ គឺ រវាងថ្នាក់ទី៧នឹងថ្នាក់ទី៨ ( M.d=0.54) និងរវាងថ្នាក់ទី៨នឹងថ្នាក់ទី៩ (M.d=0.49) ។ ចំពោះថ្នាក់ផ្សេងទៀតមិនមានភាពខុសគ្នានោះទេ។

# *Abstract*

Education is one of the most important aspects of human resource development and is the backbone of the national economic development. So quality of education is the most important factors. The quality of education depends on three main factors: 1)The quality of the professors or teachers must have technical knowledge in technical pedagogies related to education, foreign languages, ICT (information communication technology), has a good conscience and a good personality. 2) Curriculum quality the generalizability analysis should focus on the atmosphere around, the student population, students trends, reactions, and comparing the studies of regions and universe. 3) Physical material quality continues to improve and modernize textbooks as well continuing to improve the quality of library centers, library materials, tools and technology for educational, research and experimental work.

This study research to find out:

(1) The factors of students' quality academic performance in New Generation School.

(2) The same and differences between the factors of students' quality academic performance in New Generation School by devided into Gender and grades.

This study research is depend on the theories and the related documents, especially the Ministry of Education Youth and Sports and others reseachers. The collected results from 300 students: Male: 154 and Female: 146 in grade7, grade8 and grade9 of New Generation School. This reseach is used the quantitative method by focus on two questions: (1) What are the factors of students' academic performance inNew Generation School. (2) What are the same and differences between the factors of students' academic performance in New Generation School by devided into Gender and grades.

As the results, the factors of students' academic performance in New Generation School are:

(1) The three general results are: (1) The diligent of students in studying, a high average (M=4.13). (2) Teachers must take the exam to teach in New Generation School, a high average (M=4.06). (3) Teachers and students have computers, tablets, and LCD for teaching and learning, a high average (M=4.03).

(2) The focus on factors are:1/ School factor, a high average (M=3.76). 2/ Social factor, a medium average (M=3.42). 3/ Students factor, a medium average (M=2.59) and 4. Family factor, a medium average (M=2.49).

(3) The results of comparing between Male and female shown that, the factors of students' academic performance for Female is higher average than Male. It means that Female have a high average (M=3.81) and a high average of Male (M=3.71).

(4) As the result of comparing between the factors shown that, the three factors are the same such as: 1/ Students factor. 2/ Family factor. And 3/ school factor. And the others one is different.

(5) The comparing between grade shown that, there is a difference between Grade8 and Grade9 (M.d=0.34). For family factor, there are two differences between grade7 with grade8 (M.d=0.54) and grade8 with grade9 (M.d=0.49) and the others aren’t

# មាតិកា

សេចក្តីប្រកាសអះអាងរបស់បេក្ខជន ..... ii

សេចក្តីថ្លែងអំណរគុណ ..... iii

*មូលន័យសង្ខេប* ..... iv

*Abstract* ..... vi

**ជំពូកទី១៖** ..... ២

**សេចក្តីផ្តើម** ..... ២

១.១ លំនាំនៃការស្រាវជ្រាវ ..... ២

១.២ បញ្ហានៃការស្រាវជ្រាវ ..... ៣

១.៣- គោលបំណងនៃការស្រាវជ្រាវ ..... ៤

១.៤- សំណួរស្រាវជ្រាវ ..... ៤

១.៥- សារៈសំខាន់នៃការស្រាវជ្រាវ ..... ៤

១.៦- ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ..... ៤

១.៧- រចនាសម្ព័ន្ធស្រាវជ្រាវ ..... ៤

**ជំពូកទី២៖** ..... ៦

**រំលឹកទ្រឹស្តី** ..... ៦

២.១. និយមន័យ(ពាក្យគន្លឹះ) ..... ៦

២.២ ប្រព័ន្ធអប់រំនៅកម្ពុជា ..... ៧

២.២.១ ការអប់រំកុមារតូច ..... ៧

២.២.២ ការអប់រំថ្នាក់បឋមសិក្សា ..... ៧

២.២.៣ ការអប់រំចំណេះទូទៅ ..... ៨

២.២.៤ ការអប់រំថ្នាក់ឧត្តមសិក្សា ..... ៨

២.២.៥ ការអប់រំបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន ..... ៩

២.២.៦ ការអប់រំក្រៅប្រព័ន្ធ ...................................................................................... ១២

២.៣ ចក្ខុវិស័យ និងបេសកកម្ម របស់ក្រសួងអប់រំ យុវជន និងកីឡា (អយក) ............................ ១៣

២.៤.យុទ្ធសាស្រ្តកំណែទម្រង់វិស័យអប់រំ ........................................................................១៤

២.៤.១ យុទ្ធសាស្រ្តកំណែទម្រង់ការគ្រប់គ្រងអប់រំ ............................................................១៤

២.៤.២យុទ្ធសាស្រ្តកំណែទម្រង់ឧត្តមសិក្សា............................................................................១៤

២.៤.៣ យុទ្ធសាស្រ្តកំណែទម្រង់ការអភិវឌ្ឍយុវជន.....................................................................១៥

២.២.៤.យុទ្ធសាស្រ្តកំណែទម្រង់ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា.......................................១៥

២.៥.គោលនយោបាយលើកកម្ពស់វិស័យអប់រំ ដែលជាវិស័យអាទិភាព .....................................១៥

២.៥.១ គោលនយោបាយ ធនធានមនុស្សក្នុងវិស័យអប់រំ៖ ......................................................១៥

២.៥.២ គោលនយោបាយ ស្តីពីគ្រូបង្រៀន..................................................................................១៦

២.៥.៣ យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ នីតិកាលទី៥ របស់រាជរដ្ឋាភិបាលកម្ពុជា............១៦

២.៥.៤ យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ នីតិកាលទី៦ របស់រាជរដ្ឋាភិបាលកម្ពុជា............១៦

២.៥.៥ គោលនយោបាយអប់រំឆ្នាំ២០០៩-២០១៣..................................................................១៦

២.៥.៦ គោលនយោបាយអប់រំឆ្នាំ ២០១៤-២០១៨ ................................................................ ១៧

២.៦.គោលនយោបាយសាលារៀនជំនាន់ថ្មីៈ ........................................................................១៨

២.៧ អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា(KAPE) ......................................................១៩

តារាងទី១៖ ការចំណាយលម្អិត និងប្រភពចំណូលសំខាន់ៗរបស់សាលា ...................................... ២០

២.៨ សាលរៀនជំនាន់ថ្មី (អនុវិទ្យាល័យគោកព្រីង) ............................................................... ២០

២.៩ គោលការណ៍នៃការជ្រើសរើសគ្រូនៃសាលារៀនជំនាន់ថ្មី .................................................. ២១

២.៩.១ លក្ខណៈសម្បត្តិ ...................................................................................................... ២១

២.៩.២ លក្ខន្តិកៈ .............................................................................................................. ២១

២.៩.៣ ឱកាស និងអត្ថប្រយោជន៍.........................................................................................២២

២.១០ ទ្រឹស្តីពាក់ព័ន្ធ..........................................................................................................២២

២.១០.១ ការសិក្សាស្រាវជ្រាវរបស់លោក NCHUNGO និងលោក JOSEPHAT......................២២

២.១០.២ ការសិក្សារបស់លោក JAMILLAH.H. MAGANGA.............................................២៣

២.១០.៣ ការសិក្សាស្រាវជ្រាវរបស់ M.S.Farooq, A.H.Chaudhry, M.Shafiq និងG.Berhanu.២៣

**ជំពូកទី៣៖**.............................................................................................. ២៥

**វិធីសាស្ត្រស្រាវជ្រាវ**.................................................................................... ២៥

៣.១ ប្រជាជន និងភាគសំណាក.......................................................................... ២៥

៣.១.១ ប្រជាជន.............................................................................................. ២៥

៣.១.២ ភាគសំណាក.......................................................................................... ២៦

តារាងទី២៖ ស្ថិតិ សិស្ស ថ្នាក់ នៃអនុវិទ្យាល័យគោកព្រីង.......................................... ២៦

៣.២ ឧបករណ៍នៃការស្រាវជ្រាវ .......................................................................... ២៦

៣.៣ ដំណើរការនៃការប្រមូលទិន្នន័យ .................................................................២៧

៣.៤ ការវិភាគទិន្នន័យ......................................................................................... ២៨

៣.៥ ក្រមសីលធម៌នៃការស្រាវជ្រាវ ........................................................................ ២៩

**ជំពូកទី៤៖** .............................................................................................. ៣១

**លទ្ធផលស្រាវជ្រាវ និងការពិភាក្សា** ............................................................... ៣១

៤.១ លទ្ធផលនៃការស្រាវជ្រាវសំណួរទី១៖ តើអ្វីខ្លះដែលជាកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី? ........................................................................ ៣១

៤.២ លទ្ធផលនៃការស្រាវជ្រាវសំណួរទី២៖ ) តើមានភាពខុសគ្នា និងដូចគ្នាអ្វីខ្លះ រវាងកត្តាដែលជះឥទ្ធិពលដល់គុណភាពការសិក្សារបស់សិស្សសាលាជំនាន់ថ្មីតាមកម្រិតថ្នាក់ និងភេទរបស់សិស្ស? ..........៤៦

**ជំពូកទី៥៖** ..............................................................................................៥០

**សេចក្តីសន្និដ្ឋាន និងសំណូមពរ** .....................................................................៥១

៥.១ សេចក្តីសង្ខេបលទ្ធផលនៃការស្រាវជ្រាវ.........................................................៥១

៥.២-ការពិភាក្សាការស្រាវជ្រាវ.......................................................................... ៥៣

៥.៣ សំណូមពរ.................................................................................................. ៥៣

៥.៣.១. សំណូមពរសម្រាប់ការអនុវត្ត..................................................................................... ៥៣
៥.៣.២. សំណូមពរសម្រាប់ការស្រាវជ្រាវបន្ត ....................................................................................៥៤
៥.៤ សេចក្តីសន្និដ្ឋាន ................................................................................................................៥៥
**ឯកសារយោង** ........................................................................................................................ ៥៧
**ឧបសម្ព័ន្ធ**.................................................................................................................................៥៩

# បញ្ជីតារាង

**តារាងទី១៖** ការចំណាយលម្អិត និងប្រភពចំណូលសំខាន់ៗរបស់សាលា....................................២៣

**តារាងទី២៖** ស្ថិតិ សិស្ស ថ្នាក់នៃអនុវិទ្យាល័យគោកព្រីង..........................................................២៩

**តារាងទី៣៖** មធ្យម គម្លាតស្តង់ដា អត្ថន័យ និង លំដាប់កម្រិតនៃកត្តាដែលជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី (N=៣០០)។..........................................................៣៨

**តារាងទី៤៖** មធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់កម្រិតនៃការយល់ដឹងពីកត្តាដែលជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សនៅសាលារៀនជំនាន់ថ្មី ចំនួន៣០០នាក់ (N=300)។................. ៤២

**តារាងទី៦៖** មធ្យម គម្លាតស្តង់ដានៃកត្តាដែលជះឥទ្ធិលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី (អនុវិទ្យាល័យគោកព្រីង) ចំនួន ៣០០ នាក់ (N=300) ដោយបែងចែកទៅតាមភេទនីមួយៗ ..៤៥

**តារាងទី៧៖** មធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់កម្រិតនៃកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី ដែលមានចំនួន ៣០០ នាក់ (N=300)........................................៤៨

**តារាងទី៨៖** មធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់កម្រិតនៃកត្តាជះឥទ្ធិពលនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី តាមភេទ ទៅលើកត្តានីមួយៗ។..............................................................៥១

**តារាងទី៩៖** មធ្យម កម្រិតនៃកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មីដោយបែងចែកតាមកម្រិតថ្នាក់របស់សិស្ស។............................................................................. ៥២

**៤.២ លទ្ធផលនៃការស្រាវជ្រាវសំណួរទី២៖** តើមានភាពខុសគ្នា និងដូចគ្នាអ្វីខ្លះ រវាងកត្តាដែលជះឥទ្ធិពលដល់គុណភាពការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មីតាមកម្រិតថ្នាក់ និងភេទរបស់សិស្ស?.......... ៥៣

**តារាងទី ១០៖** ការប្រៀបធៀបភាពខុសគ្នារបស់ កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី ទៅលើកត្តាសិស្សដោយបែងចែកតាមថ្នាក់នីមួយៗ....................................... ៥៣

**តារាងទី ១១៖** ការប្រៀបធៀបភាពខុសគ្នារបស់ កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី ដោយផ្តោតទៅលើកត្តាគ្រួសារ ដោយបែងចែកទៅតាមកម្រិតថ្នាក់នីមួយៗ ........៥៤

**តារាងទី១២៖** ភាពដូចគ្នា និងភាពខុសគ្នា រវាងកត្តាដែលបានជះឥទ្ធិពលដល់គុណភានៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី របស់សិស្សប្រុស និងសិស្សស្រី ដោយចាត់តាមផ្នែកនីមួយៗ ដែលមានសិស្សចំនួន ៣០០ នាក់ (N=300)...............................................................................................៥៥

**តារាងទី១៣៖** ភាពខុសគ្នា រវាងកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី ដោយចាត់តាមកត្តានីមួយៗ ដែលមានសិស្សចំនួន ៣០០ នាក់ (N=300) ។..................................៥៥

# <u>ឧបសម្ព័ន្ធ</u>

**ឧបសម្ព័ន្ធ១៖** លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា...............................................៦០

**ឧបសម្ព័ន្ធ២៖** លិខិតឧទ្ទេសនាមរបស់វិទ្យាស្ថានជាតិអប់រំ ...........................................................៦១

**ឧបសម្ព័ន្ធ៣៖** គណៈកម្មការការពារនិក្ខេបបទ ........................................................................... ៦៣

**ឧបសម្ព័ន្ធ៤៖** គណៈកម្មការមេប្រយោគ ..................................................................................៦៥

**ឧបសម្ព័ន្ធ៥៖** គណៈកម្មការកណ្ដាល ......................................................................................៦៦

**ឧបសម្ព័ន្ធ៦៖** កំណាត់បង្ហាញរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង ................................ ៦៧

**ឧបសម្ព័ន្ធ៧៖** កម្រងសំណួរ ..................................................................................................៦៨

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំនៃការស្រាវជ្រាវ

ការអប់រំបានដើរតួយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស និងជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ការអប់រំតាមគ្រប់រូបភាពទាំងក្នុងប្រព័ន្ធ ក្រៅប្រព័ន្ធ និងមិនផ្លូវការ ជាមធ្យោបាយស័ក្តិសិទ្ធិក្នុងការធានាឲ្យការសិក្សាមាន គុណភាពប្រកបដោយ សមធម៌ បរិយាប័ន្ន និងលើកកម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ការសិក្សាពេញមួយជីវិត ជាការអប់រំសំដៅ ធានាសិទ្ធិសេរីភាព និងសុភមង្គលបុគ្គល គ្រួសារ និងសង្គមជាតិ ដើម្បីឆ្លើយតបទៅនឹងទីផ្សារការងារក្នុងបរិបទថ្មី។ ការអប់រំ ដើម្បីអភិវឌ្ឍវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងគុណសម្បទា ឲ្យក្លាយជា ពលរដ្ឋល្អ និងចេះរួមរស់ជាមួយគ្នា ប្រកបដោយភាពសុខដុមនៅក្នុងសង្គម។ ស្ថិតក្នុងបរិការណ៍នៃសកលភាវូបនីយកម្មសតវត្សន៍ទី២១ និងការប្រកួតប្រជែងទាំងក្នុងតំបន់ និងសកលលោកផ្នែក សេដ្ឋកិច្ច នយោបាយ បរិស្ថាន វប្បធម៌ ឧស្សាហកម្ម និងបច្ចេកវិទ្យា បុគ្គលគ្រប់រូបត្រូវទទួលបានការបណ្តុះបណ្តាលវប្បធម៌សិក្សាពេញមួយជីវិត ដើម្បីប្រែក្លាយប្រទេសកម្ពុជា ឲ្យក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងក្លាយជាប្រទេសដែលមានចំណូលកម្រិតខ្ពស់ និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០ ***(គោលនយោបាយជាតិរបស់រាជរដ្ឋាភិបាល ស្តីពី ការសិក្សាពេញមួយជីវិត ខែកក្កដា ឆ្នាំ២០១៩)*** ។

ក្នុងនោះ រាជរដ្ឋាភិបាលបានធ្វើកំណែទម្រង់ចំណុចសំខាន់ បីគឺ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់រដ្ឋបាលមុខងារសាធារណៈ កំណែទម្រងការអនុវត្តកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីឆ្លើយតប ទៅនឹងមហិច្ឆិតារបស់ក្រសួងអប់រំ ដែលជាវិស័យអាទិភាពក្នុងចំណោមវិស័យទាំងឡាយ ក្នុងការពង្រឹងគុណភាពអប់រំ និងគុណភាពនៃការសិក្សារបស់សិស្សអោយកាន់តែប្រសើរឡើង និងអាចប្រកួតប្រជែងទីផ្សារការងារក្នុងតំបន់ និងថ្នាក់អន្តរជាតិ។ ជាងនេះទៅទៀតយុទ្ធសាស្រ្តចំបងក្នុងយុទ្ធសាស្រ្តចតុកោណ គឺការអភិវឌ្ឍវិស័យអប់រំ ពោលគឺការកសាង និងអភិវឌ្ឍធនធានមនុស្ស ការពង្រឹងគុណភាពអប់រំយកចិត្តទុកដាក់លើការអប់រំជាមូលដ្ឋាន ក្រោយកម្រិតមូលដ្ឋាន និងឧត្តមសិក្សា និងពង្រឹងភាពជាដៃគូរវាងផ្នែកឯកជន និងផ្នែកសាធារណៈក្នុងការកៀរគរ និងប្រើប្រាស់ធនធានមនុស្សដែលធ្វើឲ្យប្រទេសកម្ពុជាក្លាយជា ប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសអភិវឌ្ឍនៅឆ្នាំ២០៥០ ។

ចំណែកឯក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតនូវគោលនយោបាយដោយធានាការអប់រំប្រកបដោយគុណភាព បរិយាប័ន្ន សមធម៌ និងបង្កើននូវកាលានុវត្តភាពសិក្សាពេញមួយជីវិតសម្រាប់ជនគ្រប់រូប និងធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់***( ក្រសួងអប់រំ យុ***

*វជន និងកីឡា ឆ្នាំ២០១៩)* ។ ក្នុងនោះក្រសួងអប់រំបានបង្កើតនូវចក្ខុវិស័យច្បាស់លាស់ពោលគឺ កសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់វិស័យ ដើម្បីកសាងសង្គមកម្ពុជាឲ្យក្លាយជាសង្គមរីកចម្រើនលើផ្នែក ចំណេះដឹង និងចំណេះធ្វើឲ្យស្របទៅនឹងបរិបទទីផ្សារការងារនាពេលបច្ចុប្បន្ន។ ហើយក្រសួងមានបេសកកម្ម ក្នុងការដឹកនាំ និងអភិវឌ្ឍវិស័យអប់រំ ឲ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍ សេដ្ឋកិច្ច សង្គម វប្បធម៌ របស់កម្ពុជា និងការរីកចម្រើនក្នុងតំបន់ និងសកលលោក *(www.moeys.kg.com)*។ លើសពីនេះទៅទៀតក្រសួងបានបង្កើតនូវគោលនយោបាយវិមជ្ឈការ គឺការប្រគល់ការងារ មុខងារនិងការទទួលខុសត្រូវដល់មន្ត្រីអង្គភាពចាត់តាំងនៅថ្នាក់មូលដ្ឋានដែលបានជ្រើសរើសដោយការបោះឆ្នោត និងវិសហមជ្ឈការ ជាការផ្តល់អំណាចឲ្យទៅស្ថាប័នតំណាងរាជរដ្ឋាភិបាលថ្នាក់ក្រោមជាតិ ជាអ្នកធ្វើផែនការអភិវឌ្ឍស្ថាប័ន និងសាលារៀនដោយផ្ទាល់។ ពោលគឺ ធ្វើឲ្យប្រសើរឡើងនូវគុណភាពនៃការផ្តល់សេវាអប់រំឲ្យប្រជាពលរដ្ឋស្របតាមរដ្ឋធម្មនុញ្ញនៃច្បាប់ស្តីពី ការអប់រំ ព្រមទាំងឆ្លើយតបតាមការកំណត់នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ និងមានគោលបំណង ពង្រឹងស្វ័យភាព និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសិក្សាសាធារណៈ ដើម្បីធ្វើឲ្យប្រសើរឡើងនូវ គុណភាព តម្លាភាព សមធម៌ និងគណនេយ្យភាពនៃការផ្តល់សេវាអប់រំជូនប្រជាពលរដ្ឋ *(គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ខែកញ្ញា ឆ្នាំ២០១៦)*។

ជាការពិតណាស់ គុណភាពនៃការសិក្សារបស់សិស្ស គឺត្រូវការ ការចូលរួមពីគ្រប់មជ្ឈដ្ឋាន រួមមាន រាជរដ្ឋាភិបាល ក្រសួងស្ថាប័ន អង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍនានា និងថ្នាក់ក្រោមជាតិ រួមមានៈ មន្ទីរអប់រំ ខេត្ត ការិយាល័យអប់រំស្រុក និងថ្នាក់សាលារៀនព្រមទាំងការចូលរួមពីសហគមន៍មូលដ្ឋាន ក្នុងការជម្រុញ លើកទឹកចិត្ត ដល់អ្នកសិក្សាគ្រប់រូបមានឱកាសក្នុងការសិក្សារៀនសូត្រ ដើម្បីទទួលបាននូវចំណេះដឹង ជំនាញ មានក្រមសីលធម៌ល្អ សុជីវធម៌ ក្នុងការរួមរស់ជាមួយគ្នា ប្រកបដោយសេចក្តីសុខ សុវត្ថិភាព និងធ្វើឲ្យប្រទេសកម្ពុជាក្លាយជាប្រទេសអភិវឌ្ឍពេញលេញនៅឆ្នាំ២០៥០។

## ១.២ បញ្ហានៃការស្រាវជ្រាវ

ដើម្បីឲ្យការសិក្សាទទួលបាននូវគុណភាព និងប្រសិទ្ធិភាពចាំបាច់ត្រូវមានការចូលរួមពីមជ្ឈដ្ឋានជាច្រើន ហើយកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សាសំខាន់បំផុត គឺកត្តាខ្លួនឯង គ្រួសារ សាលារៀន និងសហគមន៍ ព្រមទាំងអ្នកពាក់ព័ន្ធផ្សេងៗទៀតដែលជាកត្តាចាំបាច់មិនអាចខ្វះបាន។ ជាក់ស្តែងក្រសួងអប់រំ យុវជន និងកីឡាបានធ្វើកំណែទម្រង់លើការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (២០១៤-២០១៦) បានបង្ហាញឲ្យឃើញថា ការប្រលងមានភាព ត្រឹមត្រូវ យុត្តិធម៌ តម្លាភាព និងលទ្ធផល

ទទួលយកបាន ទាំងនេះក៏ព្រោះតែមានការចូលរួមពី សិស្សានុសិស្ស យុវជន មាតាបិតាអាណាព្យាបាល និងអាជ្ញាធរគ្រប់ជាន់ថ្នាក់ ទើបដំណើរការបានដោយរលូន ប្រកបដោយគុណភាព និងប្រសិទ្ធិភាពខ្ពស់។

សាលារៀនមួយរីកចម្រើនទៅបាន អាស្រ័យដោយអ្នកគ្រប់គ្រងល្អ លោកគ្រូ អ្នកគ្រូមានចំណេះដឹងជំនាញច្បាស់លាស់ មានទំនាក់ទំនងល្អរវាងសាលារៀនជាមួយមាតាបិតា អាណាព្យាបាលសិស្ស សាលារៀនជាមួយសហគមន៍ ទើបការសិក្សារបស់សិស្សទទួលបានលទ្ធផលល្អ។ អាស្រ័យហេតុនេះហើយ ទើបតម្រូវឲ្យមានការសិក្សាស្រាវជ្រាវជាក់លាក់មួយ ស្តីពីកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សនៅសាលារៀនជំនាន់ថ្មី ដើម្បីស្វែងយល់ឲ្យមានភាពស៊ីជម្រៅ និងប្រាកដនិយម។

## ១.៣- គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងសិក្សាពី៖

១. កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី។

២. ប្រៀបធៀបកត្តាជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស តាមភេទ និងកម្រិតថ្នាក់របស់សិស្ស។

## ១.៤- សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើ ការស្រាវជ្រាវនេះនឹងឆ្លើយនូវសំណួរចំនួនពីរដូចខាងក្រោម៖

(១) តើមានកត្តាអ្វីខ្លះ ដែលជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី?

(២) តើមានភាពខុសគ្នា និងដូចគ្នាអ្វីខ្លះ រវាងកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មីតាមកម្រិតថ្នាក់ និងភេទរបស់សិស្ស?

## ១.៥- សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានសារៈសំខាន់ណាស់ ព្រោះវាបានជួយក្នុងការឆ្លុះបញ្ចាំងឲ្យឃើញនូវចំណុចខ្លាំង និងចំណុចខ្សោយនៃកិច្ចដំណើរការសាលារៀនជំនាន់ថ្មី ព្រមទាំងបទពិសោធន៍ល្អៗ សម្រាប់ដំណើរការសាលារៀនផ្សេងៗទៀត ដែលគ្រោងនឹងដាក់បញ្ចូលជាសាលារៀនជំនាន់ថ្មី។ ម្យ៉ាងវិញទៀត តាមរយៈនៃការសិក្សាស្រាវជ្រាវនេះ បានចូលរួមចំណែកក្នុងការកៀរគរការចូលរួមពីគ្រប់មជ្ឈដ្ឋានក្នុងការជួយជ្រោមជ្រែងដល់កិច្ចដំណើរការសាលា ក៏ដូចជាការចូលរួមកសាង និងអភិវឌ្ឍសាលារៀន ដើម្បីឲ្យមានកម្រិតស្តង់ដា ជាគ្រឹះនៃការជំរុញគុណភាពនៃការសិក្សារបស់សិស្សនាពេលអនាគត់។

## ១.៦- ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ គឺផ្តោតលើកត្តាទាំងឡាយដែលជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្ស ព្រមទាំងកិច្ចដំណើរការសាលារៀនជំនាន់ថ្មី (អនុវិទ្យាល័យគោកព្រីង) ក្នុងឃុំគោកព្រីង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ អាស្រ័យហេតុនេះ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសសមាសភាពដែលត្រូវផ្តល់ព័ត៌មានចំនួន ៣00 នាក់ដែលជាសិស្សរៀន ថ្នាក់ទី៧ ថ្នាក់ទី៨ និងថ្នាក់ទី៩។

## ១.៧- រចនាសម្ព័ន្ធស្រាវជ្រាវ

និក្ខេបបទនេះចែកជា ៥ជំពូកៈ

**ជំពូកទី១៖ សេចក្តីផ្តើម** ដែលមាន ៧ផ្នែក រួមមានៈ សាវតា បញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី២៖ រំលឹកទ្រឹស្តី** ជាការលើកយកមកបង្ហាញពីកត្តាទាំងឡាយដែលជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សនៅសាលាជំនាន់ថ្មី ផលប្រយោជន៍ និងសារៈសំខាន់ ព្រមទាំងទ្រឹស្តីដែលពាក់ព័ន្ធរួមទាំងក្នុងប្រទេស ថ្នាក់តំបន់ និងសកលលោកឲ្យបានទូលំទូលាយ និងច្បាស់លាស់។

**ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ** រៀបរាប់ពីវិធីសាស្ត្រនានាដែលយកមកប្រើដើម្បីទទួលបានទិន្នន័យកមកវិភាគ ព្រមទាំងវិធីវិភាគទិន្នន័យ ដែលត្រូវបានយកមកប្រើប្រាស់ក្នុងការស្រាវជ្រាវនេះ។

**ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា** បកស្រាយលើទិន្នន័យដែលបានមកពីកម្រងសំណួរ ព្រមទាំងទិន្នន័យដែលប្រមូលបាន។

**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ** បន្ទាប់ពីបានរកឃើញនូវកត្តាទាំងឡាយដែលបានជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សនៅសាលារៀនជំនាន់ថ្មី រួចមកអ្នកស្រាវជ្រាវនឹងធ្វើសេចក្តីសន្និដ្ឋានលើលទ្ធផល ព្រមទាំងសំណូមពរដល់អ្នកពាក់ព័ន្ធដើម្បីចូលរួម ផ្តល់យោបល់ កែលម្អ ស្ថាបនា និងកៀរគរអង្គការនានាឲ្យជួយអភិវឌ្ឍសាលារៀន ដើម្បីពង្រឹង និងជំរុញគុណភាពនៃការសិក្សារបស់សិស្ស។

# ជំពូកទី២

# រំលឹកទ្រឹស្តី

# ជំពូកទី២
# រំលឹកទ្រឹស្តី

## ២.១. និយមន័យ(ពាក្យគន្លឹះ)

*គុណភាពនៃការសិក្សា* គឺសំដៅលើការសិក្សាដែលប្រកបដោយលទ្ធផល និងប្រសិទ្ធិភាពខ្ពស់ ពោលគឺអ្នកសិក្សាទទួលបាននូវចំណេះដឹង ចំណេះធ្វើ ឥរិយាបទ និងចេះរួមរស់ជាមួយសមូហភាព ហើយអ្វីដែលអ្នកសិក្សាបានចេះ គឺជាចំណេះដែលមានភាពច្បាស់លាស់ ជំនាញ សមត្ថភាពដែលសមស្របទៅនឹងតាមទីផ្សារការងារ ក្នុងតំបន់ និងសកលលោក។ *សាលារៀនជំនាន់ថ្មី* គឺជាសាលាដែលផ្តោតលើគោលការណ៍ អភិបាលកិច្ចដ៏មានប្រសិទ្ធិភាព ដែលត្រូវបានប្រើប្រាស់នៅក្នុងវិស័យឯកជន ទៅដល់ប្រព័ន្ធសាលារៀនសាធារណៈ ដោយប្រើប្រាស់គំរូ ការគ្រប់គ្រងបែបជាដៃគូរវាងគ្រឹះស្ថានសាធារណៈ និងឯកជន ដើម្បីរក្សានិរន្តរភាព បរិស្ថានសាលាកុមារមេត្រី ដែលមានគុណភាពខ្ពស់សម្រាប់សិស្សានុសិស្ស នៅតាមជនបទ និងជុំវិញរាជធានីភ្នំពេញ។ ជារួម គោលដៅរយៈពេលវែង គឺដើម្បីបង្កើតនូវគំរូអភិវឌ្ឍវិស័យអប់រំ ដែលនាំទៅរកគំនិតថ្មីសម្រាប់សាលារៀនសាធារណៈនៅកម្ពុជា ក្នុងការបង្ហាញពី ការងារអភិបាលកិច្ចល្អ ស្តង់ដាវិជ្ជាជីវៈ និងគុណភាពខ្ពស់ *(ក្រសួងអប់រំ តុលា ២០១៥)*។ *សាលារៀនជំនាន់ថ្មី* គឺជាការព្យាយាមបង្កើតគំរូអភិវឌ្ឍថ្មី នៅក្នុងប្រព័ន្ធអប់រំសាធារណៈ ដែលដឹកនាំទៅដល់ការបង្កើតសាលារៀនសាធារណៈស្វយ័ត ដែលទទួលបានការវិនិយោគខ្ពស់ផ្សារភ្ជាប់ទៅនឹងស្តង់ដាថ្មីមានគណនេយ្យភាព និងអភិបាលកិច្ចល្អព្រមទាំងស្តង់ដាវិជ្ជាជីវៈ សម្រាប់ការសិក្សានៅក្នុងសតវត្សន៍ទី២១ *(ក្រសួងអប់រំ ខែកញ្ញា ២០១៦)*។

## ២.២ ប្រព័ន្ធអប់រំនៅកម្ពុជា

ប្រព័ន្ធអប់រំនៅកម្ពុជាបានចែកចេញជា ប្រាំមួយប្រភេទ គឺ ការអប់រំកុមារតូច ការអប់រំថ្នាក់បឋមសិក្សា ការអប់រំចំណេះទូទៅ ការអប់រំថ្នាក់ឧត្តមសិក្សា ការអប់រំបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន និងការអប់រំក្រៅប្រព័ន្ធ។

### ២.២.១ *ការអប់រំកុមារតូច*

វឌ្ឍភាពបានកើនឡើងដោយសារការពង្រីកចំនួនសាលាមត្តេយ្យសិក្សាសហគមន៍ ថ្នាក់មត្តេយ្យក្នុងសាលារៀនបឋមសិក្សា មត្តេយ្យឯកជន និងកម្មវិធីអប់រំកុមារតូចតាមផ្ទះ និងតាមខ្នងផ្ទះ។ គ្រូមត្តេយ្យសិក្សាសហគមន៍ និងក្រុមម្តាយបង្គោលនៃកម្មវិធីអប់រំកុមារតូចតាមផ្ទះ និងតាមខ្នងផ្ទះបានទទួលការបំប៉នសម្ភារៀន និងបង្រៀន និងការអភិវឌ្ឍសម្ភាររូបវន្តមត្តេយ្យសិក្សាសហគមន៍ត្រូវបានយកចិត្តទុកដាក់។ អន្តរាគមន៍លក្ខណៈជាគោលនយោបាយឆ្នាំ២០០៩-២០១៣ គឺជាមូកដ្ឋានគ្រឹះសម្រាប់ការឈានទៅបង្កើតគុណភាពនៃសេវាអប់រំកុមារតូចនៅឆ្នាំ២០១៨ ពោលគឺការរៀបចំគោលនយោបាយជាតិ និងផែនការសកម្មភាពជាតិ ស្តីពីការគាំពារ និងអភិវឌ្ឍកុមារតូច។ បង្កើតគណៈកម្មការជាតិគាំពារ និងអភិវឌ្ឍកុមារតូ

ច។ ប្រកាសស្តីពីការគ្រប់គ្រងសាលាមត្តេយ្យឯកជន និងប្រកាសស្តីពីការទទួលស្គាល់គ្រូបង្គោលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ គោលការណ៍ប្រតិបត្តិសម្រាប់កម្មវិធីអប់រំមាតាបិតា រួមទាំងស្ត្រីមានផ្ទៃពោះ និងមាតាបិតាដែលមានកុមារអាយុក្រោម ២ឆ្នាំ និងគោលការណ៍ប្រតិបត្តិសម្រាប់សាលាមត្តេយ្យធនធាន។

## ២.២.២ ការអប់រំថ្នាក់បឋមសិក្សា

កុមារតូចបានចូលរៀននៅបឋមសិក្សាកាន់តែច្រើន ជាក់ស្តែងអត្រាពិតនៃការសិក្សាបានកើនឡើងពី ៩៤,៨ ភាគរយទៅដល់ ៩៧ភាគរយនិងគ្មានគំលាតយ៉េនឌ័រ។ អត្រាត្រួតថ្នាក់ និងសិស្សបោះបង់ការសិក្សាបានថយចុះ។ សាលាបឋមសិក្សាមិនគ្រប់កម្រិតត្រូវបានបន្ថែមបន្ទប់រៀនដើម្បីក្លាយជាសាលាគ្រប់កម្រិត។ នៅបឋមសិក្សាមានកម្រិតថ្នាក់ចាប់ពីទី១រហូតដល់ថ្នាក់ទី៦ ដោយគិតពីអាយុ៦ឆ្នាំ រហូតដល់អាយុ ១១ឆ្នាំ។ សម្រាប់មធ្យមសិក្សា ចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩ ដោយគិតពីអាយុ ១២ឆ្នាំ រហូតដល់អាយុ ១៥ឆ្នាំ។ មធ្យមសិក្សាទុតិយភូមិ ចាប់ពីថ្នាក់ទី១០ រហូតដល់ថ្នាក់ទី១២ ដោយគិតចាប់ពីអាយុ ១៥ រហូតដល់អាយុ ១៨ឆ្នាំ។

## ២.២.៣ ការអប់រំចំណេះទូទៅ

ការចូលរៀន និងគុណភាពនៅកម្រិតនេះមានការប្រែប្រួលតិចតួច។ អត្រាត្រួតថ្នាក់បានថយចុះតិចតួច ប៉ុន្តែអត្រាបោះបង់ការសិក្សាមិនមានការប្រែប្រួល។ការប្រឡងថ្នាក់ចាតិនៅថ្នាក់ទី៩ និងទ១២ ត្រូវបានអនុវត្តជាទៀងទាត់។ ចំនួនអនុវិទ្យាល័យ និងវិទ្យាល័យបានកើនឡើង។ សាលាមធ្យមសិក្សាបឋមភូមិ ៥០ ភាគរយបានអភិវឌ្ឍន៍ទៅជាសាលាមធ្យមសិក្សាទុតិយភូមិ។ សាលមធ្យមសិក្សាបឋមភូមិចំនួន ១៤១ ក្នុងខេត្ត ៨ មានបន្ទប់កុំព្យូទ័រ។ គោលនយោបាយសាលាកុមារមេត្រីបានអនុវត្តនៅសាលាចំនួន ៨២៣ (៥០,៧៤ ភាគរយនៃសាលាមធ្យមសិក្សាបឋមភូមិ)។ ប្រព័ន្ធនៃការបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀនជាពិសេសគ្រូបង្រៀនកម្រិតមូលដ្ឋាននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងវិទ្យាស្ថានជាតិអប់រំត្រូវបានពង្រីក។ គុណភាពរបស់សិស្សថ្នាក់ទី១២ ត្រូវបានលើកកម្ពស់ និងផ្តល់នូវចំណេះដឹងដែលពាក់ព័ន្ធដ៏ទៃទៀត សម្រាប់ការអប់រំបច្ចេកទេស វិជ្ជាជីវៈ និងឧត្តមសិក្សា។ វិធីសាស្ត្រក្នុងការបង្រៀន ត្រូវបានអនុវត្តតាមរៀប ជាមេរៀន ចម្លងតាម ដកស្រង់ និងការចងចាំ។ វិធីសាស្ត្រទាំងនេះត្រូវបានបញ្ចូលនូវការគិត និងជំនាញវិភាគ។ ស្តង់ដាគ្រូបង្រៀន ត្រូវបានត្រួតពិនិត្យតាមដាន វាយតម្លៃ និងអភិវឌ្ឍជាប្រចាំ។

## ២.២.៤ ការអប់រំថ្នាក់ឧត្តមសិក្សា

ក្នុងអំឡុងឆ្នាំ ២០០៩-២០១៣ ការអប់រំនៅឧត្តមសិក្សា មានការរីកចម្រើន ដូចជាការចូលរៀនរបស់និស្សិតកើនឡើងដល់ ២០,៧០០០ នាក់ និងនិស្សិតទទួលបានអាហាររូបករណ៍ មាន ៤២០០ នាក់ ព្រមទាំងការកើនឡើងនូវគ្រឹះស្ថានឧត្តមសិក្សាដែលសម្រេចបានតាមបទដ្ឋាននៃការទទួលស្គាល់។ គណៈកម្មការទទយលស្គាល់គុណភាពអប់រំកម្ពុជាមានសមត្ថភាពខ្ពស់ក្នុងការគ្រប់គ្រង និងដំណើរការប្រព័ន្ធទទួ

ស្គាល់គុណភាព។ វប្បធម៌នៃការស្រាវជ្រាវបានចាប់ផ្តើមផុសឡើងតាមរយៈ ការអនុវត្តកម្មវិធីផ្តល់មូលនិធិស្រាវជ្រាវ និងមានកិច្ចសហប្រតិបត្តិការក្នុង តំបន់រឹងមាំ កិច្ចសហការ និងសកម្មភាពបានអនុវត្តរួមគ្នា។ រាជរដ្ឋាភិបាលបានទទួលស្គាល់ពីសារៈសំខាន់នៃការផ្តល់ឱកាស ក្នុងការសិក្សានៅឧត្តមសិក្សា និងសារៈសំខាន់ក្នុងការធានាគុណភាព និងភាពឆ្លើយតប។ ការធ្វើសមាហរណកម្មអាស៊ាននឹងផ្តល់ជាឱកាសសម្រាប់សហការរវាងស្ថាប័ន ការស្រាវជ្រាវរួមគ្នា និងការកំណត់ស្តង់ដាគុណភាព។

## ២.២.៥ ការអប់រំបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន

### ១. វត្ថុបំណង និងយុត្តិកម្ម

វត្ថុបំណងទីមួយ គឺធានាការផ្តល់គ្រូបង្រៀនគ្រប់កម្រិតសិក្សាប្រកបដោយប្រសិទ្ធ ភាព ដើម្បីឆ្លើយតបទៅនឹងការពង្រីកប្រព័ន្ធអប់រំរួមទាំងការពង្រីក សមត្ថភាពអ្នកគ្រប់គ្រងសាលាគរុកោសល្យ និងអ្នកគ្រប់គ្រងអប់រំ គ្រូឧទ្ទេស នាយកសាលារៀន និងមន្ត្រីអប់រំសំខាន់ៗផ្សេងទៀត ។

វត្ថុបំណងទីពីរគឺកែលម្អគុណភាពនៃការបង្រៀនតាមរយៈការពង្រីកការធ្វើវិក្រឹតការគ្រូបង្រៀន ។

### ២. ការឆ្លើយតបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ

*គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌*

- ធានាសនិទានកម្មបុគ្គលិកអប់រំសម្រាប់តំបន់ដាច់ស្រយាល និងជួបការលំបាក ។

**សកម្មភាពគោលនយោបាយ**

- ផែន ការសកម្មភាពក្នុងការបង្រៀនថ្នាក់គួបសម្រាប់គ្រូនៅតំបន់ព្រំដែន តំបន់ដាច់ស្រយាល និងឬតំបន់ជនជាតិភាគតិចត្រូវបានរៀបចំជារៀងរាល់ឆ្នាំ។

*គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងប្រសិទ្ធភាពសេវាអប់រំ*

- លើកកម្ពស់ការអភិវឌ្ឍគ្រូបង្រៀនទាំងការបណ្តុះបណ្តាល និងវិក្រឹតការ។

**សកម្មភាពគោលនយោបាយ ៖**

- ផែនការសកម្មភាពសម្រាប់អភិវឌ្ឍសមត្ថភាពត្រូវបានរៀបចំតាមឆ្នាំនីមួយៗ។
- របាយការណ៍ស្តីពីការវិភាគតម្រូវការបំប៉ននិងផែនការ អភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេសត្រូវបានបញ្ចប់នៅ ឆ្នាំ២០១០។
- ផែនការគោលស្តីពី ការអភិវឌ្ឍគ្រូបង្រៀន ត្រូវបានបញ្ចប់នៅឆ្នាំ២០១០។

របាយការណ៍ស្តីពី ការវិភាគតម្រូវការសម្ភារៈរូបវ័ន្តនៅតាមសាលាគរុកោសល្យ ត្រូវបានបញ្ចប់ នៅឆ្នាំ ២០១០។

- ផែនការលើកកម្ពស់សមត្ថភាពគ្រូបង្រៀនមធ្យមសិក្សាដែលសមត្ថភាពនៅមានកម្រិត រៀបចំ បាន នៅឆ្នាំ ២០១១។
- ខ្លឹមសារឯកសារ ICT ក្នុងកម្មវិធីបណ្តុះបណ្តាល គ្រូបង្រៀនត្រូវបានកែលម្អ នៅឆ្នាំ ២០១១។

- ម៉ូឌុលស្ដីពីការយល់ដឹងយេនឌ័រ ត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីបណ្ដុះបណ្ដាលជាផ្លូវការ នៅឆ្នាំ ២០១១។
- កម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀន ត្រូវបានបញ្ចប់ការកែលម្អ នៅឆ្នាំ២០១២។
- ម៉ូឌុលស្ដីពីការអប់រំបញ្ចូលគ្នា ក្នុងកម្មវិធីបណ្ដុះបណ្ដាលត្រូវ បានកែលម្អនៅឆ្នាំ ២០១២។

**៣. សូចនាករ និងចំណុចដៅ**

- គរុសិស្ស -គរុនិស្សិតថ្មីចំនួន ៥០០០នាក់ ក្នុងមួយឆ្នាំត្រូវបានជ្រើសរើសចូលរៀននៅសាលាគរុកោសល្យដែលក្នុង នោះយ៉ាងតិច៤០% មកពីតំបន់ជនបទ តំបន់ជួបការលំបាក តំបន់ដាច់ស្រយាល និងក្រុមជនជាតិភាគតិច។
- គ្រូ បឋមសិក្សាចំនួន ៣០០០នាក់ ត្រូវបានបង្កើនសមត្ថភាពឱ្យក្លាយជាគ្រូបង្រៀនកម្រិតអប់រំមូលដ្ឋានតាមរយៈការបំប៉ននៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង ៦ នៅត្រឹមឆ្នាំសិក្សា ២០១៣-២០១៤។
- អធិការ បឋមសិក្សាចំនួន ៩០នាក់ និងអធិការមធ្យមសិក្សាចំនួន ១២០នាក់ ត្រូវបានជ្រើសរើសតាមរយៈការបណ្ដុះបណ្ដាលនៅវិទ្យាស្ថានជាតិអប់រំ ត្រឹមឆ្នាំសិក្សា ២០១៣-២០១៤។
- គរុសិស្ស -គរុនិស្សិតចំនួន ១,៥០០នាក់ត្រូវបានជ្រើសរើសជារៀងរាល់ឆ្នាំ ពីតំបន់ជួបការលំបាក ហើយពួកគេត្រូវបានចាត់តាំងឲ្យទៅ បម្រើការនៅតំបន់នោះវិញក្រោយពីបញ្ចប់ ការបណ្ដុះបណ្ដាល ។

**៤. សកម្មភាព និងកម្មវិធីចម្បងៗ**

**៤.១. កម្មវិធីចរន្ត (ថវិកាកម្មវិធី និងថវិកាផ្សេងៗទៀត)**

**១- ថវិកាដំណើរការសាលាគរុកោសល្យទាំង ២៥**

- ផ្ដល់ ថវិកាដំណើរការប្រចាំឆ្នាំ ដល់សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិមសាលាគរុកោសល្យ និងវិក្រឹតការរាជធានី-ខេត្តទាំង១៨ មជ្ឈមណ្ឌលគរុកោសល្យ ភូមិភាគទាំង៦ និងមជ្ឈមណ្ឌលធនធានចំនួន៦ សំដៅកែលម្អគុណភាព និងប្រសិទ្ធភាពនៃកម្មវិធីបណ្ដុះបណ្ដាល និងវិក្រឹតការគ្រូបង្រៀន។ អាទិភាពមួយ សម្រាប់សាលាគរុកោសល្យ គឺការបណ្ដុះបណ្ដាលគ្រូបង្រៀនកម្រិតមូលដ្ឋាន ដើម្បីឆ្លើយតបប្រកបដោយភាពទន់ភ្លន់ទៅនឹងការប្រែប្រួលការចូល រៀននៅបណ្ដាឆ្នាំខាងមុខនេះ។

**២- កម្មវិធីអភិវឌ្ឍសមត្ថភាពគ្រប់គ្រងអប់រំ**

- ផ្ដល់ឱ្យនាយកសាលាបឋមសិក្សា និងមធ្យមសិក្សានូវជំនាញនានា ដើម្បីអនុវត្ត ការដឹកនាំឱ្យបានសកម្មនិងទទួលខុសត្រូវក្នុងការអនុវត្តវិធាន ការនានា និងគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាពនិងគុណភាពតាមរយៈកម្មវិធី បំប៉នសមត្ថភាពគ្រប់គ្រងអប់រំ។

**៣- កម្មវិធីបន្តការអភិវឌ្ឍ/វិក្រឹតការគ្រូបង្រៀន**

- បង្កើនសមត្ថភាពបុគ្គលិក នៅសាលាគរុកោសល្យទាំងអស់ រួមមានការបំប៉នគ្រូ ឧទ្ទេស តាមរយៈកម្មវិធីអភិវឌ្ឍបុគ្គលិកនៅសាលាគរុកោសល្យ។
- ផ្តោតការយកចិត្តទុកដាក់ទៅលើការបង្រៀនថ្នាក់គួប ជាពិសេសសម្រាប់ សាលារៀនដែលស្ថិតនៅក្នុងតំបន់ដាច់ស្រយាលនិងសាលារៀនមិន គ្រប់កម្រិត ថ្នាក់។ អាទិភាពត្រូវផ្តល់ឱ្យគ្រូបង្រៀនដែលបច្ចុប្បន្នកំពុងបង្រៀនថ្នាក់គួប។
- បង្កើន សមត្ថភាពគ្រូបឋមសិក្សាឱ្យទៅជាគ្រូបង្រៀនកម្រិតមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងកំណើនសិស្សចូលរៀននៅមធ្យមសិក្សាបឋមភូមិ។
- បំប៉នសមត្ថភាព ស្តីពីការប្រើប្រាស់កម្មវិធីសិក្សា ស្តង់ដាកម្មវិធីសិក្សា និងអប់រំបញ្ចូលគ្នាជូនដល់គ្រូបង្រៀននៅគ្រប់កម្រិតសិក្សា។
- ផ្តល់ការបណ្តុះបណ្តាលបច្ចេកវិទ្យាព័ត៌មានសារគមនាគមន៍ ដល់គ្រូឧទ្ទេស និងគ្រូមធ្យមសិក្សាទាំងអស់។
- បំប៉នសមត្ថភាព ស្តីពីការបញ្ជ្រាបយេនឌ័រជូនដល់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

**៤.២. កម្មវិធីមូលធន**

**ការវិនិយោគ ៖**

- លទ្ធកម្មបំពាក់ឧបករណ៍ ICT នៅសាលាគរុកោសល្យត្រូវបានរៀបចំឡើងនៅឆ្នាំ ២០១១។

**កិច្ចសហប្រតិបត្តិការបច្ចេកទេស ៖**

- ពង្រឹងសមត្ថភាពគ្រប់គ្រងរបស់អ្នកដឹកនាំ នៅគ្រប់សាលាគរុកោសល្យ។
- ពង្រឹងសមត្ថភាពគ្រូឧទ្ទេស នៅសាលាគរុកោសល្យទាំងអស់អំពីវិធីសាស្រ្តបង្រៀន ដូចជា ការសិក្សា ស្រាវជ្រាវមេរៀន និងការសិក្សាតាមបែបរិះរក(Lesson Study and Inquiry Base Learning)។
- បំប៉នគ្រូឧទ្ទេសនៅសាលាគរុកោសល្យ ស្តីពីការអភិវឌ្ឍ និងប្រើប្រាស់សម្ភារឧបទេស។
- បំប៉នគ្រូឧទ្ទេសនៅសាលាគរុកោសល្យ ស្តីពីការប្រើប្រាស់ឧបករណ៍ពិសោធន៍។
- ពង្រឹងសមត្ថភាពមន្ត្រីនាយកដ្ឋានបណ្តុះបណ្តាលនិងរិក្រឹតការ ដើម្បីកំណត់សកម្មភាពជាអាទិភាពសំដៅធ្វើឱ្យការផ្តល់សេវា កាន់តែមានប្រសិទ្ធភាពតាមរយៈសកម្មភាពដូចខាងក្រោម ៖

  - រៀបចំផែនការសកម្មភាពសម្រាប់បណ្តុះបណ្តាល និងរិក្រឹតការគ្រូបង្រៀន ដើម្បី ពង្រាយទៅកាន់សាលារៀននៅតំបន់ជនបទ តំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក ដោយសហការជាមួយនាយកដ្ឋានបុគ្គលិក។
  - អភិវឌ្ឍផែនការសកម្មភាពសម្រាប់ពង្រឹងនិងពង្រីកការធ្វើរិក្រឹតការគ្រូបង្រៀន។
  - វាយ តម្លៃកម្មវិធីបណ្តុះបណ្តាល និងរិក្រឹតការគ្រូបង្រៀន រួមមានផលប៉ះពាល់នៃកម្មវិធីបណ្តុះបណ្តាលគ្រូសម្រាប់តំបន់ជនបទ តំបន់ដាច់ស្រយាល និងតំបន់ជួបការលំបាក។

### ៥. ការពិនិត្យតាមដាន និងការគ្រប់គ្រងកម្មវិធី

គោលបំណងនៃកម្មវិធីនេះ គឺផ្ទេរមជ្ឈការការពិនិត្យតាមដាន និងការវាយតម្លៃដល់សាលាគរុកោសល្យពីមជ្ឈការកសាងផែនការនិងត្រួតពិនិត្យ ទៅជាការពិនិត្យតាមដាននិងការគាំទ្រពីប្រព័ន្ធ បណ្តុះបណ្តាលថ្នាក់ជាតិ។ វត្ថុបំណងជាយុទ្ធសាស្ត្រនេះ គឺបង្កលទ្ធភាពផ្ទេរសិទ្ធិទទួលខុសត្រូវ និងស្វ័យភាពប្រតិបត្តិកាន់តែធំធេងដល់សាលាគរុកោសល្យ។ ថវិកាសម្រាប់ដំណើរការគ្រឹះស្ថាននីមួយៗត្រូវបានផ្តល់ជូនតាមរយៈមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត និងនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ។ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ត្រូវទទួលខុសត្រូវចំពោះការពិនិត្យតាមដាន និងការធានាគុណភាព។ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការត្រូវទទួលខុសត្រូវចំពោះការ កសាងផែនការនិងពិនិត្យតាមដានទូទៅ រួមមានការបែង ចែកថវិកាទៅតាមសេចក្តីណែនាំដែលបានឯកភាពគ្នារួចហើយ។ សាលាគរុកោសល្យនីមួយៗ ត្រូវ រៀបចំផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំ និងរបាយការណ៍រីកចម្រើនប្រចាំត្រីមាសរៀងរាល់ឆ្នាំ។

ការបែងចែក មូលនិធិទៅដល់សាលាគរុកោសល្យ ត្រូវគ្រប់គ្រងដោយមន្ទីរអប់រំ យុវជន និង កីឡារាជធានី ខេត្ត។ មន្ទីរអប់រំ យុវជន និង កីឡារាជធានី ខេត្តត្រូវរៀបចំផែនការបែងចែកថវិកា និងទទួលខុសត្រូវធ្វើរបាយការណ៍កិច្ចបញ្ជីការគណនេយ្យ។ គណៈកម្មការប្រើប្រាស់មូលនិធិរបស់ សាលាគរុកោសល្យ រួមមាន នាយក នាយករង តំណាងបុគ្គលិក ២រូប និង តំណាងគរុសិស្ស គរុនិស្សិត ២រូប។ នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការទទួលខុសត្រូវ ចំពោះសកម្មភាពពិនិត្យតាមដានកម្មវិធី ដោយគិតទាំងការពិនិត្យតាមដានហិរញ្ញវត្ថុ។ នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការទទួលខុសត្រូវ ចំពោះការគ្រោង និងការតាមដានត្រួតពិនិត្យគុណភាពនិងប្រសិទ្ធភាពនៃការប្រើប្រាស់ ថវិការបស់ អនុកម្មវិធីនេះ។ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ពិនិត្យតាមដានការ រីកចម្រើន ។

## ២.២.៦ ការអប់រំក្រៅប្រព័ន្ធ

ក្នុងកំឡុងឆ្នាំ ២០០៩-២០១៣ អនុវិស័យអប់រំក្រៅប្រព័ន្ធមានការរីកចម្រើន ជាពិសេសអត្រាអក្ខរកម្មយុវជនអាយុ ១៥-២៤ កើនដល់ ៩១,៥ ភាគរយ នៅឆ្នាំ ២០១១។ ចំនួនថ្នាក់អក្ខរកម្មបានថយចុះពី ២១៤១ ថ្នាក់នៅឆ្នាំ ២០០៩ មកត្រឹម ១៥០០ ថ្នាក់នៅឆ្នាំ ២០១១ (ថយចុះ ៣០ ភាគរយ)។ ចំនួនអ្នកសិក្សាបានថយចុះពី ៥២០៧៨ នាក់មកត្រឹម ៣៤៩៦៤ នាក់ (ថយចុះ ៣២ ភាគរយ)។ បរិមាណនេះស្មើនឹង ២,៨ ភាគរយនៃអនក្ខរជន នៅឆ្នាំ ២០១១។ ចំនួនមជ្ឈមណ្ឌលសិក្សាសហគមន៍បានកើនពី ១៥៤ កន្លែងក្នុងឆ្នាំ ២០០៩ ដល់ ៣២១ កន្លែងក្នុងឆ្នាំ ២០១២ ។ ចំនួនថ្នាក់ បណ្តុះបណ្តាលជំនាញបានកើនឡើងពី ១៥៤ ថ្នាក់ទៅដល់ ៦៦៧ ថ្នាក់ ក្នុងនោះជំនាញសិប្បកម្ម ៣៥,៨ ភាគរយ ជំនាញអ៊ុតសក់និងតុបតែង ១៩,៥ ភាគរយ ភ្លេងនិងរបាំ ១៥,១ ភាគរយ ជំនាញម៉ាស៊ីន ១២,៧ ភាគរយ និងជំនាញដទៃទៀត ។ ចំនួនសិស្សក្នុងកម្មវិធីចូលរៀនឡើងវិញបានថយចុះពី ២៦១៧៦ នាក់ មកត្រឹម ២១៣៦៦ នាក់ ទាបជាងចំណុចដៅរបស់ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២២០០០ នាក់។

ក្របខ័ណ្ឌស្ថាប័ន និងគោលនយោបាយត្រូវបានពង្រឹង តាមរយៈ ការពិនិត្យឡើងវិញគោលនយោបាយអប់រំក្រៅប្រព័ន្ធ ការបង្កើតអនុក្រុមការងារអប់រំក្រៅប្រព័ន្ធនិងមានភារកិច្ចច្បាស់លាស់ ការវាយតម្លៃសមត្ថភាពអប់រំក្រៅប្រព័ន្ធនិងការកសាងផែនទី ក៏ដូចជាការពិនិត្យឡើងវិញកម្មវិធីចូលរៀន ឡើងវិញ និងការរៀបចំសេចក្តីណែនាំស្តីពីប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំក្រៅប្រព័ន្ធនិងកម្មវិធីសមមូល។ *(www.moeys.kh.com).*

## ២.៣ ចក្ខុវិស័យ និងបេសកកម្ម របស់ក្រសួងអប់រំ យុវជន និងកីឡា (អយក)

ចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺកសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជា ឱ្យក្លាយជាសង្គម រីកចម្រើន លើផ្នែកចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។

ដើម្បីសម្រេចបានតាមចក្ខុវិស័យខាងលើ ក្រសួងអប់រំ យុវជន និង កីឡាមានបេសកកម្ម ដឹកនាំគ្រប់គ្រង និងអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា ឱ្យឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច វប្បធម៌របស់កម្ពុជា និងការរីកចម្រើននៅក្នុងតំបន់ និង សកលលោក ។ វត្ថុបំណងរយៈពេលវែងរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺការអភិវឌ្ឍយុវជនកម្ពុជាលើគ្រប់ វិស័យ និងបណ្តុះស្មារតីយុវជន យុវតីកម្ពុជាគ្រប់រូបឱ្យមានមោទនភាពជាតិ មានសីលធម៌ល្អ និងគុណធម៌ខ្ពស់ ព្រមទាំងមានសុទិដ្ឋិនិយមចំពោះប្រទេសជាតិ និងប្រជាពលរដ្ឋរបស់ខ្លួន ។

វត្ថុបំណងចំពោះមុខរបស់ក្រសួងអប់រំ យុវជន និងកីឡា គឺធានាថា យុវជននិងកុមារកម្ពុជាគ្រប់ រូបមានឱកាសស្មើភាពគ្នាក្នុងការទទួលបានការអប់រំប្រកបដោយគុណភាពស្របតាមរដ្ឋធម្មនុញ្ញ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលចំពោះអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ពោលគឺគោលការណ៍មិនរើសអើងអំពីស្ថានភាពសង្គមគ្រួសារ ភូមិសាស្ត្រ ពូជសាសន៍ សាសនា ភាសា យេនឌ័រ និងកាយសម្បទា។ ក្រសួងសង្ឃឹមទុកថា នៅពេលដែលសិស្ស និស្សិតបានបញ្ចប់ការសិក្សារបស់ខ្លួន ពួកគេនឹងមានចំណេះដឹងស្របតាមស្តង់ដាមួយសមស្រប ព្រមទាំងអាចប្រកួតប្រជែងនៅលើទីផ្សារការងារក្នុងតំបន់ និងលើសកលលោក និងអាចក្លាយជាកម្លាំងស្នូលសម្រាប់ជំរុញការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចរបស់ប្រទេសជាតិ ។

ការធ្វើសមាហរណកម្មទៅក្នុងសមាគមអាស៊ានឆ្នាំ ២០១៥ និង ការប្រែក្លាយកម្ពុជាឱ្យទៅជា ប្រទេសមានចំណូលមធ្យម ឆ្នាំ ២០៣០ ទាមទារឱ្យមានការវិនិយោគបន្ថែមទៀតក្នុងវិស័យអប់រំ។ ធនធានមនុស្សដែលមានវិជ្ជាជីវៈត្រឹមត្រូវ និងមានគុណភាព ព្រមទាំងធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ក៏ត្រូវ ដាក់ចូលក្នុងវិស័យអប់រំផងដែរ (ប្រទេសក្នុងអាស៊ានដែលជោគជ័យ ក៏ទទួលបទពិសោធពីការបង្កើន ការវិនិយោគទៅក្នុងវិស័យអប់រំ ៥ ភាគរយនៃផលិតផលក្នុងស្រុកសរុប)។

ក្រសួងទទួលស្គាល់ពីសារៈសំខាន់ក្នុងការជំរុញឱ្យវិស័យទាំងមូលអាចធ្វើការជាមួយគ្នា ដើម្បី ឆ្លើយតបនឹងតម្រូវការសង្គមនិងសេដ្ឋកិច្ច។ ចំណុចផ្តោតរបស់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៤-២០១៨ គឺប្រមូលផ្តុំនូវសមិទ្ធផលដែលមានកន្លងមក ការឈានទៅដល់ក្រុមជួបការលំបាក ការផ្តល់ការអប់រំប្រកបដោយគុណភាពនិងភាពពាក់ព័ន្ធដល់ការអភិវឌ្ឍប្រទេស។ ការផ្តល់សេវាអប់រំប្រកបដោយ វិជ្ជាជីវៈនិងគណនេយ្យភាព ជាមូលដ្ឋានសម្រាប់កសាងសង្គមមួយប្រកបដោយចំណេះដឹងនិងជំនាញ។ វិស័យអប់រំនឹងរៀបចំនូវក្របខណ្ឌធានាគុណភាពទូទាំងវិស័យ ដោយផ្អែកលើការសិក្សារៀនសូត្រនិងការផ្តល់សេវាតាមស្តង់ដារឆ្លើយតបទៅនឹងតម្រូវការរបស់កុមារ សហគមន៍ និងទីផ្សារការងារ។*(www.moeys.kh.com)*

## ២.៤.យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ

ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើមូលដ្ឋានីយកម្ម ក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពស្តីពីការអប់រំ ឆ្នាំ២០៣០ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ដែលមានគោលនយោបាយពីរគឺ ១ ) ធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ២) ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ដូចខាងក្រោម៖

### ២.៤.១ យុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងអប់រំ

១) កំណែទម្រង់ការគ្រប់គ្រងការសិក្សា ផ្តោតលើរង្វាយតម្លៃការសិក្សារបស់សិស្សជាប្រចាំ ការកែលម្អវិធីសាស្ត្របង្រៀន និងការដាក់បញ្ចូលភាពជាពលរដ្ឋមានគុណភាព ក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល ២) កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាល ផ្តោតលើការធានាការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៍មូលដ្ឋាន ការអនុវត្តការគ្រប់គ្រងតាមសាលារៀន និងការអនុវត្តគោលនយោបាយអប់រំ និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ៣) កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ ផ្តោតលើការបង្កើនស្វ័យភាព និងគណនេយ្យភាពហិរញ្ញវត្ថុនៅសាលារៀនការធ្វើសវនកម្មថវិកាអប់រំជាទៀងទាត់ និងការបង្កើនការបែងចែកថវិកាផ្សារភ្ជាប់នឹងគោលនយោបាយអប់រំ ៤) កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស ផ្តោតលើការបណ្តុះបណ្តាលដោយផ្តោតលើវិធីសាស្ត្របង្រៀន និងកម្មវិធីបំប៉ននៅនឹងកន្លែង ការបង្កើនការបណ្តុះបណ្តាលគ្រូបង្រៀន និងការអនុវត្តការវាយតម្លៃការបំពេញការងាររបស់បុគ្គលិកអប់រំ។

### ២.៤.២ យុទ្ធសាស្ត្រកំណែទម្រង់ឧត្តមសិក្សា

នៅក្នុងយុទ្ធសាស្ត្រកំណែទម្រង់ឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡាបានយកចិត្តទុកដាក់លើបញ្ហាមួយចំនួនដូចជាៈ ១) ពិនិត្យលទ្ធភាពប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ទៅជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈរដ្ឋបាល ២) ផ្តល់ស្វ័យភាពដល់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានមនុស្ស ៣) រៀបចំក្របខណ្ឌកម្មវិធីសិក្សាឲ្យឆ្លើយតបទៅនឹងការវិវត្តឧស្សាហកម្ម ៤) ជំរុញការស្រាវជ្រាវ និងលើកទឹកចិត្តការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវឧត្តមភាពនៅតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ៥) វាយតម្លៃគុណភាពអប់រំផ្ទៃក្នុង និងការវាយតម្លៃគុណភាពអប់រំនៅតាមគ្រឹះស្ថានឧត្តមសិក្សា។

### ២.៤.៣ យុទ្ធសាស្ត្រកំណែទម្រង់ការអភិវឌ្ឍយុវជន

យុវជន គឺជាទំពាំងស្នងឫស្សី និងជាអ្នកបន្តវេនអ្នកជំនាន់មុន។ នាពេលបច្ចុប្បន្នយុវជនបានដើរតួយ៉ាងសំខាន់ក្នុងការធ្វើចលនានៃការអភិវឌ្ឍ ក៏ដូចជាការកៀរគរស្វែងរកនូវថវិកា និងការចូលរួមជួយសង្គមជាតិឲ្យមានការរីកចម្រើន។ ហេតុដូចនេះទើបក្រសួងអប់រំ យុវជន និងកីឡាបានកំពុងយកចិត្តទុកដាក់ព្រមទាំងបានបង្កើតនូវ យុទ្ធសាស្ត្រកំណែទម្រង់ការអភិវឌ្ឍយុវជន រួមមានៈ

១) ផ្តល់ឱកាសឲ្យយុវជនទទួលបានការអប់រំ និងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈប្រកបដោយគុណភាព និងសមធម៌ ២) លើកទឹកចិត្តយុវជនឲ្យមានគំនិតផ្តួចផ្តើម គំនិតឆ្នៃប្រឌិត គំនិតបង្កើតថ្មី និងស្មារតីសហគ្រិនភាព ៣) អភិវឌ្ឍយុវជនឲ្យមានកាយសម្បទា ចំណេះដឹង ចំណេះធ្វើ សីលធម៌រស់នៅល្អ ចេះរួមរស់ជាមួយគ្នា ដោយសន្តិភាព និងសុខដុមនីយកម្ម ៤) បង្កឱកាសឲ្យយុវជនចូលរួមបញ្ចេញមតិ ទស្សនៈ និងធ្វើសេចក្តីសម្រេចចិត្តនានា នៅក្នុងការអភិវឌ្ឍសហគមន៍ និងសង្គមជាតិ ៥) ពង្រឹងយន្តការគ្រប់គ្រង និងពិនិត្យតាមដានកម្មវិធីអភិវឌ្ឍយុវជន

### ២.២.៤.យុទ្ធសាស្ត្រកំណែទម្រង់ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា

ការផ្តោតលើយុទ្ធសាស្ត្រកំណែទម្រង់ការអភិវឌ្ឍវិស័យអប់រំ យុវជន និងកីឡាបានយកចិត្តទុកដាក់លើបញ្ហាដូចជាៈ ១) អភិវឌ្ឍក្របខណ្ឌច្បាប់ និងគតិយុត្ត ២) អភិវឌ្ឍកីឡាកម្រិតខ្ពស់ ៣) ការអភិវឌ្ឍកីឡាសម្រាប់ទាំងអស់គ្នា ៤) អភិវឌ្ឍវិស័យអប់រំកាយ និងកីឡានៅគ្រឹះស្ថានសិក្សា និងសហគមន៍ ៥) អភិរក្ស និងអភិវឌ្ឍកីឡាគ្រប់ប្រភេទ ***(យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៨-២០២៣)***

## ២.៥.គោលនយោបាយលើកកម្ពស់វិស័យអប់រំ ដែលជាវិស័យអាទិភាព

**២.៥.១ គោលនយោបាយ ធនធានមនុស្សក្នុងវិស័យអប់រំៈ** គោលនយោបាយធនធានមនុស្សក្នុងវិស័យអប់រំ(ឆ្នាំ២០១២) បានដាក់ចេញនូវចក្ខុវិស័យ គោលបំណង និងគោលដៅសំខាន់ៗដូចជាៈ **ចក្ខុវិស័យៈ** ប្រែក្លាយធនធានមនុស្សឲ្យកាន់តែមាន សមត្ថភាពការងារ មានប្រសិទ្ធិភាព មានភាព

ស័ក្តិសិទ្ធិ និងមានការជឿទុកចិត្តក្នុងការផ្តល់ និងគាំទ្រសេវាអប់រំ ដើម្បីរួមចំណែកអភិវឌ្ឍសមត្ថភាពបុគ្គល និងស្ថាប័នប្រកបដោយឧត្តមភាព។ **គោលបំណង៖** ធ្វើឲ្យធនធានមនុស្សមានជំនាញវិជ្ជាជីវៈច្បាស់លាស់ មានភាពទទួលខុសត្រូវ មានភាពឆ្លើយតប និងត្រូវបានប្រើប្រាស់ទៅតាមតម្រូវការជាក់ស្តែងប្រកបដោយភាពស័ក្តិសិទ្ធិ និងសមធម៌។ គោលដៅ៖ (១)បង្កើនប្រសិទ្ធិភាពការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអរំ។ (២)ធ្វើសនិទានកម្មលើដំណើការគ្រប់គ្រង ការអភិវឌ្ឍ និងការប្រើប្រាស់ធនធានមនុស្សក្នុងវិស័យអប់រំ។ (៣)អភិវឌ្ឍសមត្ថភាពបុគ្គល អង្គភាព និងស្ថាប័នវិស័យអប់រំ។ (៤)ពង្រឹងក្រមសីលធម៌ និងវិន័យការងាររបស់បុគ្គលិកអប់រំ។ ***(ក្រសួងអប់រំ ឆ្នាំ២០១២)***

**២.៥.២ គោលនយោបាយ ស្តីពីគ្រូបង្រៀន៖** គោលនយោបាយគ្រូបង្រៀន មានចក្ខុវិស័យក្នុងការកសាងគ្រូបង្រៀនឲ្យមានចំណេះដឹង ជំនាញ សីលធម៌ និងមានសមត្ថភាពអនុវត្តវិជ្ជាជីវៈដោយមានការទទួលស្គាល់ពីសង្គម។ ព្រមទាំងគោលបំណង អភិវឌ្ឍគ្រូបង្រៀនឲ្យមានគុណភាព សមត្ថភាព ស្មារតីទទួលខុសត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈនិងផ្តល់លក្ខខណ្ឌចាំបាច់ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធិភាព និងភាពស័ក្តិសិទ្ធិ។***(ក្រសួងអប់រំ ឆ្នាំ២០១៣)***

**២.៥.៣ យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ នីតិកាលទី៥ របស់រាជរដ្ឋាភិបាលកម្ពុជា៖** ការកំណែទម្រង់វិស័យអប់រំ បង្កើតបាននូវបរិយាកាស និងក្តីសង្ឃឹម ក្នុងការបង្កើនគុណភាពធនធានមនុស្ស និងជំនាញសម្រាប់ផ្គត់ផ្គង់ទីផ្សារការងារ តាមរយៈការបង្កើតឲ្យមានសាលាជំនាន់ថ្មី ការពង្រឹងគុណភាពនៃការបង្រៀន ការលើកកម្ពស់សមត្ថភាពក្នុងការគ្រប់គ្រងសាលារៀន ការធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា និងការរៀបចំបរិយាកាសល្អសម្រាប់ការរៀនសូត្រ ដែលត្រូវបានជំរុញឲ្យមានវឌ្ឍនភាព។ *(យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ នីតិកាលទី៥ របស់រាជរដ្ឋាភិបាលកម្ពុជា)។*

**២.៥.៤ យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ នីតិកាលទី៦ របស់រាជរដ្ឋាភិបាលកម្ពុជា៖** ការអភិវឌ្ឍធនធានមនុស្ស ពោលគឺការបង្កើនគុណភាពវិស័យអប់រំ វិទ្យាសាស្រ្ត និងបច្ចេកទេស។ គោលដៅជាយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាល គឺអភិវឌ្ឍប្រព័ន្ធអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាប័ន្ន ដោយផ្តោតលើវិទ្យាសាស្រ្ត និងបច្ចេកទេស ការតម្រង់ទិសសម្រាប់ទីផ្សារការងារ និងការយកចិត្តទុកដាក់លើការអប់រំកាយ សម្រាប់ការទ្រទ្រង់ការអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិ។ ជាលទ្ធផលដែលរាជរដ្ឋាភិបាល សម្រេចបាន គឺអត្រាចូលរៀនខ្ពស់នៅកម្រិតបឋមសិក្សា ការលើកកម្ពស់គុណភាព និងតម្លៃនៃការអប់រំ ការធ្វើទំនើបកម្មប្រព័ន្ធអប់រំ ដូចជា ការបញ្ចូលមុខវិជ្ជា STEM[1] ក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល។ ការរៀបចំបរិស្ថានសិក្សា និងការរៀបចំឲ្យមានសាលារៀនជំនាន់ថ្មី ការពង្រឹងអធិការកិច្ចវិស័យអប់រំ និងការកែទម្រង់ឧត្តមសិក្សា ព្រមទាំងការរៀបចំ និងអនុវត្តផែនការគោលសម្រាប់ការអប់រំបច្ចេកទេសនៅវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ពិសេសលើមុខជំនាញអគ្គិសនី អេឡិចត្រូនិច មេកានិច បសុវប្បកម្ម និងក្សេត្រសាស្រ្ត។ *(យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ នីតិកាលទី៦ របស់រាជរដ្ឋាភិបាលកម្ពុជា)។*

**២.៥.៥ គោលនយោបាយអប់រំឆ្នាំ២០០៩-២០១៣៖** បានកំណត់គោលនយោបាយចំនួនបី គឺ ១.ធានាលទ្ធភាពទទួលបានសេវាអប់រំ ប្រកបដោយសមធម៌ ២.លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ និង ៣.អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ ។

គោលនយោបាយទី ១ ៖ ធានាលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌

កុមារគ្រប់រូបនឹងទទួលសេវាអប់រំកុមារតូចតាមគ្រប់រូបភាព បានចូលរៀននៅបឋមសិក្សា មធ្យមសិក្សាទុតិយភូមិ និងមានឱកាសបន្តការសិក្សាទៅមុខទៀត។ សម្រាប់កុមារដែលពុំមានលទ្ធភាពចូលរៀនក្នុងប្រព័ន្ធ ជម្រើសផ្សេងទៀតនឹងត្រូវផ្តល់លទ្ធភាពឱ្យអ្នកទាំងនោះទទួលបានការអប់រំ។ ការបង្កើនចំនួនកុមារ និងយុវជន ឱ្យទទួលបានការអប់រំនៅគ្រប់កម្រិត ដោយផ្តោតលើសមធម៌ និងតំបន់និងក្រុមកុមារជួបការលំបាក។

ការបង្កើនឱកាសដល់សិស្សដែលបញ្ចប់ការសិក្សានៅថ្នាក់ទី១២ ឱ្យទទួលបាននូវចំណេះដឹងនិងជំនាញក្នុងការគិតនិងហេតុផល និងអាចជាមូលដ្ឋានសម្រាប់បន្តការសិក្សានៅក្នុងការបណ្តុះបណ្តាលបច្ចេកទេស និងឧត្តមសិក្សាតទៅទៀត។

គោលនយោបាយទី ២ ៖ លើកកម្ពស់គុណភាពនិងភាពឆ្លើយតប

កុមារនិងយុវជនគ្រប់រូបនឹងទទួលបានការអប់រំដែលមានភាពពាក់ព័ន្ធ និងប្រកបដោយគុណភាពដែលអាចឱ្យពួកគេអាចចូលរួមចំណែកដល់ការអភិវឌ្ឍប្រទេសជាតិ។

ការធានាថា ការអប់រំប្រកបដោយគុណភាព និងមានទំនាក់ទំនងទៅនឹងគោលដៅអភិវឌ្ឍសង្គម សេដ្ឋកិច្ចរបស់ប្រទេស។ ក្របខណ្ឌគុណភាពដែលផ្តល់ដល់អ្នកសិក្សា មាតាបិតា សហគមន៍ គ្រូបង្រៀន និងអ្នកគ្រប់គ្រង ជាមួយនឹងស្តង់ដារនៃផលសម្រេច ការពិនិត្យតាមដាន និងរបាយការណ៍។

គោលនយោបាយទី ៣ ៖ ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ការផ្តល់សេវាអប់រំប្រកបដោយគុណភាពនិងប្រសិទ្ធភាព។ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនិងវិជ្ជាជីវៈនឹងផ្តល់នូវតម្លៃដ៏ល្អបំផុត (ផ្តោតលើលទ្ធផល) ទាន់ពេលវេលា និងពាក់ព័ន្ធនឹងការ ពិនិត្យតាមដាននិងរបាយការណ៍នៃលទ្ធផលទាំងនោះ ជាមួយនឹងយោបល់ត្រឡប់ ព្រមទាំងយន្តការសម្រាប់កែលម្អគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធី ***(ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៣)*** ។

**២.៥.៦ គោលនយោបាយអប់រំឆ្នាំ ២០១៤-២០១៨៖** បានកំណត់គោលនយោបាយចំនួនបី គឺ ១.ធានាលទ្ធភាពទទួលបានសេវាអប់រំ ប្រកបដោយសមធម៌ ២.លើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាអប់រំ និង ៣.អភិវឌ្ឍស្ថាប័ន និងអភិវឌ្ឍសមត្ថភាពមន្ត្រីអប់រំសម្រាប់ធ្វើវិមជ្ឈការ ***(ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៩)*** ។

**២.៥.៧ គោលនយោបាយអប់រំ ឆ្នាំ២០១៤-២០២៣៖** បានកំណត់គោលនយោបាយចំនួនពីរ គឺ ១.ធានាឲ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ ២.ធានាភាពស័ក្តិសិទ្ធ នៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។ នៅក្នុងគោលនយោបាយអប់រំនេះផងដែរ ក៏មានចក្ខុវិស័យច្បាស់លាស់ពោលគឺកសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព និងគុណធម៌ប្រសើរបំផុតលើគ្រប់ផ្នែក ដើម្បីកសាងសង្គមកម្ពុជាឲ្យក្លាយជាសង្គមរីកចម្រើន ផ្អែកលើចំណេះដឹង និងចំណេះធ្វើជាមូលដ្ឋាន។ *( ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៩)*

**២.៥.៨ ចក្ខុវិស័យសម្រាប់វិស័យអប់រំ នៅឆ្នាំ២០៣០** គឺការផ្លាស់ប្តូរជីវិតឲ្យប្រសើរឡើងតាមរយៈការអប់រំ ដោយទទួលស្គាល់ពីតួនាទីយ៉ាងសំខាន់ នៃការអប់រំថាជាក្បាលម៉ាស៊ីនចម្បងមួយនៃការអភិវឌ្ឍ និងការសម្រេចគោលដៅអភិវឌ្ឍន៍ដោយចីរភាពនិងក្តីសង្ឃឹមដែលនឹងមិនទុកអ្នកណាម្នាក់ចោលនៅពីក្រោយឡើយ។ ចក្ខុវិស័យនេះឆ្លើយតបយ៉ាងពេញលេញដោយ SDG 4 ដែលបានស្នើឡើងថា *ធានាឲ្យបាននូវការអប់រំប្រកបដោយគុណភាព បរិយាប័ន្ន សមធម៌ រួមទាំងលើកកម្ពស់ឱកាសការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។*

## ២.៦.គោលនយោបាយសាលារៀនជំនាន់ថ្មី:

សាលារៀនជំនាន់ថ្មី បង្កើតឡើងក្នុងគោលបំណងព្យាយាមបង្កើតគំរូអភិវឌ្ឍថ្មីនៅក្នុងប្រព័ន្ធអប់រំសាធារណៈ ដែលនឹងនាំទៅដល់ការបង្កើតសាលារៀនសាធារណៈស្វយ័ត ដែលទទួលបានការវិនិយោគខ្ពស់ផ្សារភ្ជាប់នឹងស្តង់ដាថ្មីមានគណនេយ្យភាព និងអភិបាលកិច្ចល្អ ព្រមទាំងស្តង់ដាវិជ្ជាជីវៈសម្រាប់ការសិក្សានៅក្នុងសតវត្សន៍ទី២១។ គោលនយោបាយនេះក៏មានគោលលដៅដូចជា: ១) បង្កើតសាលារៀនសាធារណៈស្វយ័តគ្រប់គ្រងដោយវិន័យតឹងរឹងក្នុងការបំពេញភារកិច្ច និងមានគណនេយ្យភាពផ្សារភ្ជាប់ទៅនឹងការវិនិយោគខ្ពស់។ ២) បង្កើតក្រុមប្រឹក្សាភិបាលដែលនឹងធ្វើឲ្យសាលាទទួលខុសត្រូវសម្រាប់ការបំពេញភារកិច្ច។ ៣) បង្កើតប្រព័ន្ធទទួលស្គាល់ដែលនឹងសម្របសម្រួលដល់ការសម្រេចចិត្តរបស់ក្រុមប្រឹក្សាភិបាលដោយប្រកាន់ភ្ជាប់ទៅនឹងគោលការណ៍ស្នូលរបស់សាលារៀនជំនាន់ថ្មី។ ៤) ផ្តល់សេរីភាពស្ថាប័នថ្មី (ស្វ័យភាពប្រតិបត្តិការ) ដើម្បីធ្វើឲ្យមានការឆ្នៃប្រឌិតក្នុងវិធីរៀបចំបង្កើត និងផ្តល់សេវាអប់រំ។ ៥) ធ្វើឲ្យប្រព័ន្ធអប់រំមានប្រសិទ្ធិភាព និងសមធម៌សង្គមក្នុងដំណើរការបង្រៀន និងរៀនដោយមានប្រព័ន្ធបែងចែកធនធានឲ្យសមស្របសំដៅលើកកម្ពស់សេវាអប់រំ។ ៦) កែលម្អស្តង់ដាបង្រៀនតាមរយៈវិធីសាស្ត្រថ្មីៗដែលរួមបញ្ចូល ការជ្រើសរើសគ្រូដោយការប្រកួតប្រជែង ប្រាក់លើកទឹកចិត្តអាស្រ័យលើភារកិច្ច ការប៉ប៉នសកម្មភាពគ្រូបង្រៀនបន្ថែមលើផ្នែកបច្ចេកវិទ្យា STEM និងការសិក្សាឲ្យស្គាល់បញ្ហា និងការរកដំណោះស្រាយព្រមទាំងគន្លងអាជីបគ្រូបង្រៀនច្បាស់លាស់ភ្ជាប់ទៅនឹងឱកាសអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន(អាហារូបករណ៍គ្រូដើម្បីបន្តការសិក្សាពេលអនាគត) ។ ៧) ពង្រីកសេវាអប់រំសម្រាប់យុវជនកម្ពុជាដែលនឹងរួមបញ្ចូលទាំងសេវាប្រឹក្សាអាជីព សកម្មភាពសិក្សាប្លែកៗ ដូចជា: ការងារគម្រោង ក្លឹបសិក្សាតាមមុខវិជ្ជា ការសិក្សា

តាមឧបករណ៍ចល័ត និងកម្មវិធីសិក្សាបំណិនជីវិត។ ដើម្បីសម្រេចបានគោលបំណង និងគោលដៅខាងលើ ត្រូវមានយុទ្ធសាស្ត្រដូចជា ការជ្រើសរើសសាលាយ៉ាងហ្មត់ចត់ ភាពជាដៃគូ ការទទួលខុសត្រូវរបស់សាលាជំនាន់ថ្មី ការត្រួតពិនិត្យដោយផ្ទាល់ពីថ្នាក់ជាតិ ប្រាក់លើកទឹកចិត្តគ្រូដំណើរស្វ័យភាពផ្សារភ្ជាប់នឹងការផ្ទៃប្រឌិតថ្មី ការប្រើប្រាស់បច្ចេកវិទ្យា ការពង្រឹងសិទ្ធិអំណាចយុវជន ការបង្កើនម៉ោងបង្រៀន និងរៀន ការអនុវត្តប្រភេទមុខវិជ្ជា មូលនិធិសមធម៌សង្គម គំរូសាលាក្នុងសាលា ការកាត់បន្ថយផលធៀបគ្រូ សិស្ស ការផ្លាស់ប្តូរផ្នត់គំនិតបុគ្គល និងការធ្វើទំនើបកម្មបរិស្ថានសិក្សា។ *(ក្រសួងអប់រំ យុវជន និងកីឡា ខែកញ្ញា ឆ្នាំ ២០១៦)*

## ២.៧ អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា(KAPE)

*អង្គការ ខេប* គឺជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលធ្វើការចម្បងនៅក្នុងវិស័យអប់រំក្នុងប្រព័ន្ធនៅកម្ពុជា។ ជាអង្គការមិនរកប្រាក់ចំណូលបានកំពុងប្រតិបត្តិការគម្រោង និងការស្រាវជ្រាវផ្នែកអប់រំ នៅគ្រប់កម្រិត នៅក្នុងប្រទេសកម្ពុជា ហើយមានអ្នកទទួលផលទាំងសាលាបឋមសិក្សា មធ្យមសិក្សា និងកម្មវិធីសកលវិទ្យាល័យ។ នៅពេលបច្ចុប្បន្ននេះ មានអ្នកទទួលផលផ្ទាល់ពីអង្គការ ខេប ជាកុមារចំនួនជាង ៧១.០០០នាក់ និងនាយកសាលា លោកគ្រូ អ្នកគ្រូចំនួន ១.៦៥០នាក់ នៅក្នុងសាលាចំនួន ១៦៥ ក្នុងខេត្តចំនួន ១៤។

*ការវិភាគបញ្ហាដែលជាមូលដ្ឋានក្នុងការបង្កើតគម្រោងសាលារៀនបានរកឃើញនូវបញ្ហាមួយចំនួនដែលធ្វើឲ្យគុណភាពអប់រំចុះខ្សោយ មានដូចជា:* (១) ផ្នែកគណនេយ្យភាពក្នុងការបំពេញភារកិច្ចនៅមានកម្រិតទាបទាំងសហគមន៍ និងមន្ត្រីអប់រំស្រុក។ អភិបាលកិច្ចទន់ខ្សោយឆ្លុះឲ្យឃើញថា ខ្វះគណនេយ្យភាពក្នុងការបំពេញភារកិច្ច ដែលនាំឲ្យមានការអនុគ្រោះខ្ពស់ចំពោះទង្វើខ្វះវិជ្ជាជីវៈ ឬសូម្បីទង្វើអសមត្ថភាព។ (២) ភាពអន់ថយក្នុងការកំណត់និយមន័យច្រកអាជីពសម្រាប់បុគ្គលិកដែលមានស្តង់ដាវិជ្ជាជីវៈខ្ពស់ (មានផលវិបាកក្នុងការលើកទឹកចិត្ត) និង (៣)ប្រាក់រង្វាន់លើកទឹកចិត្តតិចតួច។

*ការប្តេជ្ញាចិត្តដើម្បីឲ្យមានអភិបាលកិច្ចល្អ* គឺជាបុរេលក្ខខណ្ឌនៃការចាប់ផ្តើមការបង់ថ្លៃការសិក្សាដោយជោគជ័យ នៅឆ្នាំ២០១៤ សាលាអនុវត្តបានធ្វើកិច្ចសន្យាជាមួយឪពុកម្តាយ ថានឹងផ្តល់សេវាកម្មគុណភាពអប់រំខ្ពស់ សម្រាប់អភិបាលកិច្ចល្អ ដូចតទៅ៖ (១)គ្រូបង្រៀនយល់ព្រមឲ្យសាលារៀនលប់បំបាត់រាល់ទម្រង់នៃការបង់ថ្លៃរៀនគួរ (ជំនួសវិញដោយការផ្តល់នូវប្រាក់ឧបត្ថម្ភបន្ថែមនិងឱកាសទទួលបានប្រាក់លើកទឹកចិត្តតាមការបំពេញភារកិច្ច)។ (២)សកម្មភាពនៃការលក់នំឲ្យសិស្ស (ការបង្ខំ) នៅក្នុងថ្នាក់រៀនត្រូវបានលុបបំបាត់។ (៣)សកម្មភាពយកថ្លៃក្រដាសប្រឡងក៏ត្រូវបានលុបបំបាត់ (៤)សិស្សអាចប្រើប្រាស់បរិក្ខាមានគុណភាពខ្ពស់ រួមទាំងបន្ទប់វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ មណ្ឌលព័ត៌មាន ទទួលបានវិធីសាស្ត្របង្រៀនដោយបញ្ច្រាបបច្ចេកវិទ្យាព័ត៌មាន ICT និងសេវាកម្មអាហារដ្ឋានផងដែរ។ (៥)មាតាបិតានឹងទទួលបានព័ត៌មាន ស្តីពីសិស្សអវត្តមានដោយគ្មានមូលហេតុ (ដែលបច្ចុប្បន្នកំពុងអនុវត្តនៅតាមសាលារៀន)។

(៦)សាលានឹងរាយការណ៍ទៅក្រុមប្រឹក្សាភិបាល ដែលមានសមាសភាពមកពីមន្ទីរអប់រំ និងអង្គការខេប ព្រមទាំងផ្តល់របាយការណ៍ត្រីមាស ស្តីពីការប្រើប្រាស់មូលនិធិ (ភាគច្រើនគឺការបន្ថែមប្រាក់ខែគ្រូ និងការផ្ត ល់ថវិកាលើកិច្ចការពិសេសសម្រាប់ក្លឹបសិក្សា សេវាផ្តល់ប្រឹក្សាអាជីព។

### តារាងទី១៖ ការចំណាយលម្អិត និងប្រភពចំណូលសំខាន់ៗរបស់សាលា

| ចំណាយសំខាន់ប្រចាំឆ្នាំ | ភាគរយលំអិត | ប្រភពប្រាក់ចំណូល | ភាគរយលំអិត |
|---|---|---|---|
| ប្រាក់ឧបត្ថម្ភគ្រូបង្រៀន | ៧៣% | វិភាគទានមាតាបិតាសិស្ស | ៣១% |
| អំណោយសាលារៀន | ១០% | ចំណូលពីអាហារដ្ឋាន | ៦% |
| សន្តិសុខ | ៧% | ចំណូលផ្សេងៗក្នុងសាលា | ៣% |
| ការគ្រប់គ្រង | ៩% | អំណោយស្ថាប័នឯកជន | ៨% |
| ការថែទាំ | ១% | ថវិកាEndownment Fund | ៤% |
| **សរុប** | **១00%** | ថវិកាផ្ទៃក្នុងរបស់ខេប | ៤៨% |
| **សរុប** | | | **១00%** |

*(អង្គការខេប ខែតុលា ឆ្នាំ២០១៤, kape@kapekh.org)*

## ២.៨ សាលរៀនជំនាន់ថ្មី ( អនុវិទ្យាល័យគោកព្រីង )

យោងតាមប្រសាសន៍របស់លោក **គង់ ណារិន** នាយកសាលារៀនំនាន់ថ្មី (អនុវិទ្យាល័យគោក ព្រីង) បានឲ្យដឹងថាៈ មុនពេលដែលមានការចាប់ផ្តើមសាលារៀនជំនាន់ថ្មី នៅមុនឆ្នាំ២០១៦ គឺសាលារៀន ពុំមានភាពទំនើប ហេដ្ឋារចនាសម្ព័ន្ធនៅអន់ថយ ខ្វះអគារ ខ្វះសម្ភារៈសិក្សា ខ្វះសៀវភៅសិក្សាគោល ខ្វះគ្រូ ខ្វះសម្ភារៈបច្ចេកវិទ្យាព័ត៌មានវិទ្យា សមត្ថភាពគ្រូនៅមានកម្រិត។ ក្រោយពីប្រែក្លាយខ្លួនទៅជាសាលារៀន ជំនាន់ថ្មី នៅឆ្នាំ២០១៦ មកសាលារៀនមានការផ្លាស់ប្តូរមុខមាត់ ពោលគឺផ្តោតទៅលើចំណុចសំខាន់ ៤គឺ ***(១)ហេដ្ឋារចនាសម្ព័ន្ធ*** មានការផ្លាស់ប្តូរដោយមានអគារសិក្សាថ្មី ហើយអគារសិក្សាចាស់ត្រូវបានកែលម្អឲ្យ ត្រូវតាមស្តង់ដា មានបំពាក់បរិក្ខារសិក្សាថ្មីៗ និងមានភាពទំនើបជាងមុន មានតុ ក្តារខៀនថ្មី មានកុំព្យូទ័រ LCD ព្រមទាំងបានចាត់បន្ទប់ទៅតាមមុខវិជ្ជានីមួយៗ។ ***(២)លោកគ្រូ អ្នកគ្រូ*** ត្រូវបានបំប៉នវិធីសាស្រ្ត បង្រៀនបែបថ្មី តាមបែបស្ថាបនានិយម ជាពិសេសវិធីសាស្រ្តបង្រៀនតាមបែប សហការនិយម និងទទួល

បានចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យា (ទាំងវិធីសាស្ត្របង្រៀន និងការប្រើប្រាស់កុំព្យូទ័រ)។ ***(៣)កម្មវិធីសិក្សា*** កម្មវិធីសិក្សាត្រូវបានផ្លាស់ប្តូរដោយពង្រីកម៉ោងសិក្សាបន្ថែម ពីមុនការបង្រៀន និងរៀន ៣០ម៉ោង/សប្តាហ៍ តែកម្មវិធីនាពេលបច្ចុប្បន្ន ៤០ម៉ោង/សប្តាហ៍ ហើយត្រូវបានពង្រីកទៅលើម៉ោងវិទ្យាសាស្ត្រ។ ***(៤)វិធីសាស្ត្របង្រៀន*** បានផ្តោតទៅលើចំណុចសំខាន់ៗ ៥គឺ៖ ***(ក) សៀវភៅសិក្សាគោល*** នៅប្រើប្រាស់សៀវភៅសិក្សាក្នុងការសិក្សាដូចមុន តែត្រូវបន្ថែមវិធីសាស្ត្រថ្មីៗ ដូចជា៖ ល្បែងសិក្សា ការសិក្សាមេរៀនបំណិនជីវិត វិធីសាស្ត្របង្រៀនតាមបែបសហការ និងបែបស្ថាបនានិយម។ ***(ខ) បណ្ណាល័យ*** មានការជំរុញឲ្យសិស្សានុសិស្សចូលអានសៀវភៅ ស្រាវជ្រាវមេរៀន និងស្រាវជ្រាវមេរៀនបំណិនជីវិតផ្សេងៗ។ ***(គ) ការបង្រៀនបច្ចេកវិទ្យាព័ត៌មានវិទ្យា*** ការប្រើប្រាស់LCD ការបង្កើតEmail ការស្រាវជ្រាវតាមប្រព័ន្ធGoogle និងកម្មវិធីDownload ឯកសារផ្សេងៗតាមប្រព័ន្ធអីនធ័រណេត។ ***(ឃ) សម្ភារៈ និងការពិសោធន៍*** បន្ទាប់ពីការសិក្សាទៅលើទ្រឹស្តី សាលារៀនជំនាន់ថ្មីបានផ្តោតសំខាន់លើការពិសោធន៍ដោយផ្ទាល់ទៅលើមុខវិជ្ជានីមួយៗ ពោលគឺសិស្សានុសិស្សជាអ្នកធ្វើការពិសោធន៍ដោយផ្ទាល់ ឯគ្រូជាអ្នកសម្របសម្រួល និងកែតម្រូវ។ ***(ង)*** សាលារៀនជំនាន់ថ្មីបានផ្តោតលើមុខវិជ្ជា STEM ជាមុខវិជ្ជាសំខាន់ ព្រមទាំងធ្វើការតាំងពិព័ណស្នាដៃសិស្សដែលបានរកឃើញទៅតាមមុខវិជ្ជានីមួយៗ។ ***(កិច្ចសំភាសន៍រវាងអង្គការខប ជាមួយលោក គង់ ណារិន នាយកអនុវិទ្យាល័យគោកព្រីងនៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៧ )***

## ២.៩ គោលការណ៍នៃការជ្រើសរើសគ្រូនៃសាលារៀនជំនាន់ថ្មី

អនុវិទ្យាល័យគោកព្រីង ជាសាលាដែលមានបរិស្ថានសិក្សាទំនើប អភិបាលកិច្ចល្អ និងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនខ្ពស់ ទទួលបានការទុកចិត្ត កោតសរសើរពីមាតាបិតា សិស្សានុសិស្ស និងសហគមន៍ និងមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ ដូចនេះសាលាត្រូវការជ្រើសរើសគ្រូបង្រៀនតាមរយៈការប្រឡងប្រជែងដែលមានលក្ខណៈសម្បត្តិដូចតទៅ៖

### ២.៩.១ លក្ខណៈសម្បត្តិ

- ជាគ្រូបង្រៀនក្នុងក្របខ័ណ្ឌរដ្ឋដែលកំពុងបម្រើការងារក្នុងគ្រឹះស្ថានសិក្សារដ្ឋ
- ជាគ្រូបង្រៀនទើបនឹងបញ្ចប់វគ្គបណ្តុះបណ្តាលពីសាលាគរុកោសល្យ ឬវិទ្យាស្ថានជាតិអប់រំ
- មានចំណេះដឹងជ្រៅជ្រះលើមុខវិជ្ជាឯកទេស និងគរុកោសល្យ
- មានចំណេះដឹងផ្នែកបច្ចេកវិទ្យាព័ត៌មានវិទ្យា និងការស្រាវជ្រាវទំនើប
- មានអាយុមិនលើសពី ៣០ឆ្នាំ

### ២.៩.២ លក្ខន្តិកៈ

- គ្រូបង្រៀនដែលបានជ្រើសរើសមិនអនុញ្ញាតឲ្យរកកម្រៃពីសិស្ស ដូចជា ការលក់ដូរចំណី ក្រដាសប្រឡង ឯកសារមេរៀន និងការបង្រៀនឯកជន
- ត្រូវបំពេញការងារបង្រៀនឲ្យបានយ៉ាងហោចណាស់គ្រប់ម៉ោងកំណត់របស់ក្រសួង
- ទទួលបានការវាយតម្លៃប្រចាំឆ្នាំដោយក្រុមប្រឹក្សាភិបាលលើការបំពេញភារកិច្ច
- ក្រុមប្រឹក្សាភិបាលនឹងធ្វើការជ្រើសរើសឡើងដោយផ្អែលលើសមត្ថភាព

### ២.៩.៣ ឱកាស និងអត្ថប្រយោជន៍

- ទទួលបានកុំព្យូទ័រយួរដៃមួយគ្រឿងសម្រាប់បំពេញការងាប្រចាំថ្ងៃ
- ទទួលបានការបណ្តុះបណ្តាលស្តីពី ការប្រើប្រាស់បច្ចេកវិទ្យា ក្នុងវិស័យអប់រំ ការបំប៉នភាសាអង់គ្លេស វិធីសាស្រ្តបង្រៀនថ្មីៗ ដើម្បីពង្រឹងអាជីពគ្រូបង្រៀន
- ពង្រឹងសមត្ថភាពវិជ្ជជីវៈ គ្រូបង្រៀនឆ្លើយតបនឹងសមាហរណកម្មអាស៊ាន និងតម្រូវការអប់រំស្របនឹងនិន្នាការសកលភាវូបនីយកម្មក្នុងសតវត្សទី២១
- ទទួលបានថវិកាលើកទឹកចិត្តតាមការបំពេញភារកិច្ចប្រចាំខែប្រមាណ ៤០០ ០០០រៀល (លើកលែងវិស្សមកាល) បន្ថែមលើប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងទៀតអាស្រ័យលើទំហំការងារ
- ទទួលបានអាហារូបករណ៍ ដើម្បីបន្តការសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សានានាក្នុងព្រះរាជាណាចក្រកម្ពុជា
- ចូលរួមទស្សនកិច្ចសិក្សាទាំងក្នុង និងក្រៅប្រទេស។

*(អនុវិទ្យាល័យគោកព្រីង ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៧)*

## ២.១០ ទ្រឹស្តីពាក់ព័ន្ធ

### ២.១០.១ ការសិក្សាស្រាវជ្រាវរបស់លោក NCHUNGO និងលោក JOSEPHAT

តាមការសិក្សារបស់លោក NCHUNGO,JOSEPHAT (Setember,2013)សកលវិទ្យាល័យ ZAMBIA ផ្នែកអភិវឌ្ឍន៍ការសិក្សា បានសិក្សាទៅលើកត្តាដែលជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្ស ហើយលោកបានផ្តោតទៅលើបញ្ហាបីសំខាន់គឺ ១.កត្តាដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្សនៅសកលវិទ្យាល័យ University Of Zambia. ២. កត្តាភេទដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស។ ៣. ស្វែងរកឲ្យឃើញនូវអ្វីដែលសកលវិទ្យាល័យបានធ្វើក្នុងការដោះស្រាយទៅលើកត្តាដែលបានជះឥទ្ធពលដល់ការសិក្សារបស់សិស្ស។ ក្នុងការស្រាវជ្រាវ អ្នកស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរ

សម្រាប់សិស្ស សំណួរសម្រាប់សម្ភាសន៍ទៅលើផ្នែកគ្រប់គ្រងបុគ្គលិក និង លោកគ្រូអ្នកគ្រូ នៅសកលវិទ្យាល័យ។ អ្នកសិក្សាបានជ្រើសរើសភាគសំណាកចំនួន ៤០ ក្នុងនោះប្រុស ២០នាក់ ស្រីចំនួន ២០នាក់។ ជាលទ្ធផល កត្តាដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្សរួមមានៈ ១.ទីកន្លែងស្នាក់នៅមិនគ្រប់គ្រាន់ ២.កន្លែងរស់មានអនាម័យមិនល្អ ៣.សាលសិក្សាមានភាពចង្អៀត ៤.ខ្វះសៀវភៅសិក្សានៅក្នុងបណ្ណាល័យ ៥.ឯកសណ្ឋានរបស់សិស្ស ៦.ការដោះស្រាយម្ហូបអាហារដោយខ្លួនឯង(៩២.៦%)។ ចំពោះកត្តាភេទ គឺស្ត្រីទទួលឥទ្ធិពលជាងបុរសចំពោះការសិក្សា។ ចំពោះដំណោះស្រាយរបស់សកលវិទ្យាល័យគឺ ផ្តល់លទ្ធភាពឲ្យវិស័យឯកជនសាងសង់កន្លែងស្នាក់នៅ បែងចែកសាលសិក្សាឲ្យបានច្រើន បំពាក់អិនធ័រណេតតាមបណ្ណាល័យ បង្កើតវេបសាយដើម្បីស្រាវជ្រាវ និងសិក្សាឯកសារផ្សេងៗ។

## **២.១០.២ ការសិក្សារបស់លោក** JAMILLAH.H. MAGANGA

តាមការសិក្សាស្រាវជ្រាវរបស់លោក JAMILLAH H. MAGANGA បានសិក្សាទៅលើកត្តាដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្សនៅមធ្យមសិក្សាសាធារណៈមួយ ក្នុងស្រុក ILALA, TANZANIA (2016). ការសិក្សាបានផ្តោតទៅលើភាសាអង់គ្លេស ជាកត្តាដែលបានជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស។ សម្ភារៈនៃការបង្រៀន និងរៀន ដូចជា សៀវភៅសិក្សាគោល និងឧបករណ៍ពិសោធន៍គីមី ព្រមទាំងវិធីកសាងសមត្ថភាពនៃការដឹកនាំ ប្រឹក្សា និងវិធីដោះស្រាយចំពោះបញ្ហាទាំងឡាយដែលបានជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្ស។ ជាលទ្ធផលបានបង្ហាញឲ្យឃើញថាៈ

១. សិស្សភាគច្រើនខ្សោយភាសាអង់គ្លេស

២. សិស្សមិនចេះវាក្យស័ព្ទ

៣. សិស្សមិនចេះពាក្យបច្ចេកទេសទាក់ទងភូមិវិទ្យា រូបវិទ្យា និងគីមីវិទ្យា។

៤. សៀវភៅសិក្សាមិនគ្រប់គ្រាន់ ដូចជា សៀវភៅអប់រំសិល្បៈ និងសៀវភៅវិទ្យាសាស្ត្រជាដើម។

## **២.១០.៣ ការសិក្សាស្រាវជ្រាវរបស់** M.S.Farooq, A.H.Chaudhry, M.Shafiq **និង**G.Berhanu

តាមការសិក្សាស្រាវជ្រាវរបស់ M.S. Farooq, A.H. Chaudhry,M. Shafiq, G. Berhanu , University of the Punjab Pakistan និងuniversity of Gothenburg Sweden(December,2011) បានសិក្សាស្រាវជ្រាវទៅលើកត្តាដែលលបានជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្ស នៅថ្នាក់មធ្យមសិក្សា។ ចំពោះការស្រាវជ្រាវបានញែកឲ្យឃើញពីភាពខុសគ្នានៃកត្តាដែលជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សមធ្យមសិក្សានៅ Pakistan ។ អ្នកសិក្សាបានជ្រើសរើសសិស្សថ្នាក់ទី៩ ក្នុងនោះសិស្សប្រុសចំនួន៣០០នាក់ និងសិស្សស្រីចំនួន៣០០នាក់។ អ្នកសិក្សាបានប្រើកម្រងសំណួរក្នុងការប្រមូលទិន្នន័យ ដោយបានប្រើ standard t-test និងANOVA ក្នុងការវិភាគទិន្នន័យ។ ជាលទ្ធផលឃើញ

ថា  កត្តាសេដ្ឋកិច្ចសង្គម  និងការអប់រំរបស់មាតាបិតារបស់សិស្ស  ជាកត្តាដែលបានជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្ស។ ហើយសិស្សស្រីទទួលឥទ្ធិពលច្រើនជាងសិស្សប្រុស។

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

ក្នុងការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានជ្រើសរើសប្រជាជន (សិស្សអនុវិទ្យាល័យគោកព្រីង) ដើម្បីឆ្លើយនឹងសំណួរពហុជ្រើសរើស ដែលមានចំនួន ៣០០ ច្បាប់។ ក្នុងនោះ អ្នកស្រាវជ្រាវបានជ្រើសរើសសាលារៀនជំនាន់ថ្មី (អនុវិទ្យាល័យគោកព្រីង) ធ្វើជាភាគសំណាក។

## ៣.១ ប្រជាជន និងភាគសំណាក

### ៣.១.១ ប្រជាជន

សាលារៀនជំនាន់ថ្មី គឺជាសាលាដែលស្ថិតនៅក្នុងភូមិស្វាយព្រហួត ឃុំគោកព្រីង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ សាលារៀនជំនាន់ថ្មី (អនុវិទ្យាល័យគោកព្រីង) ត្រូវបានបង្កើតឡើងដោយសេចក្ដីប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡានៃព្រះរាជាណាចក្រកម្ពុជា។

សាលារៀនជំនាន់ថ្មីគោកព្រីង នៅឆ្នាំសិក្សា២០១៨-០១៩ មានសិស្សសរុបចំនួន៖ ៣៣៣នាក់ ស្រីចំនួន៖ ១៥៦នាក់ ហើយមានលោកគ្រូ អ្នកគ្រូសរុបចំនួន៖ ២៤នាក់ ស្រីចំនួន៖ ០៨នាក់។ ក្នុងនោះ អ្នកសិក្សាស្រាវជ្រាវ បានជ្រើសរើសប្រជាជនៈ សិស្សសាលាជំនាន់ថ្មី (អនុវិទ្យាល័យគោកព្រីង) សរុបៈ ៣០០ នាក់ ស្រីៈ ១៤៦នាក់ ដោយសារជៀសវាងក្រែងមានសិស្ស អវត្តមាន និងសិស្សបោះបង់ ដែលជាហេតុធ្វើឲ្យមានការពិបាកក្នុងការប្រមូលទិន្នន័យ។

### ៣.១.២ ភាគសំណាក

ក្នុងការជ្រើសរើសភាគសំណាកនេះ អ្នកស្រាវជ្រាវ បានជ្រើសរើសសាលារៀនជំនាន់ថ្មី(អនុវិទ្យាល័យគោកព្រីង) ធ្វើជាភាគសំណាក។ សាលារៀនជំនាន់ថ្មីគោកព្រីង មានថ្នាក់សរុបចំនួន៖ ៩ថ្នាក់ រួមមាន៖

**តារាងទី២៖ ស្ថិតិ សិស្ស ថ្នាក់ នៃអនុវិទ្យាល័យគោកព្រីង**

| ឈ្មោះសាលា | ថ្នាក់ទី៧ | | | ថ្នាក់ទី៨ | | | ថ្នាក់ទី៩ | | | សរុបរួម | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| អនុវិទ្យាល័យ គោកព្រីង | ថ្នាក់ | សិស្ស | | ថ្នាក់ | សិស្ស | | ថ្នាក់ | សិស្ស | | ថ្នាក់ | សិស្ស | |
| | | សរុប | ស្រី | | សរុប | ស្រី | | សរុប | ស្រី | | សរុប | ស្រី |
| | ០៣ | ៩៣ | ៥១ | ០៣ | ៩៧ | ៥១ | ០៣ | ១០៩ | ៤៤ | ០៩ | ៣០០ | ១៤៦ |
| សរុប | ០៣ | ៩៣ | ៥១ | ០៣ | ៩៧ | ៥១ | ០៣ | ១០៩ | ៤៤ | ០៩ | ៣០០ | ១៤៦ |

នៅក្នុងការជ្រើសរើសភាគសំណាកនេះដែរ អ្នកសិក្សាស្រាវជ្រាវ បានកំណត់យកសិស្សសរុបតែ ៣០០ នាក់ ស្រីៈ ១៤៦ នាក់ប៉ុណ្ណោះ ដោយសារផ្អែកលើសិស្សបោះបង់ និងសិស្សអវត្តមានក្នុងពេលសិក្សា ដើម្បីកុំឲ្យពិបាកក្នុងការប្រមូលទិន្នន័យ។

ការជ្រើសរើសយកសិស្សនៅសាលាជំនាន់ថ្មីនេះ អ្នកសិក្សាស្រាវជ្រាវយល់ឃើញថា សាលារៀន ជំនាន់ថ្មី គឺជាសាលាដែលបង្កើតនូវគំរូអភិវឌ្ឍថ្មីនៅក្នុងប្រព័ន្ធអប់រំសាធារណៈស្វយ័ត ដែលមាន គណនេយ្យភាព និងអភិបាលកិច្ចល្អ ព្រមទាំងស្តង់ដារវិជ្ជាជីវៈសម្រាប់ការសិក្សានៅក្នុងសតវត្សន៍ទី២១ ដូច្នេះព័ត៌មានដែលទទួលបានជាព័ត៌មានដែលពិត និងយកជាការបាន។

## ៣.២ ឧបករណ៍នៃការស្រាវជ្រាវ

ចំពោះឧបករណ៍ស្រាវជ្រាវដែលត្រូវយកមកប្រើ អ្នកស្រាវជ្រាវបានដកស្រង់កម្រងសំណួរជ្រើសរើស ចំនួន ៥២ចំណុច ចែកជា ៤ផ្នែក ដែលផ្នែកទី១៖ កត្តាសិស្ស មាន ១០ ចំណុច ចាប់ពី ១ ដល់១០ ។ ផ្នែក ទី២៖ កត្តាគ្រួសារ មានចំនួនៈ ១១ ចំណុច ចាប់ពី ១១ ដល់ ២១ ។ ផ្នែកទី៣៖ កត្តាសាលារៀន មានចំនួ នៈ ២០ ចំណុច ចាប់ពី ២២ ដល់ ៤១ ។ ផ្នែកទី៤៖ កត្តាសង្គម មានចំនួនៈ ១១ ចំណុច ចាប់ពី ៤២ រហូត ដល់ ៥២។ ដោយយកលំនាំតាមប្រភេទកម្រងសំណួរនៃនិក្ខេបបទរបស់ លោក *Richard A. LaBontee, Jr (2019)* ដែលនិក្ខេបបទរបស់លោកមាន ៦៩ ចំណុច ចែកចេញជា ៧ផ្នែក។ ការយកកម្រងសំណួរ ប្រភេទនេះមកប្រើ អ្នកស្រាវជ្រាវបានធ្វើការរៀបចំ និងកែសម្រួលដើម្បីឲ្យស៊ីនឹងបរិបទប្រទេស កម្ពុជា។ ក្នុង កិច្ចដំណើរការនៃការចងក្រងកម្រងសំណួរនេះ អ្នកសិក្សាបានធ្វើការផ្ទៀងផ្ទាត់យ៉ាងល្អិតល្អន់ ព្រមទាំងស្ថិត ក្រោមការត្រួតពិនិត្យ និងឯកភាព ដោយផ្ទាល់ពីសាស្ត្រាចារ្យ ដឹកនាំ និងសាស្ត្រាចារ្យដឹកនាំរង យ៉ាងយក ចិត្តទុកដាក់បំផុត។

ដើម្បីឲ្យការប្រមូលទិន្នន័យមានភាពងាយស្រួល និងមានភាពជាក់លាក់ អ្នកសិក្សាស្រាវជ្រាវបាន បង្កើតទម្រង់កម្រងសំណួរស្រាវជ្រាវសម្រាប់សិស្សានុសិស្ស ដែលមានបែងចែកជា ពីរផ្នែកគឺ៖ ព័ត៌មាន ទូទៅ និងកម្រងសំណួរជ្រើសរើស។

**ផ្នែកទី១៖** ព័ត៌មានទូទៅចែកជា ៦ចំណុចគឺ (១)ឈ្មោះរាជធានី ខេត្ត (២)ឈ្មោះស្រុក ខណ្ឌ (៣) ឈ្មោះសាលា (៤)ថ្នាក់ទី និង(៦)ភេទ ។

**ផ្នែកទី២៖** ជាកម្រងសំណួរជ្រើសរើសដែលមានចំនួន ៥២សំណួរ ដែលតម្រូវឲ្យសិស្សជ្រើសរើស តាមការណែនាំ និងរបៀបនៃការធីកក្នុងប្រអប់ (✓) លើចំណុចណាដែលគេយល់ថាសមស្រប និងត្រឹមត្រូវ

នៃសកម្មភាព និងខ្លឹមសារនីមួយៗដែលមានលេខតំណាងពី១ ដល់៥ គឺ ១ = គ្មានសោះ ២ = មានតិចតួច ៣ = មានជាមធ្យម ៤ = មានខ្លាំង និង៥ = មានខ្លាំងណាស់ ។

## ៣.៣ ដំណើរការនៃការប្រមូលទិន្នន័យ

បន្ទាប់ពីទទួលការណែនាំពីលោកគ្រូដឹកនាំ និងគ្រូដឹកនាំរង ព្រមទាំងទទួលបានលិខិតឧទ្ទេសនាមពីវិទ្យាស្ថានជាតិអប់រំ លេខ៖ ១១៩ វជអ.ផក ចុះថ្ងៃសុក្រ ១៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការចាត់តាំងនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ នៃវិទ្យាស្ថានជាតិអប់រំ ឲ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ គ្រប់គ្រងអប់រំ នៅតាមរាជធានី-ខេត្តនានា ក្នុងព្រះរាជាណាចក្រកម្ពុជា។ ដោយយោងលិខិតជូនដំណឹងរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ៖ ១៨៨៥ អយក.វជអ ចុះថ្ងៃព្រហស្បត្តិ៍ ១៤ កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ស្តីពីការស្នើទៅមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តនានា ដើម្បីជួយសម្រួលដល់ការចុះស្រាវជ្រាវប្រមូលទិន្នន័យ នៅតាមរាជធានី-ខេត្តនានា។ មូលហេតុនៃការស្នើសុំទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង ដោយសារសាលាជំនាន់ថ្មី ស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត។ បន្ទាប់ពីទទួលបានការឆ្លើយតបពីមន្ទីរអប់រំ យុវជន និងកីឡា ស្វាយរៀង។ បន្ទាប់ពីទទួលបានការឆ្លើយតបពី មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង តាមរយៈកំណត់បង្ហាញ ចុះថ្ងៃចន្ទ ៩រោច ខែពិសាខ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩ស្តីពីការសម្រួលដល់ការចុះប្រមូលទិន្នន័យ តាមសាលានានាក្នុងខេត្តស្វាយរៀង។ អ្នកសិក្សាស្រាវជ្រាវបានជួបលោកប្រធានមន្ទីរមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង ដើម្បីអនុញ្ញាតចុះប្រមូលទិន្នន័យនៅសាលាជំនាន់ថ្មី។ ក្នុងពេលដែលជួបលោកប្រធានមន្ទីរ លោកមានការទទួលដោយក្តីរីករាយ ព្រមទាំងបានផ្តល់នូវយុទ្ធសាស្ត្រមួយចំនួនក្នុងការទំនាក់ទំនងជាមួយលោក នាយកលោកគ្រូ អ្នកគ្រូដើម្បីទទួលបានព័ត៌មានឲ្យបានគ្រប់ជ្រុងជ្រោយ។ លោកប្រធានមន្ទីរបានចុះហត្ថលេខាអនុញ្ញាតឲ្យចុះប្រមូលទិន្នន័យនៅសាលារៀនជំនាន់ថ្មីគោកព្រីងដោយក្តីរីករាយ និងភាពកក់ក្តៅបំផុត។ បន្ទាប់ពីអ្នកស្រាវជ្រាវបានការអនុញ្ញាតពីលោកប្រធានមន្ទីររួចមក អ្នកស្រាវជ្រាវបានយកលិខិតអនុញ្ញាតធ្វើដំណើរទៅសាលារៀនជំនាន់ថ្មី។ សាលារៀនជំនាន់ថ្មី ស្ថិតនៅភូមិស្វាយប្រហួត ឃុំគោកព្រីង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ដែលមានចមម្ងាយ ៨.៥ គីឡូម៉ែតពីផ្លូវជាតិលេខ១។ នៅពេលអ្នកស្រាវជ្រាវបានមកដល់បរិវេននៃសាលាជំនាន់ថ្មី អ្នកសិក្សាស្រាវជ្រាវបានការទទួលស្វាគមន៍ពីសំណាក់លោកនាយកលោកគ្រូអ្នកគ្រូដោយភាពរួសរាយ និងស្និទ្ធស្នាលបំផុត។

មុនការចុះប្រមូលទិន្នន័យជាផ្លូវការ អ្នកសិក្សាស្រាវជ្រាវបានរៀបចំសាកល្បងលើកម្រងសំណួរទាំងអស់នៅសាលាមួយក្នុងខេត្តស្វាយរៀង។ គោលបំណងនៃការសាកល្បងកម្រងសំណួរនេះ គឺដើម្បីធានាអំពី ប្រសិទ្ធភាព និងភាពពិតប្រាកដនៃកម្រងសំណួរ ដើម្បីឲ្យប្រាកដថា ការប្រមូលទិន្នន័យនេះអាចយកជាផ្លូវការបាន ឬមិនបាន។ ក្រោយពីការសាកល្បងលើកម្រងសំណួរទាំងអស់រួចមក អ្នកសិក្សាស្រាវជ្រាវសង្កេតឃើញថា ការសាកល្បងនេះពិតជាទទួលបានលទ្ធផលល្អ ព្រោះយើងឃើញមានចំណុចខ្វះខាតមួយចំនួនរបស់កម្រងសំណួរ។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវបានយកបញ្ហាទាំងនោះ ទៅពិភាក្សាជាមួយសាស្ត្រាចារ្យដឹកនាំ ដើម្បីកែលម្អឡើងវិញ។ បន្ទាប់ពីទទួលបានការណែនាំ កែលម្អ និងឯកភាពពីសាស្ត្រាចារ្យដឹកនាំរួចមក អ្នកសិក្សាស្រាវជ្រាវក៏ចាប់ផ្តើមចុះប្រមូលទិន្នន័យតែម្តង។

ក្នុងការចុះប្រមូលទិន្នន័យ អ្នកស្រាវជ្រាវ បានពន្យល់ពីគោលបំណងនៃការប្រមូលទិន្នន័យដល់លោកនាយកសាលារួចបានចុះប្រមូលទិន្នន័យតាមថ្នាក់ គឺថ្នាក់ទី៧ ថ្នាក់ទី៨ និងថ្នាក់ទី៩ ។ មុននឹងចែកកម្រងសំណួរ អ្នកស្រាវជ្រាវបានធ្វើការណែនាំពីគោលបំណង និងវិធីបំពេញកម្រងសំណួរដល់សិស្សានុសិស្ស ក្នុងនោះអ្នកស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរចំនួនៈ ៣០០ច្បាប់សម្រាប់សិស្សដើម្បីបំពេញ ។

## ៣.៤ ការវិភាគទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រវិភាគទិន្នន័យតាមបែប រិមាណវិស័យ។ ទិន្នន័យបែបបរិមាណវិស័យដែលប្រមូលបានពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាដំបូងត្រូវវិភាគដាច់ដោយឡែកទៅតាមប្រភេទសំណាកនីមួយៗ ( សិស្សតាមកម្រិតថ្នាក់ និងភេទ)។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវសំយោគបញ្ចូលគ្នាដោយផ្តោតសំខាន់ទៅលើកត្តាដែលជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី។ ដើម្បីឆ្លើយតបនឹងចំណុចនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្មវិធី SPSS ដើម្បីវិភាគទៅលើ (Mean, Standard Deviation, One Sample T-Test and One-way ANOVA) សម្រាប់វិភាគមធ្យម គម្លាតស្តង់ដា អត្ថន័យ និងចាត់តាមលំដាប់ថ្នាក់នីមួយៗ ព្រមទាំងប្រើវិធីក្នុងការប្រៀបធៀប តាមភេទ និងកម្រិតថ្នាក់ ដើម្បីរកឲ្យឃើញនូវភាពខុសគ្នា និងដូចគ្នាទៅតាមប្រភេទនីមួយៗ។

## ៣.៥ ក្រមសីលធម៌នៃការស្រាវជ្រាវ

ការប្រកាន់ខ្ជាប់នូវក្រមសីលធម៌មានសារៈសំខាន់ណាស់ សម្រាប់អ្នកសិក្សាស្រាវជ្រាវក្នុងការធានាប្រសិទ្ធភាពនៃការស្រាវជ្រាវក៏ដូចជាបង្កើននូវទំនុកចិត្ត និងភាពជឿជាក់ដល់អ្នកចូលរួមផ្តល់ចម្លើយ ក៏ដូច

ជាទិន្នន័យផ្សេងៗសម្រាប់ប្រើប្រាស់ក្នុងកិច្ចការស្រាវជ្រាវនេះផងដែរ។ ការព្រមព្រាងគ្នារវាងអ្នកចូលរួមផ្តល់ព័ត៌មានលើកម្រងសំណួរ និងអ្នកដែលស្វែងរកប្រភពព័ត៌មានច្បាស់លាស់ និងមានប្រសិទ្ធភាព ហើយអាចយកមកប្រើការបានសម្រាប់ធ្វើការវិភាគស៊ីជម្រៅ។ អត្តសញ្ញាណរបស់អ្នកផ្តល់ចម្លើយត្រូវបានរក្សាការសំងាត់លើកលែងតែឈ្មោះសាលារៀនដែលត្រូវបានបង្ហាញ ក៏មានការឯកភាពពីនាយកសាលាគោលដៅនីមួយៗ អ្នកសិក្សាស្រាវជ្រាវបាននាំយកនូវលិខិតអនុញ្ញាតទៅជាមួយ ហើយសុំការអនុញ្ញាតពីភាគីពាក់ព័ន្ធ ដោយចាប់ផ្តើមមុនពេលបំពេញកម្រងសំណួរ។ ការចូលរួមសហការរបស់គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ ក្នុងការផ្តល់ឱកាសឲ្យអ្នកស្រាវជ្រាវចុះធ្វើកម្រងសំណួរតាមថ្នាក់ មានន័យថា អ្នកពាក់ព័ន្ធទាំងនោះយល់នូវគោលបំណង នៃការស្រាវជ្រាវជាមុន ហើយអ្នកស្រាវជ្រាវក៏រំពឹងផងដែរថានឹងទទួលបានចម្លើយ ឬព័ត៌មានដែលពិត។ ការធ្វើដូច្នេះ ធ្វើឱ្យអ្នកសិក្សាស្រាវជ្រាវមានទំនុកចិត្ត និងមានភស្តុតាងបញ្ជាក់ពីការចុះទៅប្រមូលទិន្នន័យរបស់ខ្លួនដោយស្របច្បាប់។

# ជំពូកទី ៤

# លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងធ្វើការបង្ហាញ បកស្រាយ និងការវិភាគទិន្នន័យដែលបានមកពីការបំពេញកម្រងសំណួរ ដើម្បីឲ្យដឹងថា តើអ្វីខ្លះដែលជាកត្តាដែលជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី និងកម្រិតនៃការយល់ដឹងរបស់សិស្សអំពីគុណភាពនៃការសិក្សាតាមកម្រិតថ្នាក់ និងភេទរបស់សិស្សដើម្បីរកវិធីដោះស្រាយ និងពង្រឹងគុណភាពក្នុងការសិក្សារបស់សិស្សនាពេលបច្ចុប្បន្ន និងពេលអនាគត។

## ៤.១ លទ្ធផលនៃការស្រាវជ្រាវសំណួរទី១៖ តើអ្វីខ្លះដែលជាកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី?

នៅក្នុងសំណួរទី១នេះ អ្នកស្រាវជ្រាវចង់ដឹងពីកត្តាដែលបានជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី (អនុវិទ្យាល័យគោកព្រីង) ក្នុងចំណោមសិស្សចំនួន៖ ៣០០នាក់ ស្រីចំនួន៖ ១៥៦នាក់ ដែលមាន៖ ៩ថ្នាក់ គឺថ្នាក់ទី៧ មាន ០៣ថ្នាក់ ថ្នាក់ទី៨ មាន ០៣ថ្នាក់ និងថ្នាក់ទី៩ មាន ០៣ថ្នាក់។

ឧបករណ៍ស្រាវជ្រាវ អ្នកស្រាវជ្រាវបានប្រើកម្រងសំណួរជ្រើសរើសដែលមានចំនួន ៥២ ចំណុច ហើយបានបែងចែកជា ៤ ផ្នែកគឺ ផ្នែកទី១៖ កត្តាសិស្ស (មាន១០ ចំណុច ចាប់ពី ១ ដល់ ១០) ផ្នែកទី២៖ កត្តាគ្រួសារ (មាន ១១ចំណុច ចាប់ពី ១១ ដល់ ២១ ) ផ្នែកទី៣៖ កត្តាសាលារៀន (មាន ២០ចំណុច ចាប់ពី ២២ដល់ ៤១ ) និងផ្នែកទី៤៖ កត្តាសហគមន៍ (មាន ១១ចំណុច ចាប់ពី៤២ ដល់៥២)។

ស្ថិតិដែលបានប្រើក្នុងការវិភាគរួមមាន មធ្យមភាគ(Mean) កម្លាតស្តង់ដា(Standard deviation) ដើម្បីបង្ហាញឲ្យឃើញកម្រិតនៃកត្តាដែលបានជះឥទ្ធិពលនៃគុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី។ ដោយយោងតាម ការបែងចែកកម្រិតដែលចងក្រងដោយ Oxford និងBurry-Stock (1995) កម្រិតមធ្យមត្រូវបានគេបែងចែកជា បីក្រុម គឺ កម្រិតខ្ពស់ ( 3.50 ឡើង ) កម្រិតមធ្យម( M=2.50 – 3.49 ) និងកម្រិតទាប ( M=2.49 ចុះ )។

**តារាងទី៣៖ មធ្យម គម្លាតស្តង់ដា អត្ថន័យ និង លំដាប់កម្រិតនៃកត្តាដែលជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី** ( N=៣០០ )។

| ល.រ | ខ្លឹមសារ | កម្រិតការអនុវត្ត | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | សិស្សមានស្មារតីឧស្សាហ៍ព្យាយាមប្រឹងប្រែងរៀនសូ | 4.13 | 1.16 | ខ្ពស់ | 1 |

| | | | | | |
|---|---|---|---|---|---|
| | ត្រ។ | | | | |
| ២ | ជួយធ្វើកិច្ចការផ្ទះ។ | 3.07 | 1.22 | មធ្យម | 35 |
| ៣ | មានគោលដៅច្បាស់លាស់ក្នុងការសិក្សា។ | 3.91 | 1.23 | ខ្ពស់ | 8 |
| ៤ | ជួយមើលថែប្អូននៅផ្ទះ។ | 2.80 | 1.29 | មធ្យម | 39 |
| ៥ | ពុះពារគ្រប់ឧបសគ្គ។ | 3.67 | 3.23 | ខ្ពស់ | 20 |
| ៦ | ការរលឹកត្រូវ (ការគិតបានត្រឹមត្រូវ)។ | 3.35 | 1.31 | មធ្យម | 33 |
| ៧ | សេពគ្រឿងញៀន។ | 2.41 | 1.68 | ទាប | 48 |
| ៨ | ការដើរលេង និងមានមិត្តភក្តិច្រើន។ | 2.47 | 1.32 | ទាប | 47 |
| 9 | តំណពូជ (បងប្អូន ឪពុកម្តាយមិនបានទទួលការសិក្សា) ។ | 2.50 | 1.37 | មធ្យម | 46 |
| ១០ | មានការតាំងចិត្តខ្ពស់ក្នុងការសិក្សារៀនសូត្រ។ | 3.84 | 1.35 | ខ្ពស់ | 12 |
| ១១ | គ្រួសារក្រីក្រ។ | 2.62 | 1.29 | មធ្យម | 42 |
| ១២ | ការចំណាកស្រុករបស់គ្រួសារ។ | 2.53 | 1.37 | មធ្យម | 44 |
| ១៣ | គំនាបគ្រួសារ (មិនផ្តល់ឱកាសឲ្យកូនបានចូលរៀន)។ | 2.36 | 1.50 | ទាប | 51 |
| ១៤ | ខ្វះភាពកក់ក្តៅ (ឪពុក ម្តាយរវល់ការងារ)។ | 2.58 | 1.38 | មធ្យម | 43 |
| ១៥ | គ្មានការលើកទឹកចិត្តពីក្រុមគ្រួសារ។ | 2.53 | 1.45 | មធ្យម | 44 |
| ១៦ | ការរើសអើង (កូនស្រីមិនបាច់ចូលរៀន)។ | 2.40 | 1.56 | ទាប | 49 |
| ១៧ | អំពើហឹង្សាក្នុងគ្រួសារ។ | 2.32 | 1.49 | ទាប | 52 |
| ១៨ | គ្មានមធ្យោបាយធ្វើដំណើរ។ | 2.39 | 1.31 | ទាប | 50 |
| ១៩ | គ្រួសារខ្វះលទ្ធភាពឲ្យកូនទៅរៀន | 2.73 | 1.25 | មធ្យម | 40 |
| ២០ | គ្រួសារជាអ្នកមាន។ | 2.71 | 1.24 | មធ្យម | 41 |
| ២១ | ប្រាក់វិភាគទានពីឪពុកម្តាយសិស្ស។ | 3.40 | 1.34 | មធ្យម | 32 |
| ២២ | នាយកសាលាដឹកនាំបានល្អ។ | 3.93 | 1.30 | ខ្ពស់ | 5 |
| ២៣ | នាយកសាលាមានគណនេយ្យភាពក្នុងការដឹកនាំ និងគ្រប់គ្រង។ | 3.93 | 1.29 | ខ្ពស់ | 5 |
| ២៤ | បរិស្ថានសាលាល្អ។ | 3.75 | 1.56 | ខ្ពស់ | 18 |
| ២៥ | សាលាមានសួនច្បារ និងសួនជីវចំរុះ។ | 3.53 | 1.44 | ខ្ពស់ | 28 |
| ២៦ | សាលាមានអាគារសិក្សាគ្រប់គ្រាន់ និងទំនើបៗ។ | 3.60 | 1.45 | ខ្ពស់ | 24 |
| ២៧ | គ្រូបង្រៀនប្រកបដោយ ចំណេះដឹង សមត្ថភាពខ្ពស់ | 3.91 | 1.46 | ខ្ពស់ | 8 |
| ២៨ | គ្រូបង្រៀនមានភាពរួសរាយ រាក់ទាក់ សុភាពរាបសា | 3.77 | 1.36 | ខ្ពស់ | 16 |

| | | | | | |
|---|---|---|---|---|---|
| | ប្រកបដោយស្នាមញញឹម។ | | | | |
| ២៩ | មានសម្ភារៈសិក្សាគ្រប់គ្រាន់។ | 3.70 | 1.35 | ខ្ពស់ | 19 |
| ៣០ | សាលាមានបណ្ណាល័យសម្រាប់អានសៀវភៅ។ | 3.79 | 1.45 | ខ្ពស់ | 15 |
| ៣១ | កម្មវិធីសិក្សាច្បាស់លាស់ និងត្រូវទៅតាមកម្រិតថ្នាក់របស់សិស្ស។ | 3.64 | 1.39 | ខ្ពស់ | 22 |
| ៣២ | មានសៀវភៅសិក្សាគោលគ្រប់គ្រាន់។ | 3.76 | 1.37 | ខ្ពស់ | 17 |
| ៣៣ | មានក្លឹបសិក្សា (សម្រាប់ជួយបំប៉នសិស្សខ្សោយ)។ | 3.67 | 1.39 | ខ្ពស់ | 20 |
| ៣៤ | មានការប្រឡងដើម្បីបានចូលរៀននៅសាលជំនាន់ថ្មី។ | 3.89 | 1.31 | ខ្ពស់ | 10 |
| ៣៥ | ការសិក្សាជាក្រុម។ | 3.57 | 1.33 | ខ្ពស់ | 26 |
| ៣៦ | ធ្វើតេស្តស្តង់ដា(ប្រចាំខែ ឆមាស និងដំណាច់ឆ្នាំ)។ | 3.93 | 1.26 | ខ្ពស់ | 5 |
| ៣៧ | ការចូលរួមសកម្មភាពនានាក្នុង និងក្រៅថ្នាក់។ | 3.52 | 1.24 | ខ្ពស់ | 29 |
| ៣៨ | ទស្សនកិច្ចសិក្សា។ | 3.52 | 1.31 | ខ្ពស់ | 29 |
| ៣៩ | គ្រូត្រូវប្រឡងចូលដើម្បីបានបង្រៀននៅសាលាជំនាន់ថ្មី។ | 4.06 | 1.18 | ខ្ពស់ | 2 |
| ៤០ | គ្រូ និងសិស្សប្រើប្រាស់កុំព្យូទ័រ tablets និងស្លាយដើម្បីរៀន និង បង្រៀន។ | 4.03 | 1.27 | ខ្ពស់ | 3 |
| ៤១ | មានការអប់រំសុខភាព និងកីឡា។ | 3.80 | 1.74 | ខ្ពស់ | 14 |
| ៤២ | ភូមិ ឃុំមានសុវត្ថិភាព។ | 3.61 | 1.41 | ខ្ពស់ | 23 |
| ៤៣ | គ្មានល្បែងស៊ីសង។ | 2.99 | 1.55 | មធ្យម | 37 |
| ៤៤ | ភូមិនៅជិតសាលា។ | 3.12 | 1.36 | មធ្យម | 34 |
| ៤៥ | គ្មានអំពើហឹង្សា ចោរកម្ម ។ | 3.00 | 2.68 | មធ្យម | 36 |
| ៤៦ | គ្មានការជួញដូរស្ត្រី និងកុមារ។ | 2.84 | 1.58 | មធ្យម | 38 |
| ៤៧ | សហគមន៍មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់។ | 3.55 | 1.33 | ខ្ពស់ | 27 |
| ៤៨ | មានសេវាបម្រើប្រជាពលរដ្ឋល្អ។ | 3.43 | 1.35 | មធ្យម | 31 |
| ៤៩ | ការចូលរួមបដិភាគក្នុងការកសាង និងអភិវឌ្ឍសាលារៀនពីមាតាបិតាសិស្ស។ | 3.88 | 1.28 | ខ្ពស់ | 11 |
| ៥០ | ចូលរួមគាំទ្រពីអង្គការនានា។ | 3.81 | 1.26 | ខ្ពស់ | 13 |
| ៥១ | ការគាំទ្រពីក្រសួងអប់រំ។ | 4.01 | 1.20 | ខ្ពស់ | 4 |
| ៥២ | សេវាថែរក្សាសុខភាពល្អ។ | 3.58 | 1.32 | ខ្ពស់ | 25 |
| **សរុប** | | **3. 34** | **1.43** | **មធ្យម** | |

យោងតាមតារាងខាងលើបង្ហាញថា កត្តាដែលបានជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សនៅសាលារៀនជំនាន់ថ្មីចាប់ពីកម្រិតខ្ពស់ ពី ៤.១៣ រហូតដល់កម្រិតទាប ២.៣២។ មានន័យថា ចំណុច ១៖ សិស្សមានស្មារតីឧស្សាហ៍ព្យាយាមប្រឹងប្រែងរៀនសូត្រ គឺមានកម្រិតខ្ពស់ ៤.១៣ (M= 4.13) បន្ទាប់មកទៀត គឺ ចំណុច ៣៩៖ គ្រូត្រូវប្រឡងចូលដើម្បីបានបង្រៀននៅសាលាជំនាន់ថ្មី គឺ មានកម្រិតខ្ពស់ ៤.០៦ (M= 4.06) និងកម្រិតខ្ពស់ចុងក្រោយគឺចំណុច ៤០៖ គ្រូ និងសិស្សប្រើប្រាស់កុំព្យូទ័រ tablets និងស្លាយដើម្បីរៀន និង បង្រៀន មានកម្រិតខ្ពស់ ៤.០៣ (M= 4.03) ។ តារាងខាងលើក៏បានបង្ហាញផងដែរពី កម្រិតទាបបំផុត រួមមានចំណុច ១៤៖ គ្មានមធ្យោបាយធ្វើដំណើរ មានកម្រិតទាប ២.៣៩ ( M= 2.39 ) បន្ទាប់មកចំណុច ១៣៖ គំនាបគ្រួសារ (មិនផ្តល់ឱកាសឲ្យកូនបានចូលរៀន) មានកម្រិតទាប ២.៣៦ ( M= 2.36 ) និងចំណុចចុងក្រោយដែលមានកម្រិតទាបបំផុតគឺ ចំណុច ១៧៖ អំពើហឹង្សាក្នុងគ្រួសារ ដែលមានកម្រិត ២.៣២ ( M= 2.32 ) ។

ជារួមតារាងខាងលើបង្ហាញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី គឺចំណុចទី១៖ សិស្សមានស្មារតីឧស្សាហ៍ព្យាយាមប្រឹងប្រែងរៀនសូត្រ ចំណែកឯកកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀន មានកម្រិតទាបគឺចំណុចទី១៧៖ អំពើហឹង្សាក្នុងគ្រួសារ ដែលមានកម្រិតទាបបំផុត។

នៅតារាងបន្ទាប់អ្នកស្រាវជ្រាវ នឹងធ្វើការបង្ហាញពីកម្រិត នៃកត្តាដែលបានជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី ដើម្បីឲ្យដឹងពី កម្រិតខ្ពស់ និងកម្រិតទាបទៅតាមផ្នែកនីមួយៗ។

អ្នកស្រាវជ្រាវចង់ដឹងពីកម្រិតនៃកត្តាដែលបានជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី ចំនួន ៣០០នាក់ ស្រី ១៥៦ នាក់ ដែលមាន ០៩ ថ្នាក់ ពោលគឺថ្នាក់ទី៧ មាន ០៣ ថ្នាក់ ថ្នាក់ទី៨ មាន ០៣ ថ្នាក់ និង ថ្នាក់ទី៩ មាន ០៣ ថ្នាក់ របស់សាលាជំនាន់ថ្មី (អនុវិទ្យាល័យគោកព្រីង) តាមផ្នែកនីមួយៗ

ឧបករណ៍ស្រាវជ្រាវ អ្នកស្រាវជ្រាវបានប្រើកម្រងសំណួរជ្រើសរើសដែលមានចំនួន ៥២ ចំណុច ហើយបានបែងចែកជា ៤ ផ្នែកគឺ ផ្នែកទី១៖ កត្តាសិស្ស (មាន ១០ ចំណុច ចាប់ពី ១ ដល់ ១០) ផ្នែកទី២៖ កត្តាគ្រួសារ (មាន១១ ចំណុច ចាប់ពី ១១ ដល់ ២១ ) ផ្នែកទី៣៖ សាលារៀន (មាន ២០ ចំណុច ចាប់ពី ២២ ដល់ ៤១ ) និងផ្នែកទី៤៖ កត្តាសហគមន៍ (មាន ១១ ចំណុច ចាប់ពី ៤២ ដល់ ៥២ )។

**តារាងទី៤៖ មធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់កម្រិតនៃការយល់ដឹងពីកត្តាដែលជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សនៅសាលាជំនាន់ថ្មី ចំនួន៣០០នាក់** (N=3០០)។

| ល.រ | ខ្លឹមសារ | កម្រិតការអនុវត្ត | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| **ផ្នែកទី១៖ កត្តាសិស្ស** | | | | | |
| ១ | សិស្សមានស្មារតីឧស្សាហ៍ព្យាយាមប្រឹងប្រែងរៀនសូត្រ។ | 4.13 | 1.16 | ខ្ពស់ | 1 |
| ២ | ជួយធ្វើកិច្ចការផ្ទះ។ | 3.07 | 1.22 | មធ្យម | 35 |
| ៣ | មានគោលដៅច្បាស់លាស់ក្នុងការសិក្សា។ | 3.91 | 1.23 | ខ្ពស់ | 8 |
| ៤ | ជួយមើលថែប្អូននៅផ្ទះ។ | 2.80 | 1.29 | មធ្យម | 39 |
| ៥ | ពុះពារគ្រប់ឧបសគ្គ។ | 3.67 | 3.23 | ខ្ពស់ | 20 |
| ៦ | ការរលឹកត្រូវ (ការគិតបានត្រឹមត្រូវ)។ | 3.35 | 1.31 | មធ្យម | 33 |
| ៧ | សេពគ្រឿងញៀន។ | 2.41 | 1.68 | ទាប | 48 |
| ៨ | ការដើរលេង និងមានមិត្តភក្តិច្រើន។ | 2.47 | 1.32 | ទាប | 47 |
| 9 | តំណពូជ (បងប្អូន ឪពុកម្តាយមិនបានទទួលការសិក្សា)។ | 2.50 | 1.37 | មធ្យម | 46 |
| ១០ | មានការតាំងចិត្តខ្ពស់ក្នុងការសិក្សារៀនសូត្រ។ | 3.84 | 1.35 | ខ្ពស់ | 12 |
| **សរុប** | | **3.21** | **1.51** | **មធ្យម** | 3 |
| **ផ្នែកទី២៖ កត្តាគ្រួសារ** | | | | | |
| ១១ | គ្រួសារក្រីក្រ។ | 2.62 | 1.29 | មធ្យម | 42 |
| ១២ | ការចំណាកស្រុករបស់គ្រួសារ។ | 2.53 | 1.37 | មធ្យម | 44 |
| ១៣ | គំនាបគ្រួសារ (មិនផ្តល់ឪកាសឲ្យកូនបានចូលរៀន)។ | 2.36 | 1.50 | ទាប | 51 |
| ១៤ | ខ្វះភាពកក់ក្តៅ (ឪពុក ម្តាយរវល់ការងារ)។ | 2.58 | 1.38 | មធ្យម | 43 |
| ១៥ | គ្មានការលើកទឹកចិត្តពីក្រុមគ្រួសារ។ | 2.53 | 1.45 | មធ្យម | 44 |
| ១៦ | ការរើសអើង (កូនស្រីមិនបាច់ចូលរៀន)។ | 2.40 | 1.56 | ទាប | 49 |
| ១៧ | អំពើហឹង្សាក្នុងគ្រួសារ។ | 2.32 | 1.49 | ទាប | 52 |
| ១៨ | គ្មានមធ្យោបាយធ្វើដំណើរ។ | 2.39 | 1.31 | ទាប | 50 |
| ១៩ | គ្រួសារខ្វះលទ្ធភាពឲ្យកូនទៅរៀន | 2.73 | 1.25 | មធ្យម | 40 |
| ២០ | គ្រួសារជាអ្នកមាន។ | 2.71 | 1.24 | មធ្យម | 41 |
| ២១ | ប្រាក់វិភាគទានពីឪពុកម្តាយសិស្ស។ | 3.40 | 1.34 | មធ្យម | 32 |
| **សរុប** | | **2.59** | **1. 38** | **មធ្យម** | 4 |
| **ផ្នែកទី៣៖ កត្តាសាលារៀន** | | | | | |

| | | | | | |
|---|---|---|---|---|---|
| ២២ | នាយកសាលាដឹកនាំបានល្អ។ | 3.93 | 1.30 | ខ្ពស់ | 5 |
| ២៣ | នាយកសាលាមានគណនេយ្យភាពក្នុងការដឹកនាំ និងគ្រប់គ្រង។ | 3.93 | 1.29 | ខ្ពស់ | 5 |
| ២៤ | បរិស្ថានសាលាល្អ។ | 3.75 | 1.56 | ខ្ពស់ | 18 |
| ២៥ | សាលាមានសួនច្បារ និងសួនដំរំចំរុះ។ | 3.53 | 1.44 | ខ្ពស់ | 28 |
| ២៦ | សាលាមានអាគារសិក្សាគ្រប់គ្រាន់ និងទំនើបៗ។ | 3.60 | 1.45 | ខ្ពស់ | 24 |
| ២៧ | គ្រូបង្រៀនប្រកបដោយ ចំណេះដឹង សមត្ថភាពខ្ពស់ | 3.91 | 1.46 | ខ្ពស់ | 8 |
| ២៨ | គ្រូបង្រៀនមានភាពរួសរាយ រាក់ទាក់ សុភាពរាបសា ប្រកបដោយស្នាមញញឹម។ | 3.77 | 1.36 | ខ្ពស់ | 16 |
| ២៩ | មានសម្ភារៈសិក្សាគ្រប់គ្រាន់។ | 3.70 | 1.35 | ខ្ពស់ | 19 |
| ៣០ | សាលាមានបណ្ណាល័យសម្រាប់អានសៀវភៅ។ | 3.79 | 1.45 | ខ្ពស់ | 15 |
| ៣១ | កម្មវិធីសិក្សាច្បាស់លាស់ និងត្រូវទៅតាមកម្រិតថ្នាក់របស់សិស្ស។ | 3.64 | 1.39 | ខ្ពស់ | 22 |
| ៣២ | មានសៀវភៅសិក្សាគោលគ្រប់គ្រាន់។ | 3.76 | 1.37 | ខ្ពស់ | 17 |
| ៣៣ | មានក្លឹបសិក្សា (សម្រាប់ជួយបំប៉នសិស្សខ្សោយ)។ | 3.67 | 1.39 | ខ្ពស់ | 20 |
| ៣៤ | មានការប្រឡងដើម្បីបានចូលរៀននៅសាលជំនាន់ថ្មី។ | 3.89 | 1.31 | ខ្ពស់ | 10 |
| ៣៥ | ការសិក្សាជាក្រុម។ | 3.57 | 1.33 | ខ្ពស់ | 26 |
| ៣៦ | ធ្វើតេស្តស្ទង់ដា(ប្រចាំខែ ឆមាស និងដំណាច់ឆ្នាំ)។ | 3.93 | 1.26 | ខ្ពស់ | 5 |
| ៣៧ | ការចូលរួមសកម្មភាពនានាក្នុង និងក្រៅថ្នាក់។ | 3.52 | 1.24 | ខ្ពស់ | 29 |
| ៣៨ | ទស្សនកិច្ចសិក្សា។ | 3.52 | 1.31 | ខ្ពស់ | 29 |
| ៣៩ | គ្រូត្រូវប្រឡងចូលដើម្បីបានបង្រៀននៅសាលាជំនាន់ថ្មី។ | 4.06 | 1.18 | ខ្ពស់ | 2 |
| ៤០ | គ្រូ និងសិស្សប្រើប្រាស់កុំព្យូទ័រ tablets និងស្លាយដើម្បីរៀន និង បង្រៀន។ | 4.03 | 1.27 | ខ្ពស់ | 3 |
| ៤១ | មានការអប់រំសុខភាព និងកីឡា។ | 3.80 | 1.74 | ខ្ពស់ | 14 |
| **សរុប** | | **3.76** | **1. 37** | **ខ្ពស់** | **1** |
| **ផ្នែកទី៤៖ កត្តាសហគមន៍** | | | | | |
| ៤២ | ភូមិ ឃុំមានសុវត្ថិភាព។ | 3.61 | 1.41 | ខ្ពស់ | 23 |
| ៤៣ | គ្មានល្បែងស៊ីសង។ | 2.99 | 1.55 | មធ្យម | 37 |
| ៤៤ | ភូមិនៅជិតសាលា។ | 3.12 | 1.36 | មធ្យម | 34 |
| ៤៥ | គ្មានអំពើហឹង្សា ចោរកម្ម ។ | 3.00 | 2.68 | មធ្យម | 36 |
| ៤៦ | គ្មានការជួញដូរស្ត្រី និងកុមារ។ | 2.84 | 1.58 | មធ្យម | 38 |
| ៤៧ | សហគមន៍មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់។ | 3.55 | 1.33 | ខ្ពស់ | 27 |
| ៤៨ | មានសេវាបម្រើប្រជាពលរដ្ឋល្អ។ | 3.43 | 1.35 | មធ្យម | 31 |
| ៤៩ | ការចូលរួមបដិភាគក្នុងការកសាង និងអភិវឌ្ឍសាលារៀនពីមាតាបិតាសិស្ស។ | 3.88 | 1.28 | ខ្ពស់ | 11 |

| | | | | | |
|---|---|---|---|---|---|
| ៥០ | ចូលរួមគាំទ្រពីអង្គការនានា។ | 3.81 | 1.26 | ខ្ពស់ | 13 |
| ៥១ | ការគាំទ្រពីក្រសួងអប់រំ។ | 4.01 | 1.20 | ខ្ពស់ | 4 |
| ៥២ | សេវាថែរក្សាសុខភាពល្អ។ | 3.58 | 1.32 | ខ្ពស់ | 25 |
| **សរុប** | | **3.43** | **1.48** | **មធ្យម** | 2 |
| **សរុបរួម** | | **3.24** | **1.43** | **មធ្យម** | |

តាមតារាងនៃការបែងចែកតាមផ្នែកខាងលើបានបង្ហាញថា លត្ធផលនៃកត្តាដែលបានជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី តាមផ្នែក មានកម្រិតខ្ពស់ចាប់ពី ៣.៧៦ ( M= 3.76 ) កម្រិតមធ្យមមាន ៣.៤២ , ៣.២១ និង ២.៥៩ ( M=3.42 ,M=3.21 ,M=2.59 ) ហើយកម្រិតមធ្យមទាបបំផុត គឺ ២.៥៩ (M=2.59). តាមលទ្ធផលបានបង្ហាញថា ផ្នែកទី៣៖ កត្តាសាលារៀន មានកម្រិតខ្ពស់ ៣.៧៦ (M=3.76) បន្ទាប់មកផ្នែកទី៤៖ កត្តាសហគមន៍ មានកម្រិតមធ្យម គឺមធ្យមកម្រិតខ្ពស់ ៣.៤២ (M=3.42) បន្ទាប់មកទៀតផ្នែកទី១៖ កត្តាសិស្ស មានកម្រិតមធ្យម ៣.២១ (M=3.21) ចំណែកឯផ្នែកទី ២៖ កត្តាគ្រួសារ មានកម្រិតមធ្យម គឺមធ្យមកម្រិតទាប ២.៥៩ (M=2.59) ។

តាមការបង្ហាញបានបញ្ជាក់ថា កត្តាជះឥទ្ធិពលដល់ការសិក្សារបស់សិស្សសាលាជំនាន់ថ្មីមានពីរកម្រិត គឺកម្រិតខ្ពស់ និងកម្រិតមធ្យម ពោលគឺ ផ្នែកទី ៣៖ កត្តាសាលារៀន មានកម្រិតខ្ពស់ ៣.៧៦ (M=3.76) ចំណែកឯផ្នែកទី ៤៖ កត្តាសហគមន៍ មានកម្រិតមធ្យម កម្រិតខ្ពស់ ៣.៤២ (M=3.42) ហើយផ្នែកទី ១៖ កត្តាគ្រួសារ មានកម្រិតមធ្យម កម្រិតទាប ២.៥៩ (M=2.59) ។

នៅក្នុងតារាងខាងក្រោម អ្នកស្រាវជ្រាវនឹងធ្វើការបង្ហាញពី កម្រិតនៃកត្តាជះឥទ្ធិពលដល់ការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី ដោយបង្ហាញពីមធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់នៃផ្នែកនីមួយៗ។

**តារាងទី៥៖ មធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់នៃកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី តាមផ្នែកនីមួយៗ ដែលមានសិស្សចំនួន ៣០០នាក់** ( N=300 )

| ល.រ | ខ្លឹមសារ | កម្រិតការអនុវត្ត | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | |
| ១ | កត្តាសិស្ស | 3.21 | 1.51 | មធ្យម | 3 |
| ២ | កត្តាគ្រួសារ | 2.59 | 1. 38 | មធ្យម | 4 |
| ៣ | កត្តាសាលារៀន | 3.76 | 1. 37 | ខ្ពស់ | 1 |
| ៤ | កត្តាសង្គម | 3.43 | 1.48 | មធ្យម | 2 |
| **សរុប** | | **៣.២៤** | **1.43** | **មធ្យម** | |

តាមតារាងខាងលើបង្ហាញឲ្យឃើញថា ចំណុចទី៣៖ កត្តាសាលារៀន ស្ថិតក្នុងកម្រិតខ្ពស់ គឺ ៣.៧៦ (M=3.76) ចំណែកកម្រិតមធ្យមមាន ៣.៤២ , ៣.២១ និង ២.៥៩ ( M=3.42 ,M=3.21 ,M=2.59 ) ហើយកម្រិតមធ្យមទាបបំផុត គឺ ២.៥៩ (M=2.59). តាមលទ្ធផលបានបង្ហាញថា ផ្នែកទី៣៖ កត្តាសាលារៀន មានកម្រិតខ្ពស់ ៣.៧៦ (M=3.76) បន្ទាប់មកផ្នែកទី៤៖ កត្តាសហគមន៍ មានកម្រិតមធ្យម គឺមធ្យមកម្រិតខ្ពស់ ៣.៤២ (M=3.42) បន្ទាប់មកទៀតផ្នែកទី១៖ កត្តាសិស្ស មានកម្រិតមធ្យម ៣.២១ (M=3.21) ចំណែកឯផ្នែកទី២៖ កត្តាគ្រួសារ មានកម្រិតមធ្យម គឺមធ្យមកម្រិតទាប ២.៥៩ (M=2.59) ។

តាមការបង្ហាញបានបញ្ជាក់ថា កត្តាជះឥទ្ធិពលដល់ការសិក្សារបស់សិស្សសាលាជំនាន់ថ្មីមានពីរកម្រិត គឺកម្រិតខ្ពស់ និងកម្រិតមធ្យម ពោលគឺ ផ្នែកទី ៣៖ កត្តាសាលារៀន មានកម្រិតខ្ពស់ ៣.៧៦ (M=3.76) ចំណែកឯផ្នែកទី ៤៖ កត្តាសហគមន៍ មានកម្រិតមធ្យម កម្រិតខ្ពស់ ៣.៤២ (M=3.42) ហើយផ្នែកទី ១៖ កត្តាគ្រួសារ មានកម្រិតមធ្យម កម្រិតទាប ២.៥៩ (M=2.59) ។

នៅក្នុងតារាងបន្ទាប់ អ្នកស្រាវជ្រាវ នឹងធ្វើការបង្ហាញពី កម្រិតនៃកត្តាជះឥទ្ធិពលដល់ការសិក្សារបស់សិស្សសាលាជំនាន់ថ្មី ដោយបែងចែកទៅតាមភេទនីមួយៗ ។

**តារាងទី៦៖ មធ្យម គម្លាតស្តង់ដានៃកត្តាដែលជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី (អនុវិទ្យាល័យគោកព្រីង) ចំនួន ៣០០ នាក់** (N=300) **ដោយបែងចែកទៅតាមភេទនីមួយៗ**

| ល.រ | ខ្លឹមសារ | ប្រុស | | អត្ថន័យ | លំដាប់ | ស្រី | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | | មធ្យម | គម្លាតស្តង់ដា | | |
| ១. | សិស្សមានស្មារតីឧស្សាហ៍ព្យាយាមប្រឹងប្រែងរៀនសូត្រ។ | 4.06 | 1.24 | ខ្ពស់ | 1 | 4.21 | 1.06 | ខ្ពស់ | 1 |
| ២. | ជួយធ្វើកិច្ចការផ្ទះ។ | 3.12 | 1.20 | មធ្យម | 35 | 3.02 | 1.24 | មធ្យម | 37 |
| ៣. | មានគោលដៅច្បាស់លាស់ក្នុងការសិក្សា។ | 3.91 | 1.22 | មធ្យម | 8 | 3.91 | 1.24 | ខ្ពស់ | 12 |
| ៤. | ជួយមើលថែប្អូននៅផ្ទះ។ | 2.69 | 1.29 | មធ្យម | 41 | 2.90 | 1.30 | មធ្យម | 38 |
| ៥. | ពុះពារគ្រប់ឧបសគ្គ។ | 3.39 | 1.30 | មធ្យម | 30 | 3.97 | 4.42 | ខ្ពស់ | 5 |
| ៦. | ការរលឹកត្រូវ (ការគិតបានត្រឹមត្រូវ)។ | 3.27 | 1.29 | មធ្យម | 33 | 3.45 | 1.33 | មធ្យម | 30 |
| ៧. | សេពគ្រឿងញៀន។ | 2.57 | 1.72 | មធ្យម | 46 | 2.24 | 1.63 | ទាប | 51 |
| ៨. | ការដើរលេង និងមានមិត្តភក្តិច្រើន។ | 2.58 | 1.34 | មធ្យម | 45 | 2.36 | 1.30 | ទាប | 48 |
| 9. | តំណពូជ (បងប្អូន ឪពុកម្តាយមិនបានទទួលការសិក្សា)។ | 2.53 | 1.40 | មធ្យម | 48 | 2.47 | 1.34 | ទាប | 44 |
| ១០. | មានការតាំងចិត្តខ្ពស់ក្នុងការសិក្សារៀនសូត្រ។ | 3.88 | 1.30 | មធ្យម | 10 | 3.80 | 1.40 | ខ្ពស់ | 19 |
| ១១ | គ្រួសារក្រីក្រ។ | 2.70 | 1.30 | មធ្យម | 40 | 2.53 | 1.28 | មធ្យម | 42 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១២ | ការចំណាកស្រុករបស់គ្រួសារ។ | 2.66 | 1.35 | មធ្យម | 43 | 2.39 | 1.38 | ទាប | 46 |
| ១៣ | គំនាបគ្រួសារ (មិនផ្តល់ឱកាសឲ្យកូនបានចូលរៀន)។ | 2.49 | 1.52 | មធ្យម | 49 | 2.23 | 1.48 | ទាប | 52 |
| ១៤ | ខ្វះភាពកក់ក្តៅ (ឪពុក ម្តាយរវល់ការងារ)។ | 2.66 | 1.35 | មធ្យម | 43 | 2.49 | 1.42 | ទាប | 43 |
| ១៥ | គ្មានការលើកទឹកចិត្តពីក្រុមគ្រួសារ។ | 2.68 | 1.44 | មធ្យម | 42 | 2.38 | 1.44 | ទាប | 47 |
| ១៦ | ការរើសអើង (កូនស្រីមិនបាច់ចូលរៀន)។ | 2.40 | 1.54 | ទាប | 51 | 2.40 | 1.59 | ទាប | 45 |
| ១៧ | អំពើហឹង្សាក្នុងគ្រួសារ។ | 2.38 | 1.46 | ទាប | 52 | 2.27 | 1.53 | ទាប | 50 |
| ១៨ | គ្មានមធ្យោបាយធ្វើដំណើរ។ | 2.45 | 1.31 | ទាប | 50 | 2.32 | 1.30 | ទាប | 49 |
| ១៩ | គ្រួសារខ្វះលទ្ធភាពឲ្យកូនទៅរៀន | 2.73 | 1.27 | មធ្យម | 39 | 2.73 | 1.23 | មធ្យម | 41 |
| ២០ | គ្រួសារជាអ្នកមាន។ | 2.55 | 1.18 | មធ្យម | 47 | 2.88 | 1.29 | មធ្យម | 39 |
| ២១ | ប្រាក់វិភាគទានពីឪពុកម្តាយសិស្ស។ | 3.39 | 1.34 | មធ្យម | 30 | 3.42 | 1.35 | មធ្យម | 33 |
| ២២ | នាយកសាលាដឹកនាំបានល្អ។ | 3.93 | 1.29 | ខ្ពស់ | 6 | 3.93 | 1.32 | ខ្ពស់ | 9 |
| ២៣ | នាយកសាលាមានគណនេយ្យភាពក្នុងការដឹកនាំ និងគ្រប់គ្រង។ | 3.92 | 1.26 | ខ្ពស់ | 7 | 3.95 | 1.33 | ខ្ពស់ | 6 |
| ២៤ | បរិស្ថានសាលាល្អ។ | 3.73 | 1.63 | ខ្ពស់ | 14 | 3.77 | 1.49 | ខ្ពស់ | 20 |
| ២៥ | សាលាមានសួនច្បារ និងសួនជីវចំរុះ។ | 3.40 | 1.47 | មធ្យម | 29 | 3.66 | 1.44 | ខ្ពស់ | 24 |
| ២៦ | សាលាមានអាគារសិក្សាគ្រប់គ្រាន់ និងទំនើបៗ។ | 3.57 | 1.47 | ខ្ពស់ | 25 | 3.63 | 1.44 | ខ្ពស់ | 26 |
| ២៧ | គ្រូបង្រៀនប្រកបដោយ ចំណេះដឹង សមត្ថភាពខ្ពស់ | 3.90 | 1.46 | ខ្ពស់ | 9 | 3.92 | 1.46 | ខ្ពស់ | 10 |
| ២៨ | គ្រូបង្រៀនមានភាពរួសរាយ រាក់ទាក់ សុភាពរាបសា ប្រកបដោយស្នាមញញឹម។ | 3.73 | 1.34 | ខ្ពស់ | 14 | 3.82 | 1.39 | ខ្ពស់ | 16 |
| ២៩ | មានសម្ភារៈសិក្សាគ្រប់គ្រាន់។ | 3.59 | 1.34 | ខ្ពស់ | 22 | 3.82 | 1.36 | ខ្ពស់ | 16 |
| ៣០ | សាលាមានបណ្ណាល័យសម្រាប់អានសៀវភៅ។ | 3.74 | 1.45 | ខ្ពស់ | 13 | 3.84 | 1.45 | ខ្ពស់ | 15 |
| ៣១ | កម្មវិធីសិក្សាច្បាស់លាស់ និងត្រូវទៅតាមកម្រិតថ្នាក់របស់សិស្ស។ | 3.58 | 1.37 | ខ្ពស់ | 24 | 3.71 | 1.41 | ខ្ពស់ | 21 |
| ៣២ | មានសៀវភៅសិក្សាគោលគ្រប់គ្រាន់។ | 3.70 | 1.32 | ខ្ពស់ | 16 | 3.82 | 1.42 | ខ្ពស់ | 16 |
| ៣៣ | មានក្លឹបសិក្សា (សម្រាប់ជួយបំប៉នសិស្សខ្សោយ)។ | 3.63 | 1.39 | ខ្ពស់ | 20 | 3.71 | 1.41 | ខ្ពស់ | 21 |
| ៣៤ | មានការប្រឡងដើម្បីបានចូលរៀននៅសាលជំនាន់ថ្មី។ | 3.85 | 1.27 | ខ្ពស់ | 12 | 3.94 | 1.36 | ខ្ពស់ | 8 |
| ៣៥ | ការសិក្សាជាក្រុម។ | 3.59 | 1.32 | ខ្ពស់ | 22 | 3.55 | 1.35 | ខ្ពស់ | 29 |
| ៣៦ | ធ្វើតេស្តស្តង់ដា(ប្រចាំខែ ឆមាស និងដំណាច់ឆ្នាំ)។ | 3.95 | 1.18 | ខ្ពស់ | 4 | 3.90 | 1.36 | ខ្ពស់ | 13 |
| ៣៧ | ការចូលរួមសកម្មភាពនានាក្នុង និងក្រៅថ្នាក់។ | 3.44 | 1.19 | មធ្យម | 27 | 3.62 | 1.29 | ខ្ពស់ | 27 |
| ៣៨ | ទស្សនកិច្ចសិក្សា។ | 3.34 | 1.33 | មធ្យម | 32 | 3.71 | 1.28 | ខ្ពស់ | 21 |
| ៣៩ | គ្រូត្រូវប្រឡងចូលដើម្បីបានបង្រៀននៅសាលាជំនាន់ថ្មី។ | 4.06 | 1.15 | ខ្ពស់ | 1 | 4.07 | 1.21 | ខ្ពស់ | 3 |
| ៤០ | គ្រូ និងសិស្សប្រើប្រាស់កុំព្យូទ័រ tablets និងស្មាយដើម្បីរៀន និងបង្រៀន។ | 4.05 | 1.26 | ខ្ពស់ | 3 | 4.01 | 1.28 | ខ្ពស់ | 4 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៤១ | មានការអប់រំសុខភាព និងកីឡា។ | 3.69 | 2.05 | ខ្ពស់ | 17 | 3.92 | 1.35 | ខ្ពស់ | 10 |
| ៤២ | ភូមិ ឃុំមានសុវត្ថិភាព។ | 3.61 | 1.37 | ខ្ពស់ | 21 | 3.61 | 1.45 | ខ្ពស់ | 28 |
| ៤៣ | គ្មានល្បែងស៊ីសង។ | 2.89 | 1.51 | មធ្យម | 37 | 3.10 | 1.59 | មធ្យម | 34 |
| ៤៤ | ភូមិនៅជិតសាលា។ | 3.13 | 1.34 | មធ្យម | 34 | 3.10 | 1.39 | មធ្យម | 34 |
| ៤៥ | គ្មានអំពើហឹង្សា ចោរកម្ម ។ | 2.93 | 1.46 | មធ្យម | 36 | 3.07 | 3.54 | មធ្យម | 36 |
| ៤៦ | គ្មានការជួញដូរស្ត្រី និងកុមារ។ | 2.80 | 1.56 | មធ្យម | 38 | 2.88 | 1.61 | មធ្យម | 39 |
| ៤៧ | សហគមន៍មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់។ | 3.66 | 1.22 | ខ្ពស់ | 19 | 3.44 | 1.43 | មធ្យម | 32 |
| ៤៨ | មានសេវាបម្រើប្រជាពលរដ្ឋល្អ។ | 3.41 | 1.32 | មធ្យម | 28 | 3.45 | 1.39 | មធ្យម | 30 |
| ៤៩ | ការចូលរួមបដិភាគក្នុងការកសាង និងអភិវឌ្ឍសាលារៀនពីមាតាបិតាសិស្ស។ | 3.88 | 1.26 | ខ្ពស់ | 10 | 3.88 | 1.30 | ខ្ពស់ | 14 |
| ៥០ | ចូលរួមគាំទ្រពីអង្គការនានា។ | 3.68 | 1.25 | ខ្ពស់ | 18 | 3.95 | 1.25 | ខ្ពស់ | 6 |
| ៥១ | ការគាំទ្រពីក្រសួងអប់រំ។ | 3.94 | 1.18 | ខ្ពស់ | 5 | 4.08 | 1.22 | ខ្ពស់ | 2 |
| ៥២ | សេវាថែរក្សាសុខភាពល្អ។ | 3.51 | 1.35 | ខ្ពស់ | 26 | 3.65 | 1.29 | ខ្ពស់ | 25 |
| **សរុប** | | **3.32** | **1.35** | **មធ្យម** | 2 | **3.36** | **1.46** | **មធ្យម** | 1 |

យោងតាមតារាងខាងលើបានបង្ហាញឲ្យឃើញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី របស់សិស្សប្រុស មានកម្រិតខ្ពស់ចាប់ពី ៤.០៦ (M= 4.06) រហូតដល់កម្រិតទាបបំផុត ២.៣៨ (M= 2.38) និងកម្រិតមធ្យម ៣.៣២។ មានន័យថា ចំណុចទី ១៖ សិស្សមានស្មារតីឧស្សាហ៍ព្យាយាមប្រឹងប្រែងរៀនសូត្រមានកម្រិតខ្ពស់ គឺ ៤.០៦ (M=4.06) បន្ទាប់មកចំណុចទី ៣៩ ៖ គ្រូត្រូវប្រឡងចូលដើម្បីបានបង្រៀននៅសាលាជំនាន់ថ្មី មានកម្រិតខ្ពស់ ៤.០៦ (M=4.06) និងកម្រិតខ្ពស់ចុងក្រោយគឺ ចំណុចទី ៤០៖ គ្រូ និងសិស្សប្រើប្រាស់កុំព្យូទ័រ tablets និងស្លាយដើម្បីរៀន និងបង្រៀន មានកម្រិតខ្ពស់ ៤.០៥ (M=4.05) ។ ចំណែកកម្រិតទាប គឺចំណុចទី ១៨៖ គ្មានមធ្យោបាយធ្វើដំណើរ មានកម្រិតទាប ២.៤៥(M=2.45) កម្រិតទាបបន្ទាប់គឺ ចំណុចទី១៦៖ ការរើសអើង (កូនស្រីមិនបាច់ចូលរៀន)មានកម្រិតទាប ២.៤០ (M=240) និងកម្រិតទាបបំផុត គឺចំណុចទី ១៧៖ អំពើហឹង្សាក្នុងគ្រួសារមានកម្រិត ២.៣៨ (M=2.38)។

ចំណែកកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មីរបស់សិស្សស្រី មានកម្រិតខ្ពស់ចាប់ពី ៤.២១ (M=4.21) រហូតដល់កម្រិតទាបបំផុតគឺ ២.២៣ (M=2.23) និងកម្រិតមធ្យម ៣.៣៦ (M=3.36). មានន័យថា ចំណុចទី ១. សិស្សមានស្មារតីឧស្សាហ៍ព្យាយាមប្រឹងប្រែងរៀនសូត្រមានកម្រិតខ្ពស់ គឺ ៤.២១ (M=4.21) ឯចំណុចទី ៥១៖ ការគាំទ្រពីក្រសួងអប់រំ មានកម្រិតខ្ពស់ ៤.០៨ (M=4.08) និងកម្រិតខ្ពស់ចុងក្រោយ គឺ ចំណុចទី ៣៩៖ គ្រូត្រូវប្រឡងចូលដើម្បីបានបង្រៀននៅសាលាជំនាន់ថ្មី មានកម្រិតខ្ពស់ ៤.០៧ (M=4.07)។ ចំណែកកម្រិតទាប គឺចំណុចទី ៥០៖ អំពើហឹង្សាក្នុងគ្រួសារមានកម្រិតទាប ២.២៧ (M=2.27) កម្រិតទាបបន្ទាប់គឺចំណុចទី ៧៖ សេពគ្រឿងញៀន មាន

កម្រិតទាប ២.២៤ (M=2.24) និងចំណុចទី ១៣៖ គំនាបគ្រួសារ (មិនផ្ដល់ឱកាសឲ្យកូនបានចូលរៀន) មានកម្រិតទាបបំផុត ២.២៣ (M=2.23)។

ជារួមឃើញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី គឺសិស្សស្រីមានកម្រិតខ្ពស់ជាង សិស្សប្រុស ពោលគឺ សិស្សស្រីមានកម្រិតមធ្យម ៣.៣៦ (M=3.36) រីឯសិស្សប្រុសមានកម្រិតមធ្យម ៣.៣២ (M=3.32).

នៅក្នុងតារាងបន្ទាប់ អ្នកសិក្សាស្រាវជ្រាវនឹង ធ្វើការបង្ហាញពីកម្រិតនៃកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី ទៅលើផ្នែកនីមួយៗ ដោយបែងចែកទៅតាមភេទរបស់សិស្ស ។

**តារាងទី៧៖ មធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់កម្រិតនៃកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី ដែលមានចំនួន ៣០០ នាក់** ( N=300 )

| ល.រ | ខ្លឹមសារ | ប្រុស | | អត្ថន័យ | លំដាប់ | ស្រី | | អត្ថន័យ | លំដាប់ |
|---|---|---|---|---|---|---|---|---|---|
| | | មធ្យម | គម្លាតស្តង់ដា | | | មធ្យម | គម្លាតស្តង់ដា | | |
| ១. | សិស្សមានស្មារតីឧស្សាហ៍ព្យាយាមប្រឹងប្រែងរៀនសូត្រ។ | 4.06 | 1.24 | ខ្ពស់ | 1 | 4.21 | 1.06 | ខ្ពស់ | 1 |
| ២. | ជួយធ្វើកិច្ចការផ្ទះ។ | 3.12 | 1.20 | មធ្យម | 7 | 3.02 | 1.24 | មធ្យម | 6 |
| ៣. | មានគោលដៅច្បាស់លាស់ក្នុងការសិក្សា។ | 3.91 | 1.22 | មធ្យម | 2 | 3.91 | 1.24 | ខ្ពស់ | 3 |
| ៤. | ជួយមើលថែប្អូននៅផ្ទះ។ | 2.69 | 1.29 | មធ្យម | 4 | 2.90 | 1.30 | មធ្យម | 7 |
| ៥. | ពុះពារគ្រប់ឧបសគ្គ។ | 3.39 | 1.30 | មធ្យម | 5 | 3.97 | 1.42 | ខ្ពស់ | 2 |
| ៦. | ការរិះគិតត្រូវ (ការគិតបានត្រឹមត្រូវ)។ | 3.27 | 1.29 | មធ្យម | 6 | 3.45 | 1.33 | មធ្យម | 5 |
| ៧. | សេពគ្រឿងញៀន។ | 2.57 | 1.72 | មធ្យម | 9 | 2.24 | 1.63 | ទាប | 10 |
| ៨. | ការដើរលេង និងមានមិត្តភក្តិច្រើន។ | 2.58 | 1.34 | មធ្យម | 8 | 2.36 | 1.30 | ទាប | 9 |
| 9. | តំណពូជ (បងប្អូន ឪពុកម្ដាយមិនបានទទួលការសិក្សា)។ | 2.53 | 1.40 | មធ្យម | 10 | 2.47 | 1.34 | ទាប | 8 |
| ១០. | មានការតាំងចិត្តខ្ពស់ក្នុងការសិក្សារៀនសូត្រ។ | 3.88 | 1.30 | មធ្យម | 3 | 3.80 | 1.40 | ខ្ពស់ | 4 |
| **សរុប** | | **3.2** | **1.33** | **មធ្យម** | **3** | **3.23** | **1.62** | **មធ្យម** | **3** |
| **ផ្នែកទី១៖ កត្តាសិស្ស** | | | | | | | | | |
| ១១ | គ្រួសារក្រីក្រ។ | 2.70 | 1.30 | មធ្យម | 2 | 2.53 | 1.28 | មធ្យម | 4 |
| ១២ | ការចំណាកស្រុករបស់គ្រួសារ។ | 2.66 | 1.35 | មធ្យម | 4 | 2.39 | 1.38 | ទាប | 7 |
| ១៣ | គំនាបគ្រួសារ (មិនផ្ដល់ឱកាសឲ្យកូនបានចូលរៀន)។ | 2.49 | 1.52 | មធ្យម | 8 | 2.23 | 1.48 | ទាប | 11 |
| ១៤ | ខ្វះភាពកក់ក្ដៅ (ឪពុក ម្ដាយរវល់ការងារ)។ | 2.66 | 1.35 | មធ្យម | 6 | 2.49 | 1.42 | ទាប | 5 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ១៥ | គ្មានការលើកទឹកចិត្តពីក្រុមគ្រួសារ។ | 2.68 | 1.44 | មធ្យម | 5 | 2.38 | 1.44 | ទាប | 9 |
| ១៦ | ការរើសអើង (កូនស្រីមិនបាច់ចូលរៀន)។ | 2.40 | 1.54 | ទាប | 11 | 2.40 | 1.59 | ទាប | 6 |
| ១៧ | អំពើហឹង្សាក្នុងគ្រួសារ។ | 2.38 | 1.46 | ទាប | 10 | 2.27 | 1.53 | ទាប | 10 |
| ១៨ | គ្មានមធ្យោបាយធ្វើដំណើរ។ | 2.45 | 1.31 | ទាប | 9 | 2.32 | 1.30 | ទាប | 8 |
| ១៩ | គ្រួសារខ្វះលទ្ធភាពឲ្យកូនទៅរៀន | 2.73 | 1.27 | មធ្យម | 3 | 2.73 | 1.23 | មធ្យម | 3 |
| ២០ | គ្រួសារជាអ្នកមាន។ | 2.55 | 1.18 | មធ្យម | 7 | 2.88 | 1.29 | មធ្យម | 2 |
| ២១ | ប្រាក់វិភាគទានពីឪពុកម្ដាយសិស្ស។ | 3.39 | 1.34 | មធ្យម | 1 | 3.42 | 1.35 | មធ្យម | 1 |
| **សរុប** | | **2.64** | **1.36** | **មធ្យម** | 4 | **2.54** | **1.39** | **មធ្យម** | 4 |
| **ផ្នែកទី ២៖កត្តាគ្រួសារ** | | | | | | | | | |
| ២២ | នាយកសាលាដឹកនាំបានល្អ។ | 3.93 | 1.29 | ខ្ពស់ | 4 | 3.93 | 1.32 | ខ្ពស់ | 4 |
| ២៣ | នាយកសាលាមានគណនេយ្យភាពក្នុងការដឹកនាំ និងគ្រប់គ្រង។ | 3.92 | 1.26 | ខ្ពស់ | 5 | 3.95 | 1.33 | ខ្ពស់ | 3 |
| ២៤ | បរិស្ថានសាលាល្អ។ | 3.73 | 1.63 | ខ្ពស់ | 9 | 3.77 | 1.49 | ខ្ពស់ | 13 |
| ២៥ | សាលាមានសួនច្បារ និងសួនជីវចំរុះ។ | 3.40 | 1.47 | មធ្យម | 19 | 3.66 | 1.44 | ខ្ពស់ | 17 |
| ២៦ | សាលាមានអាគារសិក្សាគ្រប់គ្រាន់ និងទំនើបៗ។ | 3.57 | 1.47 | ខ្ពស់ | 17 | 3.63 | 1.44 | ខ្ពស់ | 18 |
| ២៧ | គ្រូបង្រៀនប្រកបដោយ ចំណេះដឹង សមត្ថភាពខ្ពស់ | 3.90 | 1.46 | ខ្ពស់ | 6 | 3.92 | 1.46 | ខ្ពស់ | 5 |
| ២៨ | គ្រូបង្រៀនមានភាពរួសរាយ រាក់ទាក់ សុភាពរាបសាប្រកបដោយស្នាមញញឹម។ | 3.73 | 1.34 | ខ្ពស់ | 9 | 3.82 | 1.39 | ខ្ពស់ | 10 |
| ២៩ | មានសម្ភារៈសិក្សាគ្រប់គ្រាន់។ | 3.59 | 1.34 | ខ្ពស់ | 14 | 3.82 | 1.36 | ខ្ពស់ | 10 |
| ៣០ | សាលាមានបណ្ណាល័យសម្រាប់អានសៀវភៅ។ | 3.74 | 1.45 | ខ្ពស់ | 8 | 3.84 | 1.45 | ខ្ពស់ | 9 |
| ៣១ | កម្មវិធីសិក្សាច្បាស់លាស់ និងត្រូវទៅតាមកម្រិតថ្នាក់របស់សិស្ស។ | 3.58 | 1.37 | ខ្ពស់ | 14 | 3.71 | 1.41 | ខ្ពស់ | 14 |
| ៣២ | មានសៀវភៅសិក្សាគោលគ្រប់គ្រាន់។ | 3.70 | 1.32 | ខ្ពស់ | 11 | 3.82 | 1.42 | ខ្ពស់ | 10 |
| ៣៣ | មានក្លឹបសិក្សា (សម្រាប់ជួយបំប៉នសិស្សខ្សោយ)។ | 3.63 | 1.39 | ខ្ពស់ | 1៣ | 3.71 | 1.41 | ខ្ពស់ | 14 |
| ៣៤ | មានការប្រឡងដើម្បីបានចូលរៀននៅសាលជំនាន់ថ្មី។ | 3.85 | 1.27 | ខ្ពស់ | 7 | 3.94 | 1.36 | ខ្ពស់ | 3 |
| ៣៥ | ការសិក្សាជាក្រុម។ | 3.59 | 1.32 | ខ្ពស់ | 14 | 3.55 | 1.35 | ខ្ពស់ | 20 |
| ៣៦ | ធ្វើតេស្តស្ទង់ជា(ប្រចាំខែ ឆមាស និងដំណាច់ឆ្នាំ)។ | 3.95 | 1.18 | ខ្ពស់ | 3 | 3.90 | 1.36 | ខ្ពស់ | 8 |
| ៣៧ | ការចូលរួមសកម្មភាពនានាក្នុង និងក្រៅថ្នាក់។ | 3.44 | 1.19 | មធ្យម | 18 | 3.62 | 1.29 | ខ្ពស់ | 19 |
| ៣៨ | ទស្សនកិច្ចសិក្សា។ | 3.34 | 1.33 | មធ្យម | 20 | 3.71 | 1.28 | ខ្ពស់ | 14 |
| ៣៩ | គ្រូត្រូវប្រឡងចូលដើម្បីបានបង្រៀននៅសាលាជំនាន់ថ្មី។ | 4.06 | 1.15 | ខ្ពស់ | 1 | 4.07 | 1.21 | ខ្ពស់ | 1 |
| ៤០ | គ្រូ និងសិស្សប្រើប្រាស់កុំព្យូទ័រ tablets និងស្លាយដើម្បីរៀន និងបង្រៀន។ | 4.05 | 1.26 | ខ្ពស់ | 2 | 4.01 | 1.28 | ខ្ពស់ | 2 |
| ៤១ | មានការអប់រំសុខភាព និងកីឡា។ | 3.69 | 2.05 | ខ្ពស់ | 12 | 3.92 | 1.35 | ខ្ពស់ | 5 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| **សរុប** | | **3.71** | **1.37** | **ខ្ពស់** | **1** | **3.81** | **1.37** | **ខ្ពស់** | **1** |
| **ផ្នែកទី ៣៖ កត្តាសាលារៀន** | | | | | | | | | |
| ៤២ | ភូមិ ឃុំមានសុវត្ថិភាព។ | 3.61 | 1.37 | ខ្ពស់ | 5 | 3.61 | 1.45 | ខ្ពស់ | 5 |
| ៤៣ | គ្មានល្បែងស៊ីសង។ | 2.89 | 1.51 | មធ្យម | 10 | 3.10 | 1.59 | មធ្យម | 8 |
| ៤៤ | ភូមិនៅជិតសាលា។ | 3.13 | 1.34 | មធ្យម | 8 | 3.10 | 1.39 | មធ្យម | 8 |
| ៤៥ | គ្មានអំពើហឹង្សា ចោរកម្ម ។ | 2.93 | 1.46 | មធ្យម | 9 | 3.07 | 3.54 | មធ្យម | 10 |
| ៤៦ | គ្មានការជួញដូរស្រ្តី និងកុមារ។ | 2.80 | 1.56 | មធ្យម | 11 | 2.88 | 1.61 | មធ្យម | 11 |
| ៤៧ | សហគមន៍មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់។ | 3.66 | 1.22 | ខ្ពស់ | 4 | 3.44 | 1.43 | មធ្យម | 7 |
| ៤៨ | មានសេវាបម្រើប្រជាពលរដ្ឋល្អ។ | 3.41 | 1.32 | មធ្យម | 7 | 3.45 | 1.39 | មធ្យម | 6 |
| ៤៩ | ការចូលរួមបដិភាគក្នុងការកសាង និងអភិវឌ្ឍសាលារៀនពីមាតាបិតាសិស្ស។ | 3.88 | 1.26 | ខ្ពស់ | 2 | 3.88 | 1.30 | ខ្ពស់ | 3 |
| ៥០ | ចូលរួមគាំទ្រពីអង្គការនានា។ | 3.68 | 1.25 | ខ្ពស់ | 3 | 3.95 | 1.25 | ខ្ពស់ | 2 |
| ៥១ | ការគាំទ្រពីក្រសួងអប់រំ។ | 3.94 | 1.18 | ខ្ពស់ | 1 | 4.08 | 1.22 | ខ្ពស់ | 1 |
| ៥២ | សេវាថែរក្សាសុខភាពល្អ។ | 3.51 | 1.35 | ខ្ពស់ | 6 | 3.65 | 1.29 | ខ្ពស់ | 4 |
| **សរុប** | | **3.4** | **1.34** | **មធ្យម** | **2** | **3.47** | **1.58** | **មធ្យម** | **2** |
| **ផ្នែកទី ៤៖ កត្តាសង្គម** | | | | | | | | | |
| **សរុបរួម** | | **3.23** | **1.35** | **មធ្យម** | **2** | **3.25** | **1.49** | **មធ្យម** | **1** |

តាមតារាងជាផ្នែកខាងលើបានបង្ហាញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី នៅក្នុងផ្នែកនីមួយៗ សម្រាប់សិស្សប្រុស ផ្នែកទី ១៖ ចំណុចទី ១៖សិស្សមានស្មារតីឧស្សាហ៍ព្យាយាមប្រឹងប្រែងរៀនសូត្រ មានកម្រិតខ្ពស់ ៤.០៦ (M=4.06) និងចំណុចទី ៩៖ តំណពូជ (បងប្អូន ឪពុកម្តាយមិនបានទទួលការសិក្សា មានកម្រិតមធ្យមទាបបំផុត ២.៥៣ (M=2.53) ចំណែកឯសិស្សស្រី ផ្នែកទី ១៖ ចំណុចទី ១៖ សិស្សមានស្មារតីឧស្សាហ៍ព្យាយាមប្រឹងប្រែងរៀនសូត្រ មានកម្រិតខ្ពស់ ៤.២១ (M=4.21) ព្រមទាំងចំណុចទី ៧៖ សេពគ្រឿងញៀន មានកម្រិតទាបំផុត ២.២៤ (M=2.24)។

ចំពោះកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី របស់សិស្សប្រុស ផ្នែកទី ២៖ កត្តាគ្រួសារ ចំណុចទី ២១៖ ប្រាក់វិភាគទានពីឪពុកម្តាយសិស្ស មានមធ្យម កម្រិតខ្ពស់ ៣.៣៩ (M=3.39) និងចំណុចទី ១៦៖ ការរើសអើង (កូនស្រីមិនបាច់ចូលរៀន) មានកម្រិតទាបបំផុត ២.៤០ (M=2.40) ចំណែកសិស្សស្រី ផ្នែកទី ១៖ ចំណុចទី ២១៖ ប្រាក់វិភាគទានពីឪពុកម្តាយសិស្ស មានមធ្យមកម្រិតខ្ពស់ ៣.៤២ (M=3..42) ហើយចំណុចទី ១៣៖ គំនាបគ្រួសារ (មិនផ្តល់ឳកាសឲ្យកូនបានចូលរៀន) មានមធ្យមកម្រិតទាបបំផុត ២.២៣ (M=2.23)។

រីឯកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី របស់សិស្សប្រុស ផ្នែកទី ៣៖ កត្តាសាលារៀន ចំណុចទី ៣៩៖ គ្រូត្រូវប្រឡងចូលដើម្បីបានបង្រៀននៅសាលាជំនាន់ថ្មី មាន

មធ្យម កម្រិតខ្ពស់ ៤.០៦ (M=4.06) និងចំណុចទី ៣៨៖ ទស្សនកិច្ចសិក្សា មានមធ្យម កម្រិតមធ្យមទាបបំផុត គឺ ៣.៣៤ (M=3.34)ចំពោះសិស្សស្រី ផ្នែកទី ៣៖ កត្តាសាលារៀន ចំណុចទី ៣៩៖ គ្រូត្រូវប្រឡងចូលដើម្បីបានបង្រៀននៅសាលាជំនាន់ថ្មី មានមធ្យម កម្រិតខ្ពស់ ៤.០៧ (M=4.07) និងចំណុចទី ៣៥៖ ការសិក្សាជាក្រុម មានមធ្យម កម្រិតមធ្យមទាបបំផុត ៣.៥៥ (M=3.55).

ចំណែកកកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី របស់សិស្សប្រុស ផ្នែកទី ៤៖ ចំណុចទី ៥១៖ ការគាំទ្រពីក្រសួងអប់រំ មានមធ្យម កម្រិតខ្ពស់ ៣.៩៤ (M=3.94) ឯចំណុចទី ៤៦៖ គ្មានការជួញដូរស្ត្រី និងកុមារ មានមធ្យម កម្រិតមធ្យមទាបបំផុត ២.៨០ (M=2.80)។ ចំណែកឯសិស្សស្រី ផ្នែកទី ៤៖ ចំណុចទី ៥១៖ ការគាំទ្រពីក្រសួងអប់រំ មានមធ្យម កម្រិតខ្ពស់ ៤.០៨ (M=4.08) និងចំណុចទី ៤៦៖ គ្មានការជួញដូរស្ត្រី និងកុមារ មានមធ្យម កម្រិតមធ្យមដែលទាបបំផុត ២.៨៨ (M=2.88)។

ជារួមឃើញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី គឺសិស្សស្រីមានកម្រិតខ្ពស់ជាងសិស្សប្រុស តែការយល់ដឹងពីកត្តាដែលជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្ស មានលក្ខណៈដូចគ្នា។

នៅតារាងបន្ទាប់ អ្នកសិក្សាស្រាវជ្រាវនឹងធ្វើការបង្ហាញពី កម្រិតនៃកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី តាមភេទរបស់សិស្ស ទៅលើកត្តានីមួយៗ

**តារាងទី៨៖ មធ្យម គម្លាតស្តង់ដា អត្ថន័យ និងលំដាប់កម្រិតនៃកត្តាជះឥទ្ធិពលនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី តាមភេទ ទៅលើកត្តានីមួយៗ។**

| ខ្លឹមសារ | ប្រុស | | | | ស្រី | | | |
|---|---|---|---|---|---|---|---|---|
| | មធ្យម | គម្លាតស្តង់ដា | អត្ថន័យ | លំដាប់ | មធ្យម | គម្លាតស្តង់ដា | អត្ថន័យ | លំដាប់ |
| ១. កត្តាសិស្ស | 3.2 | 1.33 | មធ្យម | 3 | 3.23 | 1.62 | មធ្យម | 3 |
| ២. កត្តាគ្រួសារ | 2.64 | 1.36 | មធ្យម | 4 | 2.54 | 1.39 | មធ្យម | 4 |
| ៣. កត្តាសាលារៀន | 3.71 | 1.37 | ខ្ពស់ | 1 | 3.81 | 1.37 | ខ្ពស់ | 1 |
| ៤. កត្តាសង្គម | 3.4 | 1.34 | មធ្យម | 2 | 3.47 | 1.58 | មធ្យម | 2 |
| **សរុប** | 3.23 | 1.35 | មធ្យម | 2 | 3.25 | 1.49 | មធ្យម | 1 |

តាមតារាងជាផ្នែកខាងលើបានបង្ហាញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី របស់សិស្សប្រុសមានកម្រិតខ្ពស់ចាប់ពី ៣.៧១ (M=3.71) រហូតដល់មធ្យម កម្រិតទាប ២.៦៤ (M=2.64) ពោលគឺ ផ្នែកទី ៣៖ កត្តាសាលារៀន មានកម្រិតខ្ពស់ ៣.៧១ (M=3.71) និង

ផ្នែកទី ២៖ កត្តាគ្រួសារ មានមធ្យម កម្រិតទាប ២.៦៤ (M=2.64)។ ចំណែកឯកត្តាជះឥទ្ធិពលដល់កាគុណភាពនៃរសិក្សារបស់សិស្សសាលាជំនាន់ថ្មី របស់សិស្សស្រី កម្រិតខ្ពស់ ចាប់ពី ៣.៨១ (M=3.81) រហូតដល់មធ្យមកម្រិតទាប ២.៥៤ (M=2.54). ពោលគឺ ផ្នែកទី១៖ កត្តាសាលារៀន មានកម្រិតខ្ពស់ ៣.៨១ ផ្នែកទី២៖ កត្តាសង្គម មានមធ្យម កម្រិតមធ្យម ៣.៤៧ ផ្នែកទី៣៖ កត្តាសិស្ស មានមធ្យម កម្រិតមធ្យម ៣.២៣ ផ្នែកទី៤៖ កត្តាគ្រួសារ មានមធ្យម កម្រិតមធ្យម ២.៥៤។

សរុបមក កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី របស់សិស្សស្រី មានកម្រិតមធ្យម ខ្ពស់ជាងសិស្សប្រុស គឺ ៣.២៥ (M=3.25) រីឯសិស្សប្រុស មានកម្រិតមធ្យម ៣.២៣(M=3.23)។ ចំពោះការយល់ដឹងរបស់សិស្សទាំងពីភេទមានលក្ខណៈដូចគ្នា។

**តារាងទី៩៖ មធ្យម កម្រិតនៃកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី ដោយបែងចែកតាមកម្រិតថ្នាក់របស់សិស្ស។**

| កត្តា | ក្រុមអថេរ | Sum of squares | df | Mean Squares | F | p-value |
|---|---|---|---|---|---|---|
| សិស្ស | Between Groups<br>Within Groups<br>Total | 5.968<br>135.949<br>141.916 | 2<br>297<br>299 | 2.984<br>.458 | 6.519 | .002 |
| គ្រួសារ | Between Groups<br>Within Groups<br>Total | 17.715<br>192.611<br>210.326 | 2<br>297<br>299 | 8.857<br>.649 | 13.658 | .000 |
| សាលារៀន | Between Groups<br>Within Groups<br>Total | 6.691<br>317.240<br>32.931 | 2<br>297<br>299 | 3.346<br>1.068 | 3.132 | .045 |
| សង្គម | Between Groups<br>Within Groups<br>Total | .903<br>288.641<br>289.544 | 2<br>297<br>299 | .452<br>.972 | .465 | .629 |
| សរុប | Between Groups<br>Within Groups<br>Total | .523<br>101.635<br>102.158 | 2<br>297<br>299 | .262<br>342 | .764 | .467 |

យោងតាមលទ្ធផលខាងលើឃើញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី មានកត្តាបី ដែលមានភាពខុសគ្នា គឺ ១)កត្តាសិស្ស ២)កត្តាគ្រួសារ និង ៣)កត្តាសាលារៀន ($p<0.05$) មានន័យថា តម្លៃ (p-value) បើមានតម្លៃតូចជាង ($p<0.05$) គឺមានភាពខុសគ្នា។ ចំពោះកត្តាមួយផ្សេងទៀត គឺកត្តាសង្គម មិនមានភាពខុសគ្នាទេ ដោយ ($p>0.05$) គឺកត្តាសង្គម ($p=0.629$)។

លទ្ធផលជារួមឃើញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី គឺមិនខុសគ្នាទេ ចំពោះកត្តាសង្គម ព្រោះ (p=0.467) ដែលជាតម្លៃធំជាង 0.0៥ (p>0.05)។

តាមលទ្ធផលនៃតារាងខាងលើ អ្នកសិក្សាស្រាវជ្រាវនឹងធ្វើការប្រៀបធៀប កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី ដោយចាត់តាមកម្រិតថ្នាក់នីមួយៗរបស់សិស្ស។

## ៤.២ លទ្ធផលនៃការស្រាវជ្រាវសំណួរទី២៖ តើមានភាពខុសគ្នា និងដូចគ្នាអ្វីខ្លះរវាងកត្តាដែលជះឥទ្ធិពលដល់គុណភាពការសិក្សារបស់សិស្សសាលាជំនាន់ថ្មីតាមកម្រិតថ្នាក់ និងភេទរបស់សិស្ស?

នៅក្នុងចំណុចនេះ អ្នកស្រាវជ្រាវនឹងធ្វើការប្រៀបធៀបនូវភាពដូចគ្នា និងភាពខុសគ្នា រវាងកត្តាដែលជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្ស តាមកម្រិតថ្នាក់ និងភេទរបស់សិស្ស។ អ្នកសិក្សាស្រាវជ្រាវនឹងធ្វើការញែកឲ្យឃើញច្បាស់នូវកម្រិតថ្នាក់ និងភេទ។

**តារាងទី ១០៖ ការប្រៀបធៀបភាពខុសគ្នារបស់ កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី ទៅលើកត្តាសិស្សដោយបែងចែកតាមថ្នាក់នីមួយៗ**

| កត្តាសិស្ស | Mean | ថ្នាក់ទី៧ | ថ្នាក់ទី៨ | ថ្នាក់ទី៩ |
|---|---|---|---|---|
| | | 3.20 | 3.40 | 3.06 |
| ថ្នាក់ទី៧ | 3.20 | _ | _ | _ |
| ថ្នាក់ទី៨ | 3.40 | _ | _ | 0.34 |
| ថ្នាក់ទី៩ | 3.06 | _ | 0.34* | _ |

តាមលទ្ធផលនៃតារាងខាងលើបានបង្ហាញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សនៅសាលារៀនជំនាន់ថ្មី ដោយមើលទៅលើកត្តាសិស្ស បានបង្ហាញថា រវាងសិស្សថ្នាក់ទី៧ នឹងថ្នាក់ទី៧ និងរវាងសិស្សថ្នាក់ទី៧ នឹងថ្នាក់ទី៨ ព្រមទាំងថ្នាក់ទី៩ និងទី៩ ការយល់ឃើញទៅលើកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី ពុំមានភាពខុសគ្នានោះទេ។ ចំណែកសិស្សថ្នាក់ទី៨ និងសិស្សថ្នាក់ទី៩ គឺមានភាពខុសគ្នា ទៅលើកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី គឺតម្លៃមធ្យមខុសគ្នា 0.៣៤ (M.D=0.34)។

សរុបជារួមឃើញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មីមានភាពខុសគ្នារវាងសិស្សថ្នាក់ទី៨ ជាមួយសិស្សថ្នាក់ទី៩ ពីព្រោះតម្លៃខុសគ្នា 0.៣៤ (M.d=0.34)។

**តារាងទី ១១៖ ការប្រៀបធៀបភាពខុសគ្នារបស់ កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី ដោយផ្តោតទៅលើកត្តាគ្រួសារ ដោយបែងចែកទៅតាមកម្រិតថ្នាក់នីមួយៗ**

| កត្តាគ្រួសារ | Mean | ថ្នាក់ទី៧ | ថ្នាក់ទី៨ | ថ្នាក់ទី៩ |
|---|---|---|---|---|
| | | 2.39 | 2.94 | 2.45 |
| ថ្នាក់ទី៧ | 2.39 | _ | 0.54* | _ |
| ថ្នាក់ទី៨ | 2.94 | 0.54 | __ | 0.49 |
| ថ្នាក់ទី៩ | 2.45 | _ | 0.49* | _ |

តាមលទ្ធផលនៃតារាងខាងលើបានបង្ហាញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី ទៅលើកត្តាគ្រួសារ គឺរវាងសិស្សថ្នាក់ទី៧នឹងសិស្សថ្នាក់ទី៧ រវាងសិស្សថ្នាក់ទី៧នឹងសិស្សថ្នាក់ទី៩ រវាងសិស្សថ្នាក់ទី៨នឹងសិស្សថ្នាក់ទី៨ និងសិស្សថ្នាក់ទី៩នឹងសិស្សថ្នាក់ទី៩ ពុំមានភាពខុសគ្នាទេ ចំពោះកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី។ ចំណែកឯកត្តាជះឥទ្ធិពលដល់ការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី របស់សិស្សថ្នាក់ទី៧នឹងសិស្សថ្នាក់ទី៨ និងសិស្សថ្នាក់ទី៨នឹងសិស្សថ្នាក់ទី៩ មានភាពខុសគ្នា មានន័យថា តម្លៃមធ្យមរបស់ថ្នាក់ទី៧នឹងថ្នាក់ទី៨ មានតម្លៃ 0.៥៤ ( M.D=0.54) និងថ្នាក់ទី៨នឹងថ្នាក់ទី៩ មានតម្លៃ 0.៤៩ (M.D=0.49)។

សរុបជារួមឃើញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី មានភាពខុសគ្នា នៅក្នុងកត្តាសិស្ស និងកត្តាគ្រួសារ គឺខុសគ្នារវាង សិស្សថ្នាក់ទី៧នឹងថ្នាក់ទី៨ និងថ្នាក់ទី៨នឹងថ្នាក់ទី៩ រីឯកត្តាពីរផ្សេង គឺកត្តាសាលារៀន និងកត្តាសង្គម ពុំមានភាពខុសគ្នាតាមកម្រិតថ្នាក់នោះទេ។

**តារាងទី១២៖ ភាពដូចគ្នា និងភាពខុសគ្នា រវាងកត្តាដែលបានជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី របស់សិស្សប្រុស និងសិស្សស្រី ដោយចាត់តាមផ្នែកនីមួយៗ ដែលមានសិស្សចំនួន ៣០០ នាក់** ( N=300 )

| ខ្លឹមសារ | ប្រុស | | | | ស្រី | | | |
|---|---|---|---|---|---|---|---|---|
| | មធ្យម | គម្លាតស្តង់ដា | អត្ថន័យ | លំដាប់ | មធ្យម | គម្លាតស្តង់ដា | អត្ថន័យ | លំដាប់ |
| ១. កត្តាសិស្ស | 3.2 | 1.33 | មធ្យម | 3 | 3.23 | 1.62 | មធ្យម | 3 |
| ២. កត្តាគ្រួសារ | 2.64 | 1.36 | មធ្យម | 4 | 2.54 | 1.39 | មធ្យម | 4 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៣. កត្តាសាលារៀន | 3.71 | 1.37 | ខ្ពស់ | 1 | 3.81 | 1.37 | ខ្ពស់ | 1 |
| ៤. កត្តាសង្គម | 3.4 | 1.34 | មធ្យម | 2 | 3.47 | 1.58 | មធ្យម | 2 |
| **សរុប** | 3.23 | 1.35 | មធ្យម | 2 | 3.25 | 1.49 | មធ្យម | 1 |

តាមតារាងជាផ្នែកខាងលើបានបង្ហាញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី របស់សិស្សប្រុសមានកម្រិតខ្ពស់ចាប់ពី ៣.៧១ (M=3.71) រហូតដល់មធ្យម កម្រិតទាប ២.៦៤ (M=2.64) ពោលគឺ ផ្នែកទី ៣៖ កត្តាសាលារៀន មានកម្រិតខ្ពស់ ៣.៧១ (M=3.71) និងផ្នែកទី ២៖ កត្តាគ្រួសារ មានមធ្យម កម្រិតទាប ២.៦៤ (M=2.64)។ ចំណែកឯកត្តាជះឥទ្ធិពលដល់កាគុណភាពនៃរសិក្សារបស់សិស្សសាលាជំនាន់ថ្មី របស់សិស្សស្រី កម្រិតខ្ពស់ ចាប់ពី ៣.៨១ (M=3.81) រហូតដល់មធ្យមកម្រិតទាប ២.៥៤ (M=2.54)។

តារាងបន្ទាប់ទៅនេះ អន្តសិក្សាស្រាវជ្រាវនឹងបង្ហាញពី ភាពដូចគ្នារវាងកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី តាមកត្តានីមួយៗដូខាងក្រោម៖

**តារាងទី១៣៖ ភាពខុសគ្នា រវាងកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី ដោយចាត់តាមកត្តានីមួយៗ ដែលមានសិស្សចំនួន ៣០០ នាក់** (N=300) ។

| កត្តាសិស្ស | Mean | ថ្នាក់ទី៧ | ថ្នាក់ទី៨ | ថ្នាក់ទី៩ | t | p-value |
|---|---|---|---|---|---|---|
| | | 3.20 | 3.40 | 3.06 | | |
| ថ្នាក់ទី៧ | 3.20 | _ | _ | _ | _ | _ |
| ថ្នាក់ទី៨ | 3.40 | _ | _ | 0.34 | .094 | .002 |
| ថ្នាក់ទី៩ | 3.06 | _ | 0.34* | _ | .094 | .002 |
| កត្តាគ្រួសារ | Mean | ថ្នាក់ទី៧ | ថ្នាក់ទី៨ | ថ្នាក់ទី៩ | t | p-value |
| | | 2.39 | 2.94 | 2.45 | | |
| ថ្នាក់ទី៧ | 2.39 | _ | 0.54* | _ | 0.11 | .000 |
| ថ្នាក់ទី៨ | 2.94 | _ | __ | 0.49 | _ | _ |
| ថ្នាក់ទី៩ | 2.45 | _ | 0.49* | _ | 0.11 | .000 |

តាមលទ្ធផលខាងលើបានបង្ហាញថា ក្នុងកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី គឺកត្តាសិស្ស និងកត្តាគ្រួសារ មានភាពខុសគ្នា។ មានន័យថា នៅក្នុងកត្តាសិស្ស គឺខុសគ្នារវាងថ្នាក់ទី៨ និងថ្នាក់ទី៩ ដោយសារតម្លៃ (p-value =0.002) ដែលជាតម្លៃតូចជាង (p<0.05)។

ចំណែកឯ កត្តាគ្រួសារ គឺមានភាពខុសគ្នារវាង ពីរកម្រិតថ្នាក់ គឺ រវាងថ្នាក់ទី៧នឹងថ្នាក់ទី៨ និងរវាងថ្នាក់ទី៨នឹងថ្នាក់ទី៩ ពោលគឺតម្លៃខុសគ្នា ( M.d=0.54) និង (M.d=0.49) រីឯ (p-value=.000) ដែលជាតម្លៃតូចជាង 0.0៥ ($p<0.05$)។

# ជំពូកទី ៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសង្ខេបលទ្ធផលនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះក្នុងគោលបំណងសិក្សាអំពី កត្តាដែលជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្ស និងភាពដូចគ្នា និងភាពខុសគ្នា រវាងកត្តាដែលបានជះឥទ្ធិពលដល់ការសិក្សារបស់សិស្ស ដោយបែងចែកតាមថ្នាក់ និងភេទរបស់សិស្ស សាលាជំនាន់ថ្មី (អនុវិទ្យាល័យគោកព្រីង) ខេត្តស្វាយរៀង។ ក្នុងនោះ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសប្រជាជន (សិស្ស) ចំនួន ៣០០ នាក់ ស្រី ១៤៦ នាក់ រួមមាន៖

- ថ្នាក់ទី៧ មាន ០៣ ថ្នាក់ មានសិស្ស ចំនួន ៩៣ នាក់ ស្រី ៥១ នាក់
- ថ្នាក់ទី៨ មាន ០៣ ថ្នាក់ មានសិស្ស ចំនួន ៩៧ នាក់ស្រី ៥១ នាក់
- ថ្នាក់ទី៩ មាន ០៣ ថ្នាក់ មានសិស្ស ចំនួន ១០៩ នាក់ ស្រី ៤៤ នាក់។

ឧបករណ៍នៃការស្រាវជ្រាវ អ្នកសិក្សាបានប្រើប្រាស់កម្រងសំណួរជ្រើសរើសដែលមានចំនួន ៥២ សំណួរ បែងចែកជា ៤ ផ្នែក គឺ

- ផ្នែកទី១៖ កត្តាសិស្ស (មាន ១០ ចំណុច ចាប់ពី ១ ដល់ ១០)
- ផ្នែកទី២៖ កត្តាគ្រួសារ (មាន ១១ ចំណុច ចាប់ពី ១១ ដល់ ២១)
- ផ្នែកទី៣៖ កត្តាសាលារៀន (មាន ២០ ចំណុច ចាប់ពី ២២ ដល់ ៤១)
- ផ្នែកទី៤៖ កត្តាសង្គម (មាន ១១ ចំណុច ចាប់ពី ៤២ ដល់ ៥២)

នៅក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រវិភាគទិន្នន័យតាមបែបបរិមាណវិស័យ។ បន្ទាប់មកអ្នកសិក្សាស្រាវជ្រាវ សំយោគបញ្ចូលគ្នា នូវសំណាកនីមួយៗ ( ដោយប្រៀបធៀបភាពខុសគ្នា និងភាពដូចគ្នា រវាងភេទ និងតាមថ្នាក់នីមួយៗរបស់សិស្ស) ដោយផ្តោតសំខាន់ទៅលើ កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី។ ដើម្បីឆ្លើយតបនឹងចំណុចនេះ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្មវិធី SPSS ដើម្បីវិភាគរក (Mean, Standard Diviation, One-Sample T-test and One-way ANOVA) ព្រមទាំងសាងតារាងតាម Ms. Word និងMs.Excel ដើម្បីធ្វើការបង្ហាញ និងប្រៀបធៀបតាមផ្នែកនីមួយៗ។

លទ្ធផលនៃការស្រាវជ្រាវសំខាន់ៗអាចបូកសរុបបានដូចខាងក្រោម៖

១. តាមតារាងខាងលើបង្ហាញថា កត្តាដែលបានជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សនៅសាលាជំនាន់ថ្មីចាប់ពីកម្រិតខ្ពស់ ពី ៤.១៣ រហូតដល់កម្រិតទាប ២.៣២។ មានន័យថា ចំណុច ១៖

សិស្សមានស្មារតីឧស្សាហ៍ព្យាយាមប្រឹងប្រែងរៀនសូត្រ គឺមានកម្រិតខ្ពស់ ៤.១៣ (M= 4.13) បន្ទាប់មកទៀត គឺ ចំណុច ៣៩៖ គ្រូត្រូវប្រឡងចូលដើម្បីបានបង្រៀននៅសាលាជំនាន់ថ្មី គឺ មានកម្រិតខ្ពស់ ៤.0៦ (M= 4.06) និងកម្រិតខ្ពស់ចុងក្រោយគឺចំណុច ៤0៖ គ្រូ និងសិស្សប្រើប្រាស់កុំព្យូទ័រ tablets និងស្លាយដើម្បីរៀន និង បង្រៀន មានកម្រិតខ្ពស់ ៤.0៣ (M= 4.03) ។ តារាងខាងលើក៏បានបង្ហាញផងដែរពីកម្រិតទាបបំផុត រួមមានចំណុច ១៤៖ គ្មានមធ្យោបាយធ្វើដំណើរ មានកម្រិតទាប ២.៣៩ ( M= 2.39 ) បន្ទាប់មកចំណុច ១៣៖ គំនាបគ្រួសារ (មិនផ្ដល់ឱកាសឲ្យកូនបានចូលរៀន) មានកម្រិតទាប ២.៣៦ ( M= 2.36 ) និងចំណុចចុងក្រោយដែលមានកម្រិតទាបបំផុតគឺ ចំណុច ១៧៖ អំពើហឹង្សាក្នុងគ្រួសារ ដែលមានកម្រិត ២.៣២ ( M= 2.32 ) ។

ឆ្លងតាមការវិភាគរួចមក អ្នកស្រាវជ្រាវ អាចធ្វើការសរុបបានថា កត្តាជះឥទ្ធិពលដល់ការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី រួមមាន៖ ១)ការខិតខំប្រឹងប្រែងរៀនសូត្ររបស់សិស្សមានកម្រិតខ្ពស់ ២) គ្រូត្រូវប្រឡងចូលដើម្បីបានបង្រៀននៅសាលាជំនាន់ថ្មី និង ៣) ៖ គ្រូ និងសិស្សប្រើប្រាស់កុំព្យូទ័រ tablets និងស្លាយដើម្បីរៀន និង បង្រៀន។

២. តាមលទ្ធផលផ្នែកនីមួយៗ បានបង្ហាញថា ផ្នែកទី៣៖ កត្តាសាលារៀន ស្ថិតក្នុងកម្រិតខ្ពស់ គឺ ៣.៧៦ (M=3.76) ចំណែកកម្រិតមធ្យមមាន ៣.៤២ , ៣.២១ និង ២.៥៩ ( M=3.42 ,M=3.21 ,M=2.59 ) ហើយកម្រិតមធ្យមទាបបំផុត គឺ ២.៥៩ (M=2.59). តាមលទ្ធផលនេះបានបង្ហាញថា ផ្នែកទី ៣៖ កត្តាសាលារៀន មានកម្រិតខ្ពស់ ៣.៧៦ (M=3.76) បន្ទាប់មកផ្នែកទី ៤៖ កត្តាសហគមន៍ មានកម្រិតមធ្យម គឺមធ្យមកម្រិតខ្ពស់ ៣.៤២ (M=3.42) បន្ទាប់មកទៀតផ្នែកទី ១៖ កត្តាសិស្ស មានកម្រិតមធ្យម ៣.២១ (M=3.21) ចំណែកឯផ្នែកទី ២៖ កត្តាគ្រួសារ មានកម្រិតមធ្យម គឺមធ្យមកម្រិតទាប ២.៥៩ (M=2.59) ។

តាមលទ្ធផលបានបង្ហាញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី ដោយបែងចែកតាមផ្នែកនីមួយៗទៅតាមលំដាប់រួមមាន៖ ១) កត្តាសាលារៀន ២) កត្តាសង្គម ៣) កត្តាសិស្ស និង ៤) កត្តាគ្រួសារ។

៣. ជាលទ្ធផលនៃការប្រៀបធៀបរវាងសិស្ស ប្រុស និង សិស្សស្រី បានបង្ហាញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី របស់សិស្សប្រុសមានកម្រិតខ្ពស់ចាប់ពី ៣.៧១ (M=3.71) រហូតដល់មធ្យម កម្រិតទាប ២.៦៤ (M=2.64) ពោលគឺ ផ្នែកទី ៣៖ កត្តាសាលារៀន មានកម្រិតខ្ពស់ ៣.៧១ (M=3.71) និងផ្នែកទី ២៖ កត្តាគ្រួសារ មានមធ្យម កម្រិតទាប ២.៦៤ (M=2.64)។ ចំណែកឯកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី របស់សិស្សស្រី កម្រិតខ្ពស់ ចាប់ពី ៣.៨១ (M=3.81) រហូតដល់មធ្យមកម្រិតទាប ២.៥៤ (M=2.54). ជារួមឃើញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី របស់សិស្សស្រីមានកម្រិតខ្ពស់ជាងសិស្សប្រុស។

៤. តាមលទ្ធផលក្នុងការប្រៀបធៀបតាមកត្តានីមួយៗ បានបង្ហាញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី គឺ១) កត្តាសិស្ស ២) កត្តាគ្រួសារ និង ៣) កត្តាសាលារៀនមានភាពខុសគ្នា។ មានន័យថា នៅក្នុងកត្តាទាំងបីខាងលើនេះមានតម្លៃ (p-value =0.002, p-value=0.000, p-value=0.045) ដែលជាតម្លៃតូចជាង 0.0៥ (p<0.05)។

ចំណែកឯ ការប្រៀបធៀបតាមថ្នាក់គឺកត្តាសិស្ស មានភាពខុសគ្នា រវាងថ្នាក់ទី៨នឹងថ្នាក់ទី៩ គឺតម្លៃខុសគ្នា (M.d=0.34) ចំពោះកត្តាគ្រួសារ គឺមានភាពខុសគ្នារវាង ពីរកម្រិតថ្នាក់ គឺ រវាងថ្នាក់ទី៧នឹងថ្នាក់ទី៨ និងរវាងថ្នាក់ទី៨នឹងថ្នាក់ទី៩ ពោលគឺតម្លៃខុសគ្នា ( M.d=0.54) និង (M.d=0.49) រីឯ (p-value=.000) ដែលជាតម្លៃតូចជាង 0.0៥ (p<0.05)។

## ៥.២-ការពិភាក្សាការស្រាវជ្រាវ

តាមលទ្ធផលស្រាវជ្រាវខាងលើបង្ហាញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី មានភាពខុសគ្នាចំពោះ កត្តាបី គឺ ១)កត្តាសិស្សដោយសារ - p<0.002 ២)កត្តាគ្រួសារ - p<0.000 និងកត្តាសាលារៀន- p<0.0៤៥។ លក្ខខណ្ឌនេះមានន័យថា ប្រសិនបើ p-value<0.05 តម្លៃនៃកត្តាទាំងនោះនឹងមានភាពខុសគ្នា នេះបើយោងតាមការបកស្រាយរបស់លោក Fan (2003)។ បើសិនយើងសង្កេតទៅលើកម្រិតថ្នាក់នីមួយៗ ក្នុង១)កត្តាសិស្ស មានភាពខុសគ្នារវាងថ្នាក់ទី៨ និងថ្នាក់ទី៩(M.d=0.34). ចំណែកកត្តាគ្រួសារវិញ មានភាពខុសគ្នា ពីរ កម្រិតគឺរវាងថ្នាក់ទី៧នឹងថ្នាក់ទី៨ (M.d=0.54) និងរវាងថ្នាក់ទី៨នឹងថ្នាក់ទី៩ (M.d=0.49)។

## ៥.៣- សំណូមពរ

### ៥.៣.១. សំណូមពរសម្រាប់ការអនុវត្ត

ដើម្បីឲ្យការអប់រំនៅកម្ពុជា ប្រកបដោយគុណភាព និងប្រសិទ្ធភាពនៃការបង្រៀន និងរៀន និងដើម្បីឆ្លើយតបគោលនយោបាយ ផែនការជាយុទ្ធសាស្រ្ត និងចក្ខុវិស័យរបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជា យុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា អ្នកសិក្សាស្រាវជ្រាវ សំណូមពរដល់ភាគីពាក់ព័ន្ធចូលរួមចំណែក និងជួយជ្រោមជ្រែងដល់សាលារៀនជំនាន់ថ្មីដូចតទៅៈ (១) ក្រសួងអប់រំ យុវជន និងកីឡាពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំ ដាក់ចេញនូវគោលការណ៍អនុវត្តតឹងរឹង ដើម្បីពង្រឹង និងការអនុវត្តច្បាប់បទដ្ឋានគតិយុទ្ធផ្សេងៗ ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងដើម្បីឲ្យការអនុវត្តការបង្រៀន និងរៀន នៅសាលារៀនជំនាន់ថ្មី ប្រកបដោយគុណភាព និងប្រសិទ្ធិភាពខ្ពស់។ ក្រសួងត្រូវបណ្តុះបណ្តាលគ្រូបង្រៀន និងវិក្រឹតការគ្រូបង្រៀន ដើម្បីពង្រឹងចំណេះដឹងផ្នែកចិត្ត-គរុកោសល្យ វិធីសាស្រ្តបង្រៀន ការដឹកនាំការបង្រៀន និងរៀន បណ្តុះបណ្តាលបច្ចេកវិទ្យា កុំព្យូទ័រ និងភាសាអង់គ្លេសដល់លោកគ្រូ អ្នកគ្រូ ឲ្យមានចំណេះដឹងទូលំទូលាយ។ (២) មន្ទីរអប់រំ យុវជន និងកីឡា គួរយកចិត្តទុកដាក់ក្នុងការចុះពិនិត្យតាមដាន

និងវាយតម្លៃជាប្រចាំ និងបណ្តុះបណ្តាលគ្រូបង្រៀនឲ្យមានចំណេះដឹង និងវិធីសាស្ត្រថ្មីៗក្នុងការបង្រៀន និងដឹកនាំការបង្រៀនឲ្យទទួលបានលទ្ធផលល្អ។ ប្រឡងជ្រើសរើសគ្រូដែលមានសមត្ថភាព ចំណេះដឹង មានមនសិការវិជ្ជាជីវៈ និងមានក្រមសីលធម៌ល្អ ប្រកបដោយភាពសុក្រឹត យុត្តិធម៌ និងគណនេយ្យភាព ដើម្បីបង្រៀននៅសាលារៀនជំនាន់ថ្មី។ (៣) សាលារៀន លោកនាយក/នាយិកាសាលា គួរយល់ឲ្យបានច្បាស់ពី តួនាទី និងភារកិច្ច របស់ខ្លួនក្នុងការគ្រប់គ្រង និងដឹកនាំ ប្រកបដោយ គណនេយ្យភាព អភិបាលកិច្ចល្អ សុក្រឹតភាព យុត្តធម៌ មានចំណេះដឹង បទពិសោធន៍ និងក្រមសីលធម៌វិជ្ជាជីវៈខ្ពស់។ ចំពោះលោកគ្រូ អ្នកគ្រូ ត្រូវពង្រឹងចំណេះដឹង និងស្វ័យសិក្សាជាប្រចាំ ដើម្បីពង្រឹង និងពង្រីកនូវចំណេះដឹងរបស់ខ្លួនឲ្យបានទូលំទូលាយ ជាពិសេសបច្ចេកវិទ្យា ICT និងភាសាអង់គ្លេស។ ចេះស្វែងយល់ និងប្រើប្រាស់វិធីសាស្ត្របង្រៀនថ្មីៗ ដើម្បីអប់រំសិស្សានុសិស្សឲ្យទទួលបាននូវចំណេះដឹងវិជ្ជាជីវៈ និងជំនាញសមស្របទីផ្សារការងារនាពេលបច្ចុប្បន្ន។ (៤) សហគមន៍ ត្រូវចូលរួមគ្រប់សកម្មភាព ក្នុងការកៀរគរទាំងសម្ភារៈ និងថវិកា ដើម្បីជួយអភិវឌ្ឍ កែលម្អ និងកសាងសាលារៀន ឲ្យមានភាពរីកចម្រើន។ ចូលរួមជំរុញ និងលើកទឹកចិត្តសិស្ស ឲ្យស្រលាញ់ការសិក្សារៀនសូត្រ ព្រមទាំងអប់រំ ពួកគេឲ្យជៀសផុតការសេពគប់មិត្តភក្តិមិនល្អ ជាពិសេសជៀសឲ្យផុតពីគ្រឿងញៀន។ (៥) ដៃគូអភិវឌ្ឍ គួរចូលរួមឧបត្ថម្ភគាំទ្រទាំងថវិកា និងបច្ចេកទេស ដើម្បីពង្រឹងសមត្ថភាពនាយក នាយិកាក៏ដូចជាលោកគ្រូ អ្នកគ្រូឲ្យមានសមត្ថភាពពេញលេញក្នុងការបង្ហាត់បង្រៀនសិស្សឲ្យមាន ចំណេះដឹង ជំនាញ ដើម្បីឲ្យពួកគេមានសមត្ថភាពពេញលេញ។ ជួយផ្តត់ផ្គង់ធនធាន និងតាមដានជាប្រចាំ ក្នុងការអនុវត្តដើម្បីធានាបាននូវគុណភាព និងប្រសិទ្ធិភាព។

### ៥.៣.២. សំណូមពរសម្រាប់ការស្រាវជ្រាវបន្ត

១. ដោយយោងតាមពេលវេលាខ្លី ការស្រាវជ្រាវនេះ មិនទាន់បានទូលំទូលាយ និងគ្រប់ជ្រុងជ្រោយនៅឡើយទេ ដោយសិក្សាតែកត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មីដោយផ្តោតទៅលើតែអនុវិទ្យាល័យមួយ នៅក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀងតែប៉ុណ្ណោះ។ ដូចនេះសូមឲ្យការសិក្សាស្រាវជ្រាវបន្តបានទូលំទូលាយ និងគ្រប់ជ្រុងជ្រោយជាងនេះ ជាពិសេសគួរជ្រើសរើសសាលារៀនជំនាន់ថ្មីឲ្យបានច្រើនជាងនេះ ព្រមទាំងពង្រីកដែនកំណត់ និងវិសាលភាពរបស់ខ្លួនឲ្យបានធំជាងនេះ ដើម្បីរកឲ្យឃើញកាន់តែច្បាស់នូវកត្តាដែលជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មីសម្រាប់ជាមូលដ្ឋានគ្រឹះ ក្នុងការប្រែក្លាយខ្លួនពីសាលារដ្ឋ ទៅជាសាលារៀនសាធារណៈស្វយ័តដែលគ្រប់គ្រងដោយវិន័យតឹងរឹងក្នុងការបំពេញភារកិច្ច និងមានគណនេយ្យភាពផ្សារភ្ជាប់ទៅនឹងការវិនិយោគខ្ពស់។

២. ម្យ៉ាងវិញទៀត ការសិក្សានេះបានសិក្សាតែលើអនុវិទ្យាល័យតែប៉ុណ្ណោះ។ ដូច្នេះសូមឲ្យអ្នកសិក្សាស្រាវជ្រាវបន្ត សិក្សាលើគ្រប់កម្រិតសិក្សាទាំង បឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ ដែលបាន

ប្រែក្លាយទៅជាសាលារៀនជំនាន់ថ្មីរួចហើយ ដើម្បីរកបកគំហើញដែលកើតចេញពីការស្រាវជ្រាវនេះកាន់តែស៊ីជំរៅ និងមានសុក្រិតភាពជាងមុន។ ហើយជាការស្រាវជ្រាវដែលប្រកបដោយប្រសិទ្ធិភាពសម្រាប់ជាទុន និងជាគន្លឹះក្នុងការពិនិត្យតាមដាន និងប្រៀបធៀបឲ្យឃើញពីភាពខុសគ្នារវាងសាលារៀនធម្មតា និងសាលារៀនជំនាន់ថ្មី ។

## ៥.៤ សេចក្តីសន្និដ្ឋាន

(១) ការសិក្សាស្រាវជ្រាវអំពី កត្តាជះឥទ្ធិពលដល់គុនភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី (អនុវិទ្យាល័យគោកព្រីង) ក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ជារួមយើងសង្កេតឃើញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី ជាទូទៅគឺ (១) សិស្សមានស្មារតីឧស្សាហ៍ព្យាយាមប្រឹងប្រែងរៀនសូត្រ គឺមានកម្រិតខ្ពស់ ៤.១៣ (M= 4.13)។ (២) គ្រូត្រូវប្រឡងចូលដើម្បីបានបង្រៀននៅសាលាជំនាន់ថ្មី គឺ មានកម្រិតខ្ពស់ ៤.០៦ (M= 4.06) និងកម្រិតខ្ពស់ចុងក្រោយគឺ(៣) គ្រូនិងសិស្សប្រើប្រាស់កុំព្យូទ័រ tablets និងស្លាយដើម្បីរៀន និង បង្រៀន មានកម្រិតខ្ពស់ ៤.០៣ (M= 4.03) ។

(២) ចំពោះការសិក្សាទៅលើផ្នែកនីមួយៗ បានរកឃើញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី មានដូចជា៖១) កត្តាសាលារៀន ស្ថិតក្នុងកម្រិតខ្ពស់ គឺ ៣.៧៦ (M=3.76) ២) កត្តាសង្គម មានកម្រិតមធ្យម ៣.៤២ ៣) កត្តាសិស្ស មានកម្រិតមធ្យម ២.៥៩ និង ៤) កត្តាគ្រួសារ មានកម្រិតមធ្យម ២.៥៩ (M=2.59)។

(៣) លទ្ធផលនៃការប្រៀបធៀបរវាងសិស្សប្រុស និង សិស្សស្រី បានបង្ហាញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី របស់សិស្សស្រីមានកម្រិតខ្ពស់ជាង សិស្សប្រុស ពោលគឺសិស្សស្រី មានកម្រិតខ្ពស់៣.៨១ (M=3.81) ហើយសិស្សប្រុសកម្រិតខ្ពស់ ៣.៧១ (M=3.71) ។

៤. តាមលទ្ធផលក្នុងការប្រៀបធៀបតាមកត្តានីមួយៗ បានបង្ហាញថា កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មី គឺ១) កត្តាសិស្ស ២) កត្តាគ្រួសារ និង ៣) កត្តាសាលារៀនមានភាពដូចគ្នា។ ចំណែកឯកត្តាសង្គមមានភាពខុសគ្នាទេ។

៥. លទ្ធផលនៃការប្រៀបធៀបតាមថ្នាក់គឺ មានភាពខុសគ្នា រវាងថ្នាក់ទី៨នឹងថ្នាក់ទី៩ គឺតម្លៃខុសគ្នា (M.d=0.34) ចំពោះកត្តាគ្រួសារ គឺមានភាពខុសគ្នារវាង ពីរកម្រិតថ្នាក់ គឺ រវាងថ្នាក់ទី៧នឹងថ្នាក់ទី៨ ( M.d=0.54) និងរវាងថ្នាក់ទី៨នឹងថ្នាក់ទី៩ (M.d=0.49) ។ ចំពោះថ្នាក់ផ្សេងទៀតមិនមានភាពខុសគ្នានោះទេ។

# ឯកសារយោង


_គោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពី ការសិក្សាពេញមួយជីវិត (ខែកក្កដា ឆ្នាំ២០១៩)
_យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដំណាក់កាលទី3 នីតិកាលទី៥
_យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ដំណាក់កាលទី3 នីតិកាលទី៥
_ប្រព័ន្ធអប់រំនៅកម្ពុជា (www.moeys.kh.com)
_ចក្ខុវិស័យ បេសកកម្ម វិស័យអប់រំ យុវជន និងកីឡា (www.moeys.kh.com)
_យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ ឆ្នាំ២០១៨–២០២៣
_ចក្ខុវិស័យអប់រំ ឆ្នាំ២០៣០
_គោលនយោបាយលើកកម្ពស់វិស័យអប់រំ (ក្រសួងអប់រំ ឆ្នាំ២០១២)
_គោលនយោបាយ ស្តីពី ធនធានមនុស្ស ក្នុងវិស័យអប់រំ ឆ្នាំ២០១២
_គោលនយោបាយ ស្តីពី គ្រូបង្រៀន ឆ្នាំ២០១៣
_គោលនយោបាយអប់រំ ឆ្នាំ២០០៩–២០១៣
_គោលនយោបាយអប់រំ ឆ្នាំ២០១៤–២០១៨
_គោលនយោបាយអប់រំ ឆ្នាំ២០១៨–២០២៣
_គោលនយោបាយ ស្តីពី វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងវិស័យអប់រំ (ថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០១៦)
_គោលនយោបាយ ស្តីពី សាលារៀនជំនាន់ថ្មី (ខែកញ្ញា ឆ្នាំ២០១៥–២០១៦
–អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (kape@kapekh.org)
–កិច្ចសម្ភាសន៍របស់លោកនាយកសាលារៀនជំនាន់ថ្មី (ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩)
–គោលការណ៍ជ្រើសរើសគ្រូបង្រៀននៃសាលារៀនជំនាន់ថ្មី (ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៧០
– www.moeys.kh.com

_NCHUNGO, JOSEPHAT (FRIDAY 6th SETEMBER, 2013): Factors Affecting Students Academic Performance, Case study Of The University Of ZAMBIA MAIN CAMPUS, School of Humanities and Science.

_M.S. Farooq , (December, 2011, page 01-14): Factors Affecting Students' Quality of Academic Performance: A Case Study Of Secondary Shool Level, University Of PUNJAB, PAKISTAN.

_A.H.Chaudhry, (December, 2011, page 01-14): Factors Affecting Students' Quality of Academic Performance: A Case Study Of Secondary Shool Level, University Of PUNJAB, PAKISTAN.

_M.Shafiq, (December, 2011, page 01-14): Factors Affecting Students' Quality of Academic Performance: A Case Study Of Secondary Shool Level, University Of PUNJAB, PAKISTAN.

_G. Berhanu, (December, 2011, page 01-14): Factors Affecting Students' Quality of Academic Performance: A Case Study Of Secondary Shool Level, University Of Gothenburg, Sweden.

_JAMILLAH H. MAGANGA, (2016): Factors Affecting Student' Academic Performance, A Case Study Of Public School In ILALA District, University of TANZANIA.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១៖ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

លេខ [illegible] អយក.វិជអ

*ថ្ងៃព្រហស្បតិ៍ ១៤ កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២*
*រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩*

**ជម្រាបមក**

**លោកនាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**
**លោកនាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦។

**យោង** ៖ កម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ឆ្នាំសិក្សា២០១៨-២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកនាយក និងលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ចំនួន៨១នាក់ ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្ត ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩។

អាស្រ័យហេតុនេះ សូមលោកនាយក និងលោកប្រធានជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមលោកនាយក និងលោកប្រធានទទួលនូវការរាប់អានពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- សាលារាជធានី-ខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
  "ដើម្បីជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

## ឧបសម្ព័ន្ធទី២៖ លិខិតឧទ្ទេសនាមរបស់វិទ្យាស្ថានជាតិអប់រំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**

**លេខ** ១១៨ **វជអ.** ស.ក

មន្ទីរ អ.យ.ក ខេត្តស្វាយរៀង
លេខ ៦៥៨
ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩
ម៉ោង........

**លិខិតឧទ្ទេសនាម**

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ នៅវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងបាត់ដំបង សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម និងតាមរាជធានី-ខេត្តនានា ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩៖

| ល.រ | គោត្តនាម និងនាម | ភេទ | សាលាគរុកោសល្យ និង រាជធានី-ខេត្ត |
|---|---|---|---|
| ១ | កុយ វ៉ាឡង់ទីណា | ប | ខេត្តកំពង់ធំ |
| ២ | គុជ សំអើល | ប | ខេត្តស្វាយរៀង |
| ៣ | ឃិន សម្បត្តិ | ប | ខេត្តតាកែវ |
| ៤ | ឯន ណារី | ប | រាជធានីភ្នំពេញ |
| ៥ | ង៉ែត វ៉ារុធ | ប | ខេត្តតាកែវ |
| ៦ | ងួន ផល្លី | ស | ខេត្តបាត់ដំបង |
| ៧ | ឆន ឈាង | ប | សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម |
| ៨ | ឆាយ បូនី | ស | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង |
| ៩ | ជា តត | ប | ខេត្តតាកែវ |
| ១០ | ជា វណ្ណារ៉ា | ប | ខេត្តកំពង់ឆ្នាំង |
| ១១ | ញ៉ែត សំអុល | ប | ខេត្តតាកែវ |
| ១២ | ទីម ពិន្ទុ | ប | រាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ស្ពឺ កំពង់ធំ ស្ទឹងត្រែង ឧត្តរមានជ័យ និងខេត្តមណ្ឌលគិរី |
| ១៣ | ទុយ សុវណ្ណារិទ្ធ | ប | រាជធានីភ្នំពេញ ខេត្តកំពង់ចាម បាត់ដំបង និងខេត្តសៀមរាប |
| ១៤ | ធាម ហេង | ប | ខេត្តក្រចេះ |
| ១៥ | ប៉ុម សូគ៌ា | ប | ខេត្តកណ្តាល |
| ១៦ | ផុន វណ្ណៈ | ប | ខេត្តកណ្តាល |
| ១៧ | ផូ សុវណ្ណ | ប | រាជធានីភ្នំពេញ |

1

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥-២៣) ២១៥/៨៨៤ គេហទំព័រ www.nie.edu.kh

| | | | |
|---|---|---|---|
| ១៨ | ពុត ពិសី | ប | ខេត្តកំពត |
| ១៩ | ពេជ្រ វង្សី | ស | ខេត្តត្បូងឃ្មុំ |
| ២០ | ភោគ តុលា | ប | ខេត្តស្វាយរៀង |
| ២១ | លី កុសល | ប | ខេត្តកំពង់ចាម |
| ២២ | លឹម សេងហួត | ប | ខេត្តបាត់ដំបង |
| ២៣ | លុន ហ៊ាប | ប | ខេត្តកំពង់ចាម |
| ២៤ | លុយ គឹមសាន | ប | ខេត្តកណ្តាល |
| ២៥ | វ៉ា សុភក្តិ | ប | ខេត្តព្រៃវែង |
| ២៦ | សន តារាវស្សី | ប | ខេត្តកណ្តាល |
| ២៧ | ស៊ើយ វង្សស៊ី | ប | ខេត្តស្ទឹងត្រែង |
| ២៨ | សាម សុនិត | ប | ខេត្តកំពង់ចាម |
| ២៩ | សុទ្ធ ស្រីនាង | ស | ខេត្តកំពង់ស្ពឺ |
| ៣០ | សៀង គីមឈៀន | ប | ខេត្តកណ្តាល |
| ៣១ | ស្រី មៅ | ប | រាជធានីភ្នំពេញ |
| ៣២ | ហៃល ម៉ូណា | ប | រាជធានីភ្នំពេញ |
| ៣៣ | ហៃយ ចម្លង | ស | រាជធានីភ្នំពេញ |
| ៣៤ | ឡាយ វីរៈ | ប | ខេត្តឧត្តរមានជ័យ |
| ៣៥ | ឡុង ចំណាន | ប | ខេត្តកំពង់ចាម |
| ៣៦ | អ៊ិន ចាន់ថា | ប | ខេត្តស្វាយរៀង |
| ៣៧ | អ៊ីវ សុធី | ប | រាជធានីភ្នំពេញ |
| ៣៨ | អ៊ឹម សិរីវឌ្ឍ | ប | ខេត្តតាកែវ |
| ៣៩ | អ៊ុក រិទ្ធី | ប | ខេត្តសៀមរាប |
| ៤០ | អុន សេងទ្រី | ប | ខេត្តកំពង់ធំ |
| ៤១ | អៀង គីមឈាន | ប | ខេត្តកំពង់ចាម |

ថ្ងៃសុក្រ ១៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័កព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៩

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណរ៉ា

**កន្លែងទទួល៖**

-សាលារាជធានី-ខេត្តពាក់ព័ន្ធ

-អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក

-មន្ទីរ អ.យ.ក រាជធានី-ខេត្តពាក់ព័ន្ធ

"ដើម្បីសហការ"

-សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

# ឧបសម្ព័ន្ធទី៣៖ គណៈកម្មការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខៈ** ៩៦២៩ **អយក.** ១៨

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យូន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ [illegible] ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ :.....✓..........វជអ.

**បំណែងចែកគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ**
**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**
**ដែលប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩**
**នៅវិទ្យាស្ថានជាតិអប់រំ**

**គណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ**

| ក្រុម១ នៅអគារ A បន្ទប់ A5 | ក្រុម២ នៅអគារ H បន្ទប់ H ជាន់ទី១ |
|---|---|
| ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា | ឯកឧត្តមបណ្ឌិត ជ័យ សារិន |
| លោកបណ្ឌិត ម៉ុក សារ៉ុម | លោកបណ្ឌិត នូវ វីរ៉ា |
| ឯកឧត្តមបណ្ឌិត ស៊ិន សេងហុក | លោកជំទាវបណ្ឌិត ឃួន វិច្ឆិកា |
| ឯកឧត្តម លឹម សុធា | លោកបណ្ឌិត នី រដ្ឋា |
| ឯកឧត្តម នៀ សុផន | លោកបណ្ឌិត ឈូក ច័ន្ទឆាយា |
| លោកបណ្ឌិត ស៊ិត សេង | លោកបណ្ឌិត ឌី ខាំបូលី |
| លោក ឌី បុណ្ណា | |

**គណៈកម្មការកណ្ដាល និងរៀបចំ**

| ក្រុម១ នៅអគារA បន្ទប់A5 | ក្រុម២ នៅអគារH បន្ទប់H ជាន់ទី១ |
|---|---|
| លោកស្រី ប៊ុន សុផានី | លោក ចាប រតនា |
| លោក ម៉ន មុនិន្ទ | លោក សៀង វាសនា |
| លោក លឹម វ៉ាន់ | លោក ឡុច ចាន់ថន |
| លោក លន លីណា | |

ថ្ងៃអាទិត្យ ១២កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៩

**នាយកវិទ្យាស្ថានជាតិអប់រំ**

អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តមភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥-២៣) ២១៥/៥៨៤ គេហទំព័រ www.nie.edu.kh

# ឧបសម្ព័ន្ធទី៤៖ គណៈកម្មការមេប្រយោគ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខៈ** ៩៦២៩ **អយក.** ១៣
(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

**យោង ៖** -បទប្បញ្ញត្តិស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** | ខុទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** | ខុទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម **យក់ ឌ៉ុយ** | ខុទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម **លាង សេងហាក់** | ខុទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តម **ម៉ក់ ងយ** | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកដឹកនាំវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិត នៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១១កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារៈវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

## ឧបសម្ព័ន្ធទី៥៖ គណៈកម្មការកណ្ដាល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខៈ ៩៦៣១ អយក. [illegible]

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

**យោង** ៖-បទប្បញ្ញត្តិស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការកណ្ដាល** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-លោកស្រី ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-លោក ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-លោក ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤-លោក លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោក សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវមកបំពេញភារកិច្ចនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩ និងថ្ងៃបន្តបន្ទាប់ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១១រោច ខែកត្ដិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២២ខែវិច្ឆិកា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ

"ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ - ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

## ឧបសម្ព័ន្ធទី៦៖ កំណាត់បង្ហាញរបស់មន្ទីរអប់រំ យុវជន និងកីឡាខេត្តស្វាយរៀង

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**មន្ទីរអប់រំ យុវជន និងកីឡា**

**ខេត្តស្វាយរៀង**

# កំណាត់បង្ហាញ

**ឈ្មោះកន្លែងផ្ញើមក ៖** វិទ្យាស្ថានជាតិអប់រំ

**កម្មវត្ថុ ៖** [illegible]

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំ[illegible] ព.ស ២៥៦៣

ស្វាយរៀង ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩

មន្ត្រីទទួលលិខិត

[illegible]

ស្វាយរៀង ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៩

ប្រធានការិយាល័យរដ្ឋបាល

ស៊ុស_ឌីណា

**យោបល់លោកប្រធានមន្ទីរ**

[illegible]

27/05/19

ខៀវ_សំអុល

**យោបល់លោកអនុប្រធានមន្ទីរ**

**ទទួលបន្ទុក**

## ឧបសម្ព័ន្ធទី៧៖ កម្រងសំណួរ

**ប្រធានបទ៖ កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មីគោកព្រីង ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង**

Factors Influencing the students' Quality in Academic Performance in KOK PRING New Generation School in Svay Chrum district, Svay Rieng province.

### កម្រងសំណួរសម្រាប់សិស្ស

ខ្ញុំបាទឈ្មោះ **អ៊ិន ចាន់ថា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ កំពុងធ្វើនិក្ខេបបទក្រោមប្រធានបទ **កត្តាដែលជះឥទ្ធិពដល់គុណភាពនៃការសិក្សារបស់សិស្សសាលាជំនាន់ថ្មីគោកព្រីង**" ដើម្បីបញ្ចប់ការសិក្សា។

ក្នុងការរៀបចំកម្រងសំណួរនេះឡើងក្នុងគោលបំណងដើម្បី ប្រមូលទិន្នន័យទាក់ទងនឹងកត្តាដែលជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្ស ព្រមទាំងភាពខុសគ្នា និងដូចគ្នាទៅលើកត្តាដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្សដោយបែងចែកតាមកម្រិតថ្នាក់ និងភេទ នៅសាលាជំនាន់ថ្មីគោកព្រីង។

កម្រងសំណួរនេះបែងចែកជា ពីរផ្នែកគឺ៖

**ផ្នែកទី១៖** ព័ត៌មានទូទៅរបស់សិស្ស

**ផ្នែកទី២៖** កត្តាដែលជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សនៅសាលាជំនាន់ថ្មីគោកព្រីង

អាស្រ័យហេតុនេះ សូមប្អូនៗសិស្សានុសិស្សជួយផ្តល់ចម្លើយនូវសំណួរខាងក្រោមដោយក្តីអនុគ្រោះ។ គ្រប់ចម្លើយទាំងអស់របស់ប្អូនៗនឹងត្រូវបានរក្សាជាការសម្ងាត់។ ការចូលរួមរបស់ប្អូនៗពិតជាមានសារៈសំខាន់ណាស់ក្នុងការពង្រឹងគុណភាពអប់រំនៅក្នុងប្រទេសកម្ពុជាយើង។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្អូនៗសិស្សានុសិស្សទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃជាមួយខ្ញុំក្នុងការសិក្សាស្រាវជ្រាវនេះ។

ឈ្មោះ និងហត្ថលេខា

អ៊ិន ចាន់ថា

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ក្រសួងអប់រំ យុវជន និងកីឡា
## វិទ្យាស្ថានជាតិអប់រំ

# កម្រងសំណួរសម្រាប់សិស្ស

ខ្ញុំបាទឈ្មោះ អ៊ិន ចាន់ថា ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ កំពុងធ្វើនិក្ខេបបទក្រោមប្រធានបទ "**កត្តាជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សសាលារៀនជំនាន់ថ្មី ក្នុងខេត្តស្វាយរៀង**" ដើម្បីបញ្ចប់ការសិក្សា។

អាស្រ័យហេតុនេះ សូមប្អូនៗសិស្សានុសិស្សជួយផ្តល់ចម្លើយនូវសំណួរខាងក្រោមដោយក្តីអនុគ្រោះ។ គ្រប់ចម្លើយទាំងអស់របស់ប្អូនៗនឹងត្រូវបានរក្សាជាការសម្ងាត់។ ការចូលរួមរបស់ប្អូនៗពិតជាមានសារៈសំខាន់ណាស់ក្នុងការពង្រឹងគុណភាពអប់រំនៅក្នុងប្រទេសកម្ពុជាយើង។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្អូនៗសិស្សានុសិស្សទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃជាមួយខ្ញុំក្នុងការសិក្សាស្រាវជ្រាវនេះ។

កម្រងសំណួរនេះបែងចែកជា ២ផ្នែកគឺ៖

### ១. ព័ត៌មានទូទៅ

សូមប្អូនៗសរសេរបំពេញឈ្មោះ ខេត្ត ស្រុក និងសាលា ព្រមទាំងគូសសញ្ញា (✓) ក្នុងប្រអប់ឲ្យបានត្រឹមត្រូវ។

១. ឈ្មោះខេត្ត ៖...............................................................................

២. ឈ្មោះស្រុក ៖...............................................................................

៣. ឈ្មោសាលា ៖...............................................................................

៤. ថ្នាក់ទី ៖ ១. ☐ ៧ ២.☐ ៨ ៣.☐ ៩

៥. ភេទ ៖ ១.☐ ប្រុស ២.☐ ស្រី

### ២. ខ្លឹមសារកម្រងសំណួរ

សូមប្អូនៗជ្រើសរើសនូវចម្លើយមួយដែលសមស្របដោយគូសសញ្ញា(✓)ក្នុងតារាងតាមលេខសម្គាល់នីមួយៗ។

កំណត់សម្គាល់៖
១ = គ្មានសោះ
២ = មានតិចតួច
៣ = មានជាមធ្យម
៤ = មានខ្លាំង
៥ = មានខ្លាំងណាស់

| ១. កត្តាផ្ទាល់ខ្លួន | | | | | | |
|---|---|---|---|---|---|---|
| តើកត្តាផ្ទាល់ខ្លួនបានជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់ប្អូនដែរឬទេ? | | | | | | |
| ល.រ | ខ្លឹមសារ | ១ | ២ | ៣ | ៤ | ៥ |
| ១. | សិស្សមានស្មារតីឧស្សាហ៍ព្យាយាមប្រឹងប្រែងរៀនសូត្រ។ | | | | | |
| ២. | ជួយធ្វើកិច្ចការផ្ទះ។ | | | | | |
| ៣. | មានគោលដៅច្បាស់លាស់ក្នុងការសិក្សា។ | | | | | |
| ៤. | ជួយមើលថែប្អូននៅផ្ទះ។ | | | | | |
| ៥. | ពុះពារគ្រប់ឧបសគ្គ។ | | | | | |
| ៦. | ការលើកត្រូវ (ការគិតបានត្រឹមត្រូវ)។ | | | | | |
| ៧. | សេពគ្រឿងញៀន។ | | | | | |
| ៨. | ការដើរលេង និងមានមិត្តភក្តិច្រើន។ | | | | | |
| ៩. | តំណពូជ (បងប្អូន ឪពុកម្តាយមិនបានទទួលការសិក្សា)។ | | | | | |
| ១០. | មានការតាំងចិត្តខ្ពស់ក្នុងការសិក្សារៀនសូត្រ។ | | | | | |
| ២.កត្តាគ្រួសារ | | | | | | |
| តើកត្តាគ្រួសារបានជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់ប្អូនដែរឬទេ។ | | | | | | |
| ១១. | គ្រួសារក្រីក្រ។ | | | | | |
| ១២. | ការចំណាកស្រុករបស់គ្រួសារ។ | | | | | |
| ១៣. | គំនាបគ្រួសារ (មិនផ្តល់ឱកាសឲ្យកូនបានចូលរៀន)។ | | | | | |
| ១៤. | ខ្វះភាពកក់ក្តៅ (ឪពុក ម្តាយរវល់ការងារ)។ | | | | | |
| ១៥. | គ្មានការលើកទឹកចិត្តពីក្រុមគ្រួសារ។ | | | | | |
| ១៦. | ការរើសអើង (កូនស្រីមិនបាច់ចូលរៀន)។ | | | | | |
| ១៧. | អំពើហឹង្សាក្នុងគ្រួសារ។ | | | | | |
| ១៨. | គ្មានមធ្យោបាយធ្វើដំណើរ។ | | | | | |
| ១៩. | ខ្ញុំព្យាយាមចងចាំពាក្យដោយការប្រកបរបស់វា។ | | | | | |
| ២០. | គ្រួសារជាអ្នកមាន។ | | | | | |
| ២១. | ប្រាក់វិភាគទានពីឪពុកម្តាយសិស្ស។ | | | | | |
| ៣.កត្តាសាលារៀន | | | | | | |
| តើសាលារៀនជាកត្តាដែលជះឥទ្ធិបលដល់គុណភាពនៃការសិក្សារបស់ប្អូនដែរឬទេ? | | | | | | |
| ២២. | នាយកសាលាដឹកនាំបានល្អ។ | | | | | |
| ២៣. | នាយកសាលាមានគណនេយ្យភាពក្នុងការដឹកនាំ និងគ្រប់គ្រង។ | | | | | |
| ២៤. | បរិស្ថានសាលាល្អ។ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ២៥. | សាលាមានសួនច្បារ និងសួនជីវចំរុះ។ | | | | | |
| ២៦. | សាលាមានអាគារសិក្សាគ្រប់គ្រាន់ និងទំនើបៗ។ | | | | | |
| ២៧. | គ្រូបង្រៀនប្រកបដោយ ចំណេះដឹង សមត្ថភាពខ្ពស់ | | | | | |
| ២៨. | គ្រូបង្រៀនមានភាពរួសរាយ រាក់ទាក់ សុភាពរាបសា ប្រកបដោយស្នាមញញឹម។ | | | | | |
| ២៩. | មានសម្ភារៈសិក្សាគ្រប់គ្រាន់។ | | | | | |
| ៣០. | សាលាមានបណ្ណាល័យសម្រាប់អានសៀវភៅ។ | | | | | |
| ៣១. | កម្មវិធីសិក្សាច្បាស់លាស់ និងត្រូវទៅតាមកម្រិតថ្នាក់របស់សិស្ស។ | | | | | |
| ៣២. | មានសៀវភៅសិក្សាគោលគ្រប់គ្រាន់។ | | | | | |
| ៣៣. | មានក្លឹបសិក្សា (សម្រាប់ជួយបំប៉នសិស្សខ្សោយ)។ | | | | | |
| ៣៤. | មានការប្រឡងដើម្បីបានចូលរៀននៅសាលជំនាន់ថ្មី។ | | | | | |
| ៣៥. | ការសិក្សាជាក្រុម។ | | | | | |
| ៣៦. | ធ្វើតេស្តស្ដង់ដា(ប្រចាំខែ ឆមាស និងដំណាច់ឆ្នាំ)។ | | | | | |
| ៣៧. | ការចូលរួមសកម្មភាពនានាក្នុង និងក្រៅថ្នាក់។ | | | | | |
| ៣៨. | ទស្សនកិច្ចសិក្សា។ | | | | | |
| ៣៩. | គ្រូត្រូវប្រឡងចូលដើម្បីបានបង្រៀននៅសាលាជំនាន់ថ្មី។ | | | | | |
| ៤០. | គ្រូ និងសិស្សប្រើប្រាស់កុំព្យូទ័រ tablets និងស្លាយដើម្បីរៀន និងបង្រៀន។ | | | | | |
| ៤១. | មានការអប់រំសុខភាព និងកីឡា។ | | | | | |
| **៤.កត្តាសង្គម/សហគមន៍** | | | | | | |
| តើសហគមន៍បានជះឥទ្ធិពលដល់គុណភាពនៃការសិក្សារបស់សិស្សដែរឬទេ? | | | | | | |
| ៤២. | ភូមិ ឃុំមានសុវត្ថិភាព។ | | | | | |
| ៤៣. | គ្មានល្បែងស៊ីសង។ | | | | | |
| ៤៤. | ភូមិនៅជិតសាលា។ | | | | | |
| ៤៥. | គ្មានអំពើហឹង្សា ចោរកម្ម ។ | | | | | |
| ៤៦. | គ្មានការជួញដូរស្ត្រី និងកុមារ។ | | | | | |
| ៤៧. | សហគមន៍មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់។ | | | | | |
| ៤៨. | មានសេវាបម្រើប្រជាពលរដ្ឋល្អ។ | | | | | |
| ៤៩. | ការចូលរួមបដិភាគក្នុងការកសាង និងអភិវឌ្ឍសាលារៀនពីមាតាបិតាសិស្ស។ | | | | | |
| ៥០. | ចូលរួមគាំទ្រពីអង្គការនានា។ | | | | | |
| ៥១. | ការគាំទ្រពីក្រសួងអប់រំ។ | | | | | |
| ៥២. | សេវាថែរក្សាសុខភាពល្អ។ | | | | | |

**សូមអរគុណ** !